ក្រុមប្រឹក្សាអ្នកច្បាប់
អគ្គលេខាធិការដ្ឋាន
ចូល
លេខ: ១៦៦
ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០២៣
ម៉ោង: ១៥:០០

# ព្រះរាជក្រម

នស/រកម/០៥២៣/០០៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីសារពើពន្ធ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភា លើកទី៩ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៣ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង



https://www.moj.gov.kh/kh/law-regular

# ច្បាប់
# ស្តីពី
# សារពើពន្ធ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



https://www.moj.gov.kh/kh/law-regular

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-** គោលបំណង

ច្បាប់នេះកំណត់អំពីវិធាន នីតិវិធី និងលក្ខខណ្ឌ ព្រមទាំងប្រមូលផ្តុំនូវបទប្បញ្ញត្តិស្តីពីពន្ធដារ ក្នុងគោលបំណងដើម្បីគ្រប់គ្រងការប្រមូលពន្ធអាករសម្រាប់ជាគុណប្រយោជន៍ដល់ថវិការដ្ឋ។

**មាត្រា២ .-** វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តលើការគ្រប់គ្រងការប្រមូលពន្ធអាករគ្រប់ប្រភេទដែលមានចែងក្នុង ច្បាប់នេះនៅព្រះរាជាណាចក្រកម្ពុជា។

# ជំពូកទី២
# ពន្ធលើប្រាក់ចំណូល
## ផ្នែកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៣ .-** កម្មវត្ថុនៃពន្ធ

ពន្ធលើប្រាក់ចំណូល គឺជាកាតព្វកិច្ចរបស់អ្នកជាប់ពន្ធដែលមានប្រាក់ចំណូលជាប់ពន្ធទទួលបាន ក្នុងឆ្នាំជាប់ពន្ធ។

**មាត្រា៤ .-** វិសាលភាពនៃពន្ធ

ពន្ធលើប្រាក់ចំណូលអនុវត្តលើអ្នកជាប់ពន្ធនិវាសនជនចំពោះប្រាក់ចំណូលប្រភពកម្ពុជានិង ប្រាក់ចំណូលប្រភពបរទេស និងអ្នកជាប់ពន្ធអនិវាសនជនចំពោះប្រាក់ចំណូលប្រភពកម្ពុជា។

**មាត្រា៥ .-** និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងជំពូកនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- អ្នកជាប់ពន្ធនិវាសនជន សំដៅដល់៖

ក- រូបវន្តបុគ្គលដែលមាននិវាសនដ្ឋានឬមានកន្លែងស្នាក់នៅជាគោលដើមនៅក្នុងព្រះរាជាណាចក្រ កម្ពុជា ឬដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី១៨២(មួយរយប៉ែតសិបពីរ) ថ្ងៃ នៅក្នុងរយៈពេល១២(ដប់ពីរ)ខែណាមួយដែលបានបញ្ចប់ក្នុងឆ្នាំជាប់ពន្ធចរន្ត។

ខ- នីតិបុគ្គលឬក្រុមហ៊ុនសហកម្មសិទ្ធិ ដែលត្រូវបានបង្កើតឬត្រូវបានគ្រប់គ្រងនៅក្នុង ព្រះរាជាណាចក្រកម្ពុជា ឬដែលមានកន្លែងប្រកបអាជីវកម្មជាគោលដើមនៅក្នុង ព្រះរាជាណាចក្រកម្ពុជា។

២- អ្នកជាប់ពន្ធអនិវាសនជន សំដៅដល់ បុគ្គលណាមួយដែលមិនមែនជាអ្នកជាប់ពន្ធនិវាសនជន តាមកថាខណ្ឌទី១នៃមាត្រានេះ និងទទួលប្រាក់ចំណូលប្រភពកម្ពុជា។



https://www.moj.gov.kh/kh/law-regular

៣_ នីតិបុគ្គល សំដៅដល់ សហគ្រាសឬអង្គភាពនានាដែលប្រកបអាជីវកម្ម ទោះបីជាបានឬមិនទាន់បានទទួលស្គាល់ជាផ្លូវការពីស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលក្តី។ ពាក្យ **នីតិបុគ្គល** រួមបញ្ចូលផងដែរនូវស្ថាប័នរាជរដ្ឋាភិបាល អង្គការសាសនា អង្គការសប្បុរសធម៌ អង្គការមិនស្វែងរកចំណេញ សមាគម គណបក្សនយោបាយ និងគ្រឹះស្ថានអចិន្ត្រៃយ៍របស់បុគ្គលអនិវាសនជនដែលតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សម្រាប់តែគោលដៅនៃការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល ពាក្យ **នីតិបុគ្គល** ពុំរាប់បញ្ចូលទេនូវក្រុមហ៊ុនសហកម្មសិទ្ធិឬសហគ្រាសឯកបុគ្គល។

៤_ គ្រឹះស្ថានអចិន្ត្រៃយ៍ សំដៅដល់ ទីកន្លែងប្រកបអាជីវកម្មជាប់លាប់នៅព្រះរាជាណាចក្រកម្ពុជា សាខារបស់ក្រុមហ៊ុនបរទេស ឬភ្នាក់ងារនិវាសនជនដែលនៅព្រះរាជាណាចក្រកម្ពុជា ដែលតាមរយៈនេះ បុគ្គលអនិវាសនជនប្រកបអាជីវកម្មរបស់ខ្លួន។ ពាក្យ **គ្រឹះស្ថានអចិន្ត្រៃយ៍** រួមបញ្ចូលផងដែរនូវបណ្តាញ ឬរូបភាពទំនាក់ទំនងផ្សេងទៀត ដែលតាមរយៈនេះ បុគ្គលអនិវាសនជនធ្វើសកម្មភាពសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។ បុគ្គលណាមួយអាចត្រូវបានចាត់ទុកជាគ្រឹះស្ថានអចិន្ត្រៃយ៍របស់បុគ្គលអនិវាសនជននៅព្រះរាជាណាចក្រកម្ពុជា ក្នុងករណីបុគ្គលនោះមាននិងអនុវត្តជាប្រចាំនូវសិទ្ធិអំណាចក្នុងការចុះកិច្ចសន្យាក្នុងនាមបុគ្គលអនិវាសនជននោះ ឬបំពេញតួនាទីចម្បងក្នុងការសម្របសម្រួលដើម្បីឈានដល់ការចុះកិច្ចសន្យា។ គ្រឹះស្ថានអចិន្ត្រៃយ៍ត្រូវបានចាត់ទុកជានីតិបុគ្គលនិវាសនជនចំពោះតែប្រាក់ចំណូលប្រភពកម្ពុជាប៉ុណ្ណោះ។

៥_ ក្រុមហ៊ុនសហកម្មសិទ្ធិ សំដៅដល់ សហគ្រាសដែលបង្កើតឡើងដោយកិច្ចសន្យារវាងបុគ្គលពីរ ឬច្រើន ដែលដាក់រួមគ្នានូវទ្រព្យសម្បត្តិឬចំណេះដឹងឬសកម្មភាពរបស់បុគ្គលទាំងនោះ ដើម្បីប្រកបអាជីវកម្ម ឬពាណិជ្ជកម្មរួមក្នុងគោលបំណងរកប្រាក់ចំណេញ។ ក្នុងនិយមន័យនេះ ក្រុមហ៊ុនសហកម្មសិទ្ធិ រួមមាន ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនិងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។ លក្ខខណ្ឌដើម្បីទទួលបាននូវនីតិបុគ្គល ឬនីតិបុគ្គលិកលក្ខណៈនៃក្រុមហ៊ុនសហកម្មសិទ្ធិដូចមានកំណត់ក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មនិង ច្បាប់ដទៃជាធរមាន មិនត្រូវបានយកមកអនុវត្តសម្រាប់គោលបំណងប្រមូលពន្ធលើប្រាក់ចំណូលឡើយ។ ក្រុមហ៊ុនសហកម្មសិទ្ធិ មិនរាប់បញ្ចូលទេនូវក្រុមហ៊ុនមូលធន គ្រឹះស្ថានអចិន្ត្រៃយ៍ ឬសហគ្រាសឯកបុគ្គល។

៦_ សហគ្រាសឯកបុគ្គល សំដៅដល់ សហគ្រាសដែលបានបង្កើតឡើងដោយរូបវន្តបុគ្គលតែម្នាក់ ហើយទ្រព្យសម្បត្តិរបស់ម្ចាស់សហគ្រាសឯកបុគ្គលជាដើមទុនរបស់សហគ្រាសឯកបុគ្គល។ ក្នុងនិយមន័យនេះ ប្តី ប្រពន្ធ និងកូនក្នុងបន្ទុក ត្រូវចាត់ទុកថាជារូបវន្តបុគ្គលតែម្នាក់។

៧_ អាជីវកម្ម សំដៅដល់ សកម្មភាពសេដ្ឋកិច្ចដូចមានចែងក្នុងកថាខណ្ឌទី៩នៃមាត្រា១៩០នៃច្បាប់នេះ របស់បុគ្គលដែលផលិតនិងលក់ទំនិញ ផ្គត់ផ្គង់សេវា ភតិសន្យា ជួលឬលក់ទ្រព្យសម្បត្តិ ឬសកម្មភាពផ្សេងទៀត រួមទាំងសកម្មភាពរបស់ស្ថាប័នឬអង្គការនានាដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រានេះ។

៨_ ភាគលាភ សំដៅដល់ ចំណែកជាសាច់ប្រាក់ឬជាទ្រព្យដែលនីតិបុគ្គលបានចែកឱ្យអ្នកចូលហ៊ុនទៅតាមកម្រិតនៃភាគកម្មរបស់ខ្លួននៅក្នុងដើមទុនផ្ទាល់របស់នីតិបុគ្គល លើកលែងតែការបែងចែកមូលធននៅពេលជម្រះបញ្ជីរំលាយក្រុមហ៊ុនទាំងស្រុង។ ចំណែកណាមួយដែលចាត់ទុកថាជាភាគលាភឬមិនមែនជាភាគលាភ ត្រូវផ្អែកតាមលក្ខខណ្ឌខាងលើនេះ ដោយពុំគិតថានីតិបុគ្គលមានឬគ្មានប្រាក់ចំណូលសុទ្ធក្នុងឆ្នាំជាប់ពន្ធឬឆ្នាំមុនៗឡើយ។



https://www.moj.gov.kh/kh/law-regular

៩_ អ្នកចូលហ៊ុន សំដៅដល់ បុគ្គលដែលមានចំណែកភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់នីតិបុគ្គល។ សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណូល នីតិបុគ្គលណាមួយទោះបីមិនមែនជាក្រុមហ៊ុនមូលធនក្តី ត្រូវចាត់ទុកដូចជាក្រុមហ៊ុនមូលធន ហើយបុគ្គលដែលមានចំណែកភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់នីតិបុគ្គលឬក៏បុគ្គលអាចបានទទួលប្រាក់ចំណូលក្នុងឋានៈជាអ្នកបានចូលរួមក្នុងនីតិបុគ្គលនោះ ត្រូវចាត់ទុកថាជាអ្នកចូលហ៊ុនរបស់នីតិបុគ្គលដែរ។

១០_ បុគ្គលទាក់ទិន សំដៅដល់៖

ក_ សមាជិកណាម្នាក់ក្នុងវង្សញាតិអ្នកជាប់ពន្ធ។

ខ_ សហគ្រាសដែលគ្រប់គ្រងដោយផ្ទាល់ឬដោយប្រយោលលើអ្នកជាប់ពន្ធ ឬសហគ្រាសត្រូវបានអ្នកជាប់ពន្ធគ្រប់គ្រងដោយផ្ទាល់ឬដោយប្រយោល ឬក៏សហគ្រាសនោះនិងអ្នកជាប់ពន្ធស្ថិតនៅក្រោមការគ្រប់គ្រងរួមគ្នា ឬទំនាក់ទំនងរវាងគ្រឹះស្ថានអចិន្ត្រៃយ៍និងអ្នកជាប់ពន្ធអនិវាសនជន។ ពាក្យ **គ្រប់គ្រង** មានន័យថា មានកម្មសិទ្ធិចាប់ពី២០(ម្ភៃ)ភាគរយឡើងទៅលើតម្លៃឬសិទ្ធិបោះឆ្នោតនៃភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់សហគ្រាស។ ដើម្បីកំណត់ទំហំនៃការគ្រប់គ្រងរបស់អ្នកជាប់ពន្ធជារូបវន្តបុគ្គលណាម្នាក់ត្រូវគិតបញ្ចូលទាំងអស់នូវកម្មសិទ្ធិលើភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់រូបវន្តបុគ្គលនោះ និងកម្មសិទ្ធិផ្ទាល់ឬប្រយោលរបស់សហព័ទ្ធអ្នកជាប់ពន្ធ។ ដោយមិនគិតពីលក្ខខណ្ឌខាងលើនេះ រដ្ឋបាលសារពើពន្ធអាចវិនិច្ឆ័យលើការគ្រប់គ្រងដោយផ្ទាល់ឬដោយប្រយោលទៅតាមករណីជាក់ស្តែងនីមួយៗ ដើម្បីកំណត់ថាមានឬគ្មានការគ្រប់គ្រង។

១១_ គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ សំដៅដល់ គម្រោងវិនិយោគដែលទទួលបានវិញ្ញាបនបត្រចុះបញ្ជីពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឬអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត។

១២_សម្ព័ន្ធអាជីវកម្ម សំដៅដល់ សកម្មភាពអាជីវកម្មរួមគ្នារវាងអ្នកជាប់ពន្ធនិវាសនជននិងអ្នកជាប់ពន្ធនិវាសនជន ឬអ្នកជាប់ពន្ធនិវាសនជននិងអ្នកជាប់ពន្ធអនិវាសនជន ឬអ្នកជាប់ពន្ធអនិវាសនជននិងអ្នកជាប់ពន្ធអនិវាសនជន ចាប់ពីពីរឡើងទៅដោយមិនបង្កើតជានីតិបុគ្គលដាច់ដោយឡែក។

១៣_ ធនាគារ សំដៅដល់ អង្គភាពណាមួយដែលអនុវត្តជាប្រក្រតីនូវប្រតិបត្តិការណាមួយក្នុងចំណោមប្រតិបត្តិការដូចខាងក្រោម៖

ក_ ការផ្តល់ឥណទានគ្រប់ប្រភេទចំពោះសាធារណជនដោយមានកម្រៃ រាប់បញ្ចូលទាំងឥណទានភតិសន្យាហិរញ្ញវត្ថុ។

ខ_ ការទទួលប្រាក់បញ្ញើមិនមានមុខសញ្ញាប្រើពីសាធារណជន។

គ_ ប្រព្រឹត្តិកម្មនិងការដាក់ឱ្យអតិថិជនប្រើប្រាស់នូវមធ្យោបាយទូទាត់ជារូបិយវត្ថុឬជារូបិយបណ្ណ។

១៤_ ប្រាក់ចំណូលដុល សំដៅដល់ ប្រាក់ចំណូលដែលបានមកពីប្រតិបត្តិការអាជីវកម្មគ្រប់ប្រភេទ រួមទាំងចំណូលបន្ទាប់បន្សំនិងចំណូលផ្សេងៗដែលមិនទាន់កាត់កងចំណាយ។

១៥_ ប្រាក់ចំណូលសុទ្ធ សំដៅដល់ លទ្ធផលបានមកពីការយកប្រាក់ចំណូលដុលកាត់កងនូវចំណាយនានាដែលអនុញ្ញាតដោយច្បាប់នេះ។



https://www.moj.gov.kh/kh/law-regular

**មាត្រា៦ ._** របបកំណត់ពន្ធនិងវិធានគណនេយ្យ

របបកំណត់ពន្ធនិងវិធានគណនេយ្យត្រូវបានកំណត់ដូចខាងក្រោម៖

១_ របបកំណត់ពន្ធនៃព្រះរាជាណាចក្រកម្ពុជាជារបបស្វ័យប្រកាសដែលតម្រូវឱ្យអ្នកជាប់ពន្ធធ្វើការគណនាប្រាក់ពន្ធ និងដាក់លិខិតប្រកាសបង់ប្រាក់ពន្ធដោយខ្លួនឯង។ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវបានចែកជា៣(បី)ប្រភេទ គឺ អ្នកជាប់ពន្ធតូច អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ។

២_ វិធានគណនេយ្យសម្រាប់អ្នកជាប់ពន្ធដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ត្រូវបានកំណត់ដូចខាងក្រោម៖

- ក_ អ្នកជាប់ពន្ធតូចត្រូវប្រើវិធានគណនេយ្យសាមញ្ញ។
- ខ_ អ្នកជាប់ពន្ធមធ្យមនិងអ្នកជាប់ពន្ធធំ ត្រូវប្រើវិធានគណនេយ្យតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។ ប្រាក់ចំណូលត្រូវគិតបញ្ចូលនៅក្នុងឆ្នាំដែលចំណូលនោះបានកើតឡើង ទោះបីជាប្រាក់ចំណូលនោះបានទូទាត់ឬមិនទាន់ទូទាត់ក្តី។ ការកាត់កងចំណាយណាមួយអាចធ្វើទៅបាន លុះណាតែហេតុការណ៍បញ្ជាក់នូវបន្ទុករបស់អ្នកជាប់ពន្ធបានកើតឡើង លទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចដែលជាប់ទាក់ទិនដល់ខ្ទង់ចំណាយនោះបានកើតឡើង និងចំនួនទឹកប្រាក់ដែលជាបន្ទុករបស់អ្នកជាប់ពន្ធអាចបង្ហាញច្បាស់លាស់។

៣_ របបកំណត់ពន្ធនិងវិធានគណនេយ្យត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី២
## ប្រាក់ចំណូលជាប់ពន្ធនិងឆ្នាំជាប់ពន្ធ

**មាត្រា៧ ._** ប្រាក់ចំណូលជាប់ពន្ធ

ប្រាក់ចំណូលជាប់ពន្ធត្រូវបានកំណត់ដូចខាងក្រោម៖

១_ ប្រាក់ចំណូលជាប់ពន្ធ គឺជាប្រាក់ចំណូលសុទ្ធបានមកពីលទ្ធផលទាំងអស់នៃប្រតិបត្តិការអាជីវកម្មគ្រប់ប្រភេទ រួមបញ្ចូលទាំងចំណេញមូលធនដែលសម្រេចបានក្នុងពេលប្រកបអាជីវកម្មឬនៅពេលបញ្ចប់អាជីវកម្ម ការប្រាក់ ថ្លៃឈ្នួល សួយសារ និងសំណងផ្សេងៗ ព្រមទាំងប្រាក់ចំណូលពីទ្រព្យសកម្មហិរញ្ញវត្ថុ ឬទ្រព្យសកម្មវិនិយោគរាប់ទាំងអចលនទ្រព្យ។

២_ ចំពោះនីតិបុគ្គល ប្រាក់ចំណូលជាប់ពន្ធ គឺជាលទ្ធផលដែលកើតចេញពីការធ្វើនិយ័តកម្មលើលទ្ធផលគណនេយ្យក្នុងឆ្នាំជាប់ពន្ធ ស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រាទាំងឡាយនៃជំពូកនេះ។

៣_ ចំពោះរូបវន្តបុគ្គល ប្រាក់ចំណូលជាប់ពន្ធ គឺជាលទ្ធផលដែលបានមកពីការយកចំនួនសរុបនៃប្រាក់ចំណូលក្នុងឆ្នាំជាប់ពន្ធ កាត់កងនឹងចំណាយនិងទាយជ្ជទាននានាដែលកំណត់ដោយអនុក្រឹត្យតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៤_ វិធាននិងនីតិវិធីនៃការកំណត់ប្រាក់ចំណូលជាប់ពន្ធត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



https://www.moj.gov.kh/kh/law-regular

**មាត្រា៨ .-** ឆ្នាំជាប់ពន្ធ

ឆ្នាំជាប់ពន្ធត្រូវបានកំណត់ដូចខាងក្រោម៖

១- ចំពោះនីតិបុគ្គល៖

ក- ពន្ធលើប្រាក់ចំណូល ត្រូវបានគណនាចេញពីលទ្ធផលគណនេយ្យដែលសម្រេចបានក្នុងឆ្នាំប្រតិទិននីមួយៗ។

ខ- ចំពោះសហគ្រាសថ្មីដែលចាប់ផ្តើមអាជីវកម្មក្នុងពេលណាមួយនៃឆ្នាំប្រតិទិន លទ្ធផលគណនេយ្យត្រូវគិតចាប់ពីថ្ងៃដែលចាប់ផ្តើមប្រកបអាជីវកម្មមកទល់នឹងថ្ងៃទី៣១ ខែធ្នូ ឆ្នាំប្រតិទិននោះ។

គ- ប្រសិនបើមានលទ្ធផលគណនេយ្យច្រើនតៗគ្នាក្នុងឆ្នាំប្រតិទិនណាមួយ លទ្ធផលគណនេយ្យទាំងឡាយត្រូវបូកបញ្ចូលគ្នាធ្វើជាមូលដ្ឋានគិតពន្ធលើប្រាក់ចំណូល។

ឃ- សហគ្រាសដែលត្រូវបានគ្រប់គ្រងដោយនីតិបុគ្គលអនិវាសនជន អាចស្នើសុំអនុវត្តឆ្នាំជាប់ពន្ធខុសពីឆ្នាំប្រតិទិន។

ង- ចំពោះសហគ្រាសដែលបញ្ឈប់សកម្មភាពអាជីវកម្ម លទ្ធផលគណនេយ្យចុងក្រោយត្រូវគិត៖

- ចាប់ពីថ្ងៃទី១ ខែមករា រហូតដល់ថ្ងៃបញ្ឈប់សកម្មភាពជាស្ថាពរសម្រាប់សហគ្រាសដែលប្រើប្រាស់ឆ្នាំប្រតិទិនជាឆ្នាំជាប់ពន្ធ
- ចាប់ពីដើមឆ្នាំជាប់ពន្ធចន្លោះរហូតដល់ថ្ងៃបញ្ឈប់សកម្មភាពជាស្ថាពរសម្រាប់សហគ្រាសដែលស្នើសុំអនុវត្តឆ្នាំជាប់ពន្ធខុសពីឆ្នាំប្រតិទិន។

២-ចំពោះរូបវន្តបុគ្គល ពន្ធលើប្រាក់ចំណូលត្រូវបានគណនាចេញពីប្រាក់ចំណូលសរុបដែលសម្រេចបានក្នុងឆ្នាំប្រតិទិននីមួយៗ។

**មាត្រា៩ .-** ប្រាក់ចំណូលលើកលែងពន្ធ

ប្រាក់ចំណូលលើកលែងពន្ធត្រូវបានកំណត់ដូចខាងក្រោម៖

១- វៀរលែងតែមានបទប្បញ្ញត្តិផ្ទុយ ពន្ធលើប្រាក់ចំណូលមិនត្រូវអនុវត្តចំពោះ៖

ក- ប្រាក់ចំណូលរបស់រាជរដ្ឋាភិបាល ឬប្រាក់ចំណូលស្ថាប័នរាជរដ្ឋាភិបាល។

ខ- ប្រាក់ចំណូលរបស់៖

- អង្គការណាមួយដែលត្រូវបានរៀបចំឡើងនិងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬអប់រំ និងគ្មានចំណែកណាមួយនៃទ្រព្យឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជន
- សមាគមណាមួយ ក្នុងករណីដែលប្រាក់ចំណូលរបស់សមាគមនោះមិនត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជនរបស់អ្នកចូលហ៊ុនឬរូបវន្តបុគ្គល។

គ- ភាគលាភដែលបានទទួលមកពីសហគ្រាសនិវាសនជន ក្នុងករណីដែលប្រាក់ពន្ធត្រូវបង់តាមមាត្រា២០ មាត្រា២៣ និងមាត្រា២៦នៃច្បាប់នេះ ត្រូវបានបង់រួចរាល់។

២- ក្នុងករណីប្រាក់ចំណូលដូចមានចែងក្នុងវាក្យខណ្ឌ ខ នៃកថាខណ្ឌទី១នៃមាត្រានេះ ត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជនរបស់អ្នកចូលហ៊ុនឬរូបវន្តបុគ្គល ប្រាក់ចំណូលទាំងនោះត្រូវបានកំណត់ឱ្យជាប់ពន្ធឡើងវិញ។



https://www.moj.gov.kh/kh/law-regular

៣_ ក្នុងករណីអង្គការឬសមាគមដូចមានចែងក្នុងវាក្យខណ្ឌ ខ នៃកថាខណ្ឌទី១នៃមាត្រានេះ មានសកម្មភាពខាងពាណិជ្ជកម្ម ឬឧស្សាហកម្ម ឬអាជីវកម្មផ្សេងទៀតដែលមិនទាក់ទិនដល់គោលដៅឬមុខងារជាមូលដ្ឋាននៃការលើកលែងពន្ធរបស់ខ្លួន ប្រាក់ចំណូលដែលបានមកពីសកម្មភាពមិនទាក់ទិនទាំងនោះត្រូវជាប់ពន្ធតាមមាត្រា២០នៃច្បាប់នេះ។

៤_ វិធាននិងនីតិវិធីនៃការស្នើសុំលើកលែងពន្ធ ភាពបាត់បង់លក្ខណៈលើកលែងពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១០ ._** ការកំណត់ប្រាក់ចំណូលរបស់ក្រុមហ៊ុនសហកម្មសិទ្ធិនិងសម្ព័ន្ធអាជីវកម្ម

១_ ចំពោះក្រុមហ៊ុនសហកម្មសិទ្ធិនិងសម្ព័ន្ធអាជីវកម្ម ក្នុងការកំណត់ប្រាក់ចំណូលរបស់ខ្លួនសម្រាប់ឆ្នាំជាប់ពន្ធណាមួយ សមាជិកម្នាក់ៗត្រូវគិតជាចំដោយឡែកពីគ្នានូវចំណែករៀងៗខ្លួននៅក្នុងខ្ទង់ចំណូល ចំណេញ ខាត ការកាត់កង ឥណទាន និងវិភាគទានសប្បុរសធម៌ក្នុងឆ្នាំនោះ។ សម្រាប់គោលដៅនេះ ខ្ទង់នីមួយៗត្រូវរក្សាចរិតលក្ខណៈនៅដដែល ហើយត្រូវចាត់ទុកថាបានបែងចែកនៅក្នុងឆ្នាំជាប់ពន្ធ ទោះបីជាមានឬគ្មានការបែងចែកជាក់ស្តែងក្តី។ ការខាតបង់ដែលត្រូវយោងទៅឆ្នាំបន្ទាប់នឹងត្រូវកំណត់ឡើងក្រោយពីបានបែងចែកខ្ទង់នានាហើយ។

២_ វិធាននិងនីតិវិធីនៃការកំណត់ប្រាក់ចំណូលរបស់សមាជិកម្នាក់ៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិនិងសម្ព័ន្ធអាជីវកម្មត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៣
## ការកាត់កង

**មាត្រា១១ ._** ការកាត់កងដែលអនុញ្ញាត

ការកាត់កងដែលអនុញ្ញាតត្រូវបានកំណត់ដូចខាងក្រោមៈ

១_ វៀរលែងតែបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា១២ ដល់មាត្រា១៨នៃច្បាប់នេះ ចំណាយដែលអនុញ្ញាតឱ្យកាត់កង រួមមាន ចំណាយសម្រាប់អាជីវកម្មដែលអ្នកជាប់ពន្ធបានទូទាត់ឬត្រូវសងនៅក្នុងឆ្នាំជាប់ពន្ធដើម្បីប្រកបអាជីវកម្ម។

២_ ថ្លៃឈ្នួល ការប្រាក់ ការប៉ះប៉ូវ ការទូទាត់ ឬកម្រៃនានា ដែលបានបើកឱ្យអ្នកទទួលខុសត្រូវ ឬអភិបាលរបស់សហគ្រាស អ្នកចូលហ៊ុន ឬសមាជិករបស់ក្រុមហ៊ុនសហកម្មសិទ្ធិ សមាជិកនៃគ្រួសារអ្នកជាប់ពន្ធ ឬបុគ្គលទាក់ទិនផ្សេងទៀត ក្នុងករណីមានភស្តុតាងបញ្ជាក់ថា ការទូទាត់នោះបានអនុវត្តចំពោះការបំពេញសេវាជាក់ស្តែង ហើយក្នុងកម្រិតសមហេតុសមផល។

៣_ ប្រាក់ដែលបានទូទាត់លើអគារថ្មីឬទ្រព្យសកម្មដទៃទៀត ការកែលម្អជាប់លាប់ឬការកែលម្អនានាក្នុងនោះ មានការប្រាក់និងប្រាក់ពន្ធអាករដែលបានបង់ក្នុងរយៈពេលសាងសង់ឬទិញចូល។ ទឹកប្រាក់នេះត្រូវកត់ត្រាចូលក្នុងគណនីទ្រព្យសកម្មដែលពាក់ព័ន្ធ ហើយត្រូវកាត់កងតាមការរំលស់ដូចមានចែងក្នុងមាត្រា១៣នៃច្បាប់នេះ។

៤_ ចំណាយនានាធ្វើឡើងចំពោះបុគ្គលទាក់ទិននិវាសនជន ដែលមិនស្ថិតក្រោមរបបស្វ័យប្រកាស មិនអនុញ្ញាតឱ្យកាត់កងមុនការទូទាត់ជាក់ស្តែងឡើយ។



https://www.moj.gov.kh/kh/law-regular

៥_ ធនាគារក្នុងស្រុកត្រូវបានអនុញ្ញាតឱ្យធ្វើសំវិធានធនសម្រាប់ឥណទេយ្យជាប់សង្ស័យដើម្បីកំណត់ប្រាក់ចំណូលជាប់ពន្ធ។

៦_ ការកាត់កងចំណាយរបស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលទទួលបានតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

៧_ វិធាននិងនីតិវិធីនៃការកាត់កងនានាត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១២ .-** ចំណាយការប្រាក់

១_ ត្រូវបានអនុញ្ញាតឱ្យកាត់កងនូវចំណាយលើការប្រាក់ដែលអ្នកជាប់ពន្ធបានទូទាត់ឬត្រូវសងនៅក្នុងឆ្នាំជាប់ពន្ធដើម្បីប្រកបអាជីវកម្ម ប៉ុន្តែមិនឱ្យលើសពីផលបូកនៃចំណូលការប្រាក់របស់អ្នកជាប់ពន្ធនិង៥០(ហាសិប)ភាគរយនៃប្រាក់ចំណូលសុទ្ធក្រៅពីការប្រាក់របស់អ្នកជាប់ពន្ធនៅក្នុងឆ្នាំជាប់ពន្ធ។

២_ ចំណូលសុទ្ធក្រៅពីការប្រាក់ គឺជាប្រាក់ចំណូលដុលក្រៅពីចំណូលការប្រាក់ដកខ្ទង់ចំណាយនានាដែលអនុញ្ញាតឱ្យកាត់កង លើកលែងតែចំណាយការប្រាក់។

៣_ វិធាននិងនីតិវិធីនៃការយោងទៅមុខនៃចំណាយការប្រាក់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៣ .-** រំលស់ទ្រព្យរូបី

១_ លក្ខខណ្ឌនៃរំលស់ធម្មតានៃទ្រព្យរូបីមានដូចខាងក្រោម៖

ក_ ក្នុងការកំណត់ប្រាក់ចំណូលជាប់ពន្ធ ការកាត់កងសម្រាប់រំលស់ត្រូវបានផ្តល់ឱ្យម្ចាស់ទ្រព្យរូបីឬអ្នកជួលទ្រព្យរូបីក្នុងករណីដែលអ្នកជួលទទួលខុសត្រូវលើហានិភ័យចំពោះការបាត់បង់ឬការខូតខាតនៃទ្រព្យ ស្របតាមលក្ខខណ្ឌដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ខ_ ទ្រព្យរូបីដែលអាចរំលស់បាន គឺទ្រព្យរូបីប្រើប្រាស់ក្នុងអាជីវកម្មដែលតែងតែបាត់បង់តម្លៃដោយការប្រើប្រាស់ឬភាពហួសសម័យ។ ដីធ្លីមិនមែនជាទ្រព្យអាចរំលស់បានទេ។

គ_ ទ្រព្យរូបីទាំងអស់ត្រូវបានបែងចែកជាថ្នាក់និងវិធីរំលស់ដូចខាងក្រោម៖

ថ្នាក់១ : សំណង់នានា រួមបញ្ចូលទាំងអគារនិងរចនាសម្ព័ន្ធរបស់អគារ សំណង់ដែលជាសមាសភាគរបស់អគារ ផ្លូវថ្នល់ ផ្លូវដែក នាវាដឹកជញ្ជូន ត្រូវធ្វើរំលស់តាមវិធីរំលស់ស្មើភាគ

ថ្នាក់២ : កុំព្យូទ័រ ប្រព័ន្ធព័ត៌មានអេឡិចត្រូនិក ឧបករណ៍អេឡិចត្រូនិក និងបរិក្ខារផ្ទុកទិន្នន័យ ត្រូវធ្វើរំលស់តាមវិធីរំលស់ថយជាលំដាប់

ថ្នាក់៣ : រថយន្ត រថយន្តដឹកទំនិញ គ្រឿងសង្ហារិម និងបរិក្ខារការិយាល័យ ត្រូវធ្វើរំលស់តាមវិធីរំលស់ថយជាលំដាប់

ថ្នាក់៤ : ទ្រព្យសកម្មរូបីដទៃទៀត ត្រូវធ្វើរំលស់តាមវិធីរំលស់ថយជាលំដាប់។

ឃ_ ការកាត់កងសម្រាប់រំលស់នៅក្នុងកថាខណ្ឌនេះ ត្រូវគណនាដោយផ្អែកលើតម្លៃទ្រព្យក្រោយការកាត់កងទឹកប្រាក់រំលស់ពិសេសក្នុងកថាខណ្ឌទី២នៃមាត្រានេះ។


https://www.moj.gov.kh/kh/law-regular

២- លក្ខខណ្ឌនៃរំលស់ពិសេសនៃទ្រព្យរូបីមានដូចខាងក្រោម៖

ក- រំលស់ពិសេសគឺជាចំនួនដែលអាចកាត់កងក្នុងឆ្នាំទី១(មួយ)នៃការទិញ ឬនាពេលក្រោយមកទៀតនៅឆ្នាំទី១(មួយ)នៃការដាក់ប្រើប្រាស់ទ្រព្យរូបីដោយគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដូចមានចែងក្នុងវាក្យខណ្ឌ ខ នៃកថាខណ្ឌនេះ។ ចំនួនដែលអាចកាត់កងបាននេះស្មើនឹង ៤០(សែសិប)ភាគរយនៃតម្លៃមូលធននៃទ្រព្យរូបីថ្មីឬទ្រព្យរូបីប្រើប្រាស់រួចដែលបានដាក់ប្រើប្រាស់ក្នុងផលិតកម្មនិងការកែច្នៃដែលនឹងកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រំលស់ពិសេសនឹងកាត់បន្ថយនូវតម្លៃមូលធននៃទ្រព្យរូបីដែលអាចប្រើប្រាស់សម្រាប់ការរំលស់ធម្មតាតាមកថាខណ្ឌទី១នៃមាត្រានេះ។

ខ- រំលស់ពិសេសនៃទ្រព្យរូបីនឹងត្រូវបានយកមកកាត់កង ដើម្បីកំណត់ប្រាក់ចំណូលជាប់ពន្ធរបស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ឆ្នាំជាប់ពន្ធ ប្រសិនបើអ្នកវិនិយោគមិនជ្រើសយកការប្រើប្រាស់សិទ្ធិទទួលរយៈពេលលើកលែងពន្ធ ដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា២០នៃច្បាប់នេះ។

គ- ទ្រព្យរូបីដែលបានទទួលនូវការកាត់កងរំលស់ពិសេស ត្រូវដាក់ប្រើប្រាស់យ៉ាងតិចបំផុត ៤(បួន)ឆ្នាំជាប់ពន្ធ បន្ទាប់ពីឆ្នាំជាប់ពន្ធដែលរំលស់ពិសេសត្រូវបានកាត់កង។ ប្រសិនបើទ្រព្យរូបីនោះត្រូវបានឈប់ប្រើប្រាស់មុនរយៈពេលនេះ គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ត្រូវកត់ត្រាបញ្ចូលក្នុងប្រាក់ចំណូលជាប់ពន្ធវិញនូវចំនួនមួយស្មើនឹងទឹកប្រាក់រំលស់ពិសេសដែលបានកាត់កងកាត់បន្ថយដោយចំនួនមួយស្មើនឹង២(ពីរ)ភាគរយនៃទឹកប្រាក់រំលស់ពិសេសដែលបានកាត់កងសម្រាប់ខែនីមួយៗឬចំណែកនៃខែដែលទ្រព្យនោះត្រូវបានដាក់ឱ្យប្រើប្រាស់។ ចំនួននេះនឹងមិនប៉ះពាល់តម្លៃពិតគណនេយ្យនៃទ្រព្យរូបីសម្រាប់ការកំណត់ផលចំណេញពីមូលធនជាប់ពន្ធតាមមាត្រា៧នៃច្បាប់នេះឡើយ។

៣- វិធាននិងនីតិវិធីនៃការធ្វើរំលស់ទ្រព្យរូបីត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៤ .-** រំលស់ទ្រព្យអរូបី

១- អ្នកជាប់ពន្ធត្រូវធ្វើរំលស់ទ្រព្យអរូបី ដែលមានជាអាទិ៍ប្រកាសនីយបត្រតក្កកម្ម សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល គំនូរឧស្សាហកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ម៉ាកឬពាណិជ្ជនាម សិទ្ធិអាជីវកម្មដែលមានអាយុកាលមានកំណត់ និងទ្រព្យសកម្មរយៈពេលវែងផ្សេងៗទៀត ត្រូវធ្វើវិធីរំលស់ស្មើភាគទៅតាមអាយុកាលរបស់ទ្រព្យនីមួយៗ។ ប្រសិនបើអាយុកាលនៃទ្រព្យអរូបីមិនអាចកំណត់បាន រំលស់ប្រចាំឆ្នាំត្រូវអនុវត្តតាមវិធីរំលស់ស្មើភាគក្នុងរយៈពេល១០(ដប់)ឆ្នាំ។

២- វិធាននិងនីតិវិធីនៃការធ្វើរំលស់ទ្រព្យអរូបីត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។


https://www.moj.gov.kh/kh/law-regular

**មាត្រា១៥ .-** វិលស់កសិកម្មនិងធនធានធម្មជាតិ

វិលស់កសិកម្មនិងធនធានធម្មជាតិត្រូវបានកំណត់ដូចខាងក្រោម៖

១- កសិកម្មរយៈពេលវែង(ទ្រព្យសកម្មជីវសាស្ត្រ) ត្រូវប្រើវិធីរំលស់ស្មើភាគ៖

ក- ដំណាំកសិកម្ម : ត្រូវកត់ត្រាបង្គរទៅក្នុងគណនីទ្រព្យសកម្មជីវសាស្ត្រនូវចំណាយនានាក្នុងការអភិវឌ្ឍ ចំណាយពាក់ព័ន្ធផ្ទាល់ជាមួយការដាំដុះ រួមទាំងចំណាយការប្រាក់ទាក់ទិននឹងការអភិវឌ្ឍនិងការដាំដុះ និងចំណាយរៀបចំហេដ្ឋារចនាសម្ព័ន្ធដែលបម្រើឱ្យការដាំដុះ។

ខ- ការចិញ្ចឹមសត្វ : ត្រូវកត់ត្រាបង្គរទៅក្នុងគណនីទ្រព្យសកម្មជីវសាស្ត្រនូវចំណាយនានាក្នុងការអភិវឌ្ឍ ចំណាយពាក់ព័ន្ធផ្ទាល់ជាមួយនឹងការចិញ្ចឹមសត្វ រួមទាំងចំណាយការប្រាក់ទាក់ទិននឹងការអភិវឌ្ឍនិងការចិញ្ចឹមសត្វ និងចំណាយរៀបចំហេដ្ឋារចនាសម្ព័ន្ធដែលបម្រើឱ្យការចិញ្ចឹមសត្វ។

២- រំលស់ធនធានធម្មជាតិត្រូវបានកំណត់ដូចខាងក្រោម៖

ក- ត្រូវកត់ត្រាបង្គរទៅក្នុងគណនីទ្រព្យសកម្មនូវចំណាយនានាក្នុងការរុករកនិងអភិវឌ្ឍន៍ ក្នុងនោះមានទាំងការប្រាក់ដែលជាប់ទាក់ទិននឹងចំណាយនោះផង។

ខ- ទឹកប្រាក់រំលស់លើធនធានធម្មជាតិក្រៅពីរ៉ែនិងប្រេងកាត ដែលត្រូវអនុញ្ញាតឱ្យកាត់កងនៅក្នុងឆ្នាំជាប់ពន្ធណាមួយ ត្រូវគណនាដោយយកសមតុល្យនៃគណនីធនធានធម្មជាតិទៅគុណនឹងផលចែករវាងបរិមាណដែលបានផលិតចេញអំពីធនធានធម្មជាតិនៅក្នុងឆ្នាំ និងចំនួនប៉ាន់ស្មាននៃផលិតផលសរុបដែលអាចទាញយកបានពីធនធាននោះ។ នីតិវិធីនៃការកំណត់ចំនួនប៉ាន់ស្មាននៃផលិតផលសរុបត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៦ .-** វិភាគទានសប្បុរសធម៌

១- ត្រូវបានអនុញ្ញាតឱ្យកាត់កងនូវវិភាគទានសប្បុរសធម៌ដែលបានបរិច្ចាគឱ្យអង្គការនានា ដូចមានចែងក្នុងមាត្រា៩នៃច្បាប់នេះ ប៉ុន្តែមិនត្រូវឱ្យលើសពី៥(ប្រាំ)ភាគរយនៃប្រាក់ចំណូលជាប់ពន្ធមុនពេលកាត់កងវិភាគទានសប្បុរសធម៌ទាំងនោះឡើយ។

២- លក្ខណវិនិច្ឆ័យនៃវិភាគទានសប្បុរសធម៌ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៧ .-** ការយោងការខាតបង់ទៅមុខ

ក្នុងករណីដែលមានការខាតបង់នៅក្នុងឆ្នាំជាប់ពន្ធណាមួយ ការខាតបង់នោះត្រូវចាត់ជាបន្ទុកសម្រាប់ឆ្នាំជាប់ពន្ធបន្ទាប់ ហើយត្រូវកាត់កងពីប្រាក់ចំណូលសម្រេចបាននៅក្នុងឆ្នាំជាប់ពន្ធបន្ទាប់នោះ។ បើប្រាក់ចំណូលនោះមិនគ្រប់គ្រាន់សម្រាប់កាត់កងជាស្ថាពរទេ ចំណែកនៃការខាតបង់ដែលនៅសេសសល់ត្រូវយោងទៅកាត់កងនៅឆ្នាំជាប់ពន្ធបន្តបន្ទាប់រហូតដល់ឆ្នាំជាប់ពន្ធទី៥(ប្រាំ)។ នៅពេលណាដែលការខាតបង់កើតឡើងលើសពី១(មួយ)ឆ្នាំ មាត្រានេះត្រូវអនុវត្តចំពោះការខាតបង់ទាំងឡាយតាមលំដាប់ដែលការខាតបង់បានកើតឡើង

**មាត្រា១៨ .-** ការបែងចែកប្រាក់ចំណូលនិងការកាត់កងក្នុងចំណោមអ្នកជាប់ពន្ធ

១- ក្នុងករណីសហគ្រាសចាប់ពី២(ពីរ)ឡើងទៅ ទោះបីជាបានបង្កើតឬរៀបចំឡើងនៅក្នុងឬក្រៅព្រះរាជាណាចក្រកម្ពុជា ហើយដែលស្ថិតក្រោមកម្មសិទ្ធិរួមគ្នា ក្នុងករណីចាំបាច់ រដ្ឋបាលសារពើពន្ធអាចធ្វើការបែងចែកប្រាក់ចំណូលដុល ប្រាក់កាត់កង ឬអត្ថប្រយោជន៍ផ្សេងៗក្នុងចំណោមបុគ្គលទាក់ទិន ដើម្បីទប់ស្កាត់ការគេចវេសពន្ធឬគេចវេះពន្ធ ឬដើម្បីឆ្លុះបញ្ចាំងឱ្យបានច្បាស់លាស់នូវប្រាក់ចំណូលក្នុងចំណោមបុគ្គលទាក់ទិននោះ។

២- សម្រាប់គោលដៅនៃមាត្រានេះ៖

ក- សហគ្រាសចាប់ពី២(ពីរ)ឡើងទៅ ត្រូវស្ថិតក្រោមកម្មសិទ្ធិរួមគ្នា ប្រសិនបើមានបុគ្គលណាម្នាក់មានកម្មសិទ្ធិចាប់ពី២០(ម្ភៃ)ភាគរយឡើងទៅលើតម្លៃឬភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់សហគ្រាសនីមួយៗ។

ខ- ការបែងចែកប្រាក់ចំណូលទៅឱ្យគ្រឹះស្ថានអចិន្ត្រៃយ៍របស់អ្នកជាប់ពន្ធអនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវរាប់បញ្ចូលផងដែរនូវចំណូលពីការផ្គត់ផ្គង់ទំនិញឬសេវាដូចគ្នា ឬប្រហាក់ប្រហែលនឹងសកម្មភាពអាជីវកម្មរបស់គ្រឹះស្ថានអចិន្ត្រៃយ៍ដែលអ្នកជាប់ពន្ធអនិវាសនជនបានផ្គត់ផ្គង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៣- វិធាននិងនីតិវិធីនៃការបែងចែកប្រាក់ចំណូលនិងការកាត់កងក្នុងចំណោមអ្នកជាប់ពន្ធត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៩ .-** ការកាត់កងដែលមិនអនុញ្ញាត

សម្រាប់គោលដៅនៃបទប្បញ្ញត្តិស្ដីពីពន្ធលើប្រាក់ចំណូល ចំណាយដែលមិនអនុញ្ញាតឱ្យកាត់កងមានដូចខាងក្រោម៖

១- ចំណាយលើសកម្មភាពទាំងឡាយដែលជាទូទៅចាត់ទុកជាការកម្សាន្ត ការសម្រាកលំហែ ការទទួលភ្ញៀវ ឬការប្រើប្រាស់មធ្យោបាយណាមួយដែលទាក់ទិននឹងសកម្មភាពទាំងនេះ។

២- ចំណាយសម្រាប់ការរស់នៅផ្ទាល់ខ្លួនឬក្រុមគ្រួសារ លើកលែងតែអត្ថប្រយោជន៍បន្ថែមជាប្រាក់ឬជាវត្ថុដែលប្រាក់ពន្ធត្រូវបានកាត់ទុកតាមបទប្បញ្ញត្តិស្ដីពីពន្ធលើប្រាក់បៀវត្ស។

៣- ប្រាក់ពន្ធដែលបទប្បញ្ញត្តិស្ដីពីពន្ធលើប្រាក់ចំណូលបានកំណត់ និងពន្ធកាត់ទុកដែលបទប្បញ្ញត្តិស្ដីពីពន្ធលើប្រាក់បៀវត្សបានកំណត់។

៤- ការខាតបង់លើការលក់ឬដោះដូរទ្រព្យសម្បត្តិ ទោះបីដោយផ្ទាល់ឬប្រយោលក្ដីរវាងបុគ្គលទាក់ទិន។

៥- ចំណាយនានា វៀរលែងតែចំណាយដែលកើតមានឡើង ហើយអ្នកជាប់ពន្ធអាចបញ្ជាក់ច្បាស់លាស់នូវចំនួនទឹកប្រាក់និងគោលដៅអាជីវកម្ម។

## ផ្នែកទី៤
## អត្រាពន្ធនិងប្រាក់ពន្ធត្រូវបង់

**មាត្រា២០ .-** ការកំណត់ប្រាក់ពន្ធត្រូវបង់

[illegible]ពន្ធ[illegible]ប្រាក់ចំណូលប្រចាំឆ្នាំត្រូវបានកំណត់ដូចខាងក្រោម៖

[illegible]២០(ម្ភៃ)ភាគរយ ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយនីតិបុគ្គល។



https://www.moj.gov.kh/kh/law-regular

២- ៣០(សាមសិប)ភាគរយ ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានក្រោមកិច្ចព្រមព្រៀងប្រេងកាត ឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិ រួមទាំងព្រៃឈើ រ៉ែ មាស ឬត្បូងថ្មមានតម្លៃនានា។

៣- ០(សូន្យ)ភាគរយ ចំពោះប្រាក់ចំណូលជាប់ពន្ធរបស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធស្របតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

៤- ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយរូបវន្តបុគ្គល សហគ្រាសឯកបុគ្គល និងចំណែកដែលត្រូវបែងចែកឱ្យសមាជិកម្នាក់ៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ ដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គល ត្រូវជាប់ពន្ធលើប្រាក់ចំណូលតាមអត្រាកំណើនតាមថ្នាក់ដែលត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២១ .-** ពន្ធលើប្រាក់ចំណូលសម្រាប់សហគ្រាសធានារ៉ាប់រង

ពន្ធលើប្រាក់ចំណូលសម្រាប់សហគ្រាសធានារ៉ាប់រងត្រូវបានកំណត់ដូចខាងក្រោម៖

១- ចំពោះសកម្មភាពធានារ៉ាប់រងឬធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិឬហានិភ័យផ្សេងៗនៅព្រះរាជាណាចក្រកម្ពុជា ពន្ធលើប្រាក់ចំណូលត្រូវបានកំណត់ស្មើនឹង៥(ប្រាំ)ភាគរយនៃបុព្វលាភធានារ៉ាប់រងដុលដែលទទួលបាននៅក្នុងឆ្នាំជាប់ពន្ធ។

២- ចំពោះសកម្មភាពធានារ៉ាប់រងឬធានារ៉ាប់រងបន្តលើជីវិតដែលមានលក្ខណៈសន្សំ និងសកម្មភាពដទៃទៀតក្រៅពីធានារ៉ាប់រងឬធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិឬហានិភ័យផ្សេងៗដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ពន្ធលើប្រាក់ចំណូលត្រូវបានកំណត់តាមមាត្រា២០នៃច្បាប់នេះ។

៣- វិធាននិងនីតិវិធីនៃការបង់ពន្ធលើប្រាក់ចំណូលសម្រាប់សហគ្រាសធានារ៉ាប់រងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២២ .-** ពន្ធលើប្រាក់ចំណូលសម្រាប់សាខាក្រុមហ៊ុនបរទេស

ពន្ធលើប្រាក់ចំណូលសម្រាប់សាខាក្រុមហ៊ុនបរទេសត្រូវបានកំណត់ដូចខាងក្រោម៖

១- ប្រាក់ចំណូលដែលសម្រេចបានពីប្រភពកម្ពុជា ត្រូវជាប់ពន្ធលើប្រាក់ចំណូលតាមមាត្រា២០នៃច្បាប់នេះ។

២- ប្រសិនបើនៅក្នុងឆ្នាំជាប់ពន្ធចរន្ត សាខាក្រុមហ៊ុនបរទេសណាមួយធ្វើការផ្ទេរប្រាក់ចំណូលប្រភពកម្ពុជាទៅក្រៅប្រទេស ប្រាក់ចំណូលនោះ៖

ក- មិនត្រូវជាប់ពន្ធបង់មុនលើការបែងចែកភាគលាភតាមមាត្រា២៣នៃច្បាប់នេះទេ ប្រសិនបើប្រាក់ចំណូលដែលផ្ទេរនោះជាប្រាក់ចំណូលក្រោយការបង់ពន្ធលើប្រាក់ចំណូលតាមកថាខណ្ឌទី១ឬកថាខណ្ឌទី២នៃមាត្រា២០នៃច្បាប់នេះ។

ខ- ត្រូវជាប់ពន្ធបង់មុនលើការបែងចែកភាគលាភតាមមាត្រា២៣នៃច្បាប់នេះ ប្រសិនបើប្រាក់ចំណូលដែលផ្ទេរនោះជាប្រាក់ចំណូលដែលមិនបានបង់ពន្ធលើប្រាក់ចំណូល តាមកថាខណ្ឌទី១ឬកថាខណ្ឌទី២នៃមាត្រា២០នៃច្បាប់នេះ និង

ត្រូវជាប់ពន្ធកាត់ទុកតាមមាត្រា២៦នៃច្បាប់នេះ លើប្រាក់ចំណូល ដូចមានចែងក្នុងកថាខណ្ឌទី១០នៃមាត្រា៣៣នៃច្បាប់នេះ។

៣- វិធាននិងនីតិវិធីនៃការប្រមូលប្រាក់ពន្ធលើប្រាក់ចំណូលសម្រាប់សាខាក្រុមហ៊ុនបរទេសត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



https://www.moj.gov.kh/kh/law-regular

**មាត្រា២៣ .-** ពន្ធបង់មុនលើការបែងចែកភាគលាភ

ពន្ធបង់មុនលើការបែងចែកភាគលាភត្រូវបានកំណត់ដូចខាងក្រោម៖

១_ វៀរលែងតែគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលស្ថិតក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល ប្រសិនបើសហគ្រាសណាមួយបែងចែកភាគលាភចេញពីប្រាក់ចំណូលមុនបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំទៅឱ្យអ្នកចូលហ៊ុនក្នុងស្រុកឬអ្នកចូលហ៊ុនបរទេស សហគ្រាសនោះត្រូវបង់ប្រាក់ពន្ធដែលមានចំនួនស្មើនឹងផលគុណនៃទឹកប្រាក់ភាគលាភបំប៉ោងទៅតាមអត្រាពន្ធលើប្រាក់ចំណូលគុណនឹងអត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំដូចមានចែងក្នុងមាត្រា២០នៃច្បាប់នេះ។

២_ ប្រាក់ពន្ធដែលបានបង់តាមកថាខណ្ឌទី១នៃមាត្រានេះ ត្រូវបានអនុញ្ញាតជាឥណទានពន្ធសម្រាប់កាត់កងនឹងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំជាប់ពន្ធដែលមានការបែងចែក។ ប្រសិនបើឥណទានពន្ធមានចំនួនលើសពីប្រាក់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ចំនួនលើសនោះត្រូវបានអនុញ្ញាតឱ្យយោងទៅមុខសម្រាប់កាត់កងនឹងពន្ធលើប្រាក់ចំណូលនៃឆ្នាំជាប់ពន្ធបន្តបន្ទាប់។

៣_ ភាគលាភដែលបានបង់ពន្ធតាមកថាខណ្ឌទី១នៃមាត្រានេះ នៅពេលបែងចែកបន្ត មិនត្រូវជាប់ពន្ធបង់មុនលើការបែងចែកភាគលាភដូចមានចែងក្នុងមាត្រានេះទៀតទេ។

៤_ ពន្ធបង់មុនលើការបែងចែកភាគលាភដូចមានចែងក្នុងមាត្រានេះ មិនអនុវត្តទេចំពោះប្រាក់ចំណូលពីបុព្វលាភធានារ៉ាប់រងឬធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិឬហានិភ័យផ្សេងៗនៅព្រះរាជាណាចក្រកម្ពុជាដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រា២១នៃច្បាប់នេះ។

៥_ វិធាននិងនីតិវិធីនៃការប្រមូលប្រាក់ពន្ធបង់មុនលើការបែងចែកភាគលាភត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៥

## ពន្ធអប្បបរមា

**មាត្រា២៤ .-** ពន្ធអប្បបរមា

១_ ពន្ធអប្បបរមាត្រូវបានកំណត់តាមអត្រា១(មួយ)ភាគរយលើផលរបរប្រចាំឆ្នាំ រួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម ហើយត្រូវបង់នៅពេលទូទាត់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។ ពន្ធអប្បបរមាអាចត្រូវបានកាត់បន្ថយដោយពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំដែលបានបង់ជាក់ស្តែងតាមវិធានដូចមានចែងក្នុងមាត្រា៣៧ មាត្រា៣៨ និងមាត្រា៣៩នៃច្បាប់នេះ។ ពន្ធអប្បបរមាត្រូវបានកំណត់លើសហគ្រាសទាំងឡាយណាដែលមិនកាន់បញ្ជិកាគណនេយ្យបានត្រឹមត្រូវ។ គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ត្រូវទទួលបានការលើកលែងពន្ធអប្បបរមា ដោយត្រូវមានរបាយការណ៍សវនកម្មឯករាជ្យ។

២_ វិធាននិងនីតិវិធីនៃលក្ខណវិនិច្ឆ័យនៃការកាន់បញ្ជិកាគណនេយ្យមិនត្រឹមត្រូវ និងការបង់ពន្ធអប្បបរមាត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



https://www.moj.gov.kh/kh/law-regular

# ផ្នែកទី៦
# ពន្ធកាត់ទុកនិងប្រាក់រំដោះពន្ធលើប្រាក់ចំណូល

**មាត្រា២៥ .-** ពន្ធកាត់ទុកទូទៅ

ពន្ធកាត់ទុកទូទៅត្រូវបានកំណត់ដូចខាងក្រោម៖

១- អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្មដែលបានធ្វើការទូទាត់ជាសាច់ប្រាក់ឬជាវត្ថុឱ្យអ្នកជាប់ពន្ធនិវាសនជន ត្រូវកាត់ទុកនិងបង់ប្រាក់ពន្ធទៅតាមអត្រាកំណត់ដូចខាងក្រោម លើចំនួនទូទាត់មុនការកាត់ទុកប្រាក់ពន្ធ៖

ក- អត្រា១៥(ដប់ប្រាំ)ភាគរយ ចំពោះ៖

- ប្រាក់ចំណូលដែលបុគ្គលមិនស្ថិតក្រោមរបបស្វ័យប្រកាសបានទទួលពីការបំពេញសេវានានា រួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ ឬសេវាប្រហាក់ប្រហែល
- សួយសារចំពោះទ្រព្យអរូបី និងភាគកម្មក្នុងធនធានរ៉ែ និងការប្រាក់ដែលអ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្មក្រៅពីធនាគារក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជន។

ខ- អត្រា១០(ដប់)ភាគរយ ចំពោះប្រាក់ចំណូលពីការឱ្យជួលចលនទ្រព្យឬអចលនទ្រព្យ។

គ- អត្រា៦(ប្រាំមួយ)ភាគរយ ចំពោះការប្រាក់ដែលធនាគារក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជនដែលមានគណនីបញ្ញើមានកាលកំណត់។

ឃ- អត្រា៤(បួន)ភាគរយ ចំពោះការប្រាក់ដែលធនាគារក្នុងស្រុកបង់ឱ្យទៅអ្នកជាប់ពន្ធនិវាសនជនដែលមានគណនីបញ្ញើគ្មានកាលកំណត់។

២- ការកាត់ទុកក្នុងមាត្រានេះមិនត្រូវអនុវត្តទេ ចំពោះការប្រាក់ដែលបង់ទៅឱ្យធនាគារក្នុងស្រុក និងការទូទាត់ចំពោះប្រាក់ចំណូលលើកលែងពន្ធដូចមានចែងក្នុងមាត្រា៩នៃច្បាប់នេះ។

**មាត្រា២៦ .-** ពន្ធកាត់ទុកលើការទូទាត់ប្រាក់ឱ្យដល់អ្នកជាប់ពន្ធអនិវាសនជន

អ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម រួមទាំងគ្រឹះស្ថានអចិន្ត្រៃយ៍របស់បុគ្គលអនិវាសនជនដែលធ្វើការទូទាត់ប្រាក់ចំណូលប្រភពកម្ពុជា ដូចមានចែងក្នុងមាត្រា៣៣នៃច្បាប់នេះ ឱ្យទៅអ្នកជាប់ពន្ធអនិវាសនជន ត្រូវកាត់ទុកនិងបង់នូវប្រាក់ពន្ធតាមអត្រា១៤(ដប់បួន)ភាគរយនៃទឹកប្រាក់ត្រូវបើក។ ពន្ធកាត់ទុកនេះ មិនត្រូវអនុវត្តចំពោះបុព្វលាភធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិឬហានិភ័យផ្សេងៗនៅព្រះរាជាណាចក្រកម្ពុជានោះទេ។

**មាត្រា២៧ .-** ពន្ធកាត់ទុកជាពន្ធចុងក្រោយ

ពន្ធកាត់ទុកលើការទូទាត់ឱ្យដល់បុគ្គលនិវាសនជនមិនស្ថិតក្រោមរបបស្វ័យប្រកាសតាមមាត្រា២៥នៃច្បាប់នេះ និងពន្ធកាត់ទុកលើការទូទាត់ឱ្យដល់អ្នកជាប់ពន្ធអនិវាសនជនតាមមាត្រា២៦នៃច្បាប់នេះ ត្រូវចាត់ទុកជាពន្ធចុងក្រោយសម្រាប់អ្នកទទួលការទូទាត់ឬការបែងចែកដែលមានបញ្ជាក់ក្នុងមាត្រាទាំងឡាយនៃច្បាប់នេះ។



https://www.moj.gov.kh/kh/law-regular

**មាត្រា២៨ .-** ប្រាក់រំដោះពន្ធលើប្រាក់ចំណូល

សហគ្រាសដែលជាប់ពន្ធលើប្រាក់ចំណូលតាមរបបស្វ័យប្រកាស រួមទាំងគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលផុតរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល មានកាតព្វកិច្ចបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំខែតាមអត្រា១(មួយ)ភាគរយនៃផលរបរ រួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែមដែលសម្រេចបានក្នុងខែមុន។ ប្រាក់រំដោះពន្ធលើប្រាក់ចំណូលនឹងត្រូវបានយកមកកាត់កងពីពន្ធលើប្រាក់ចំណូលនៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ។

## ផ្នែកទី៧
## កាតព្វកិច្ចរបស់អ្នកជាប់ពន្ធ

**មាត្រា២៩ .-** កាតព្វកិច្ចរបស់អ្នកជាប់ពន្ធមធ្យមនិងអ្នកជាប់ពន្ធធំ

អ្នកជាប់ពន្ធមធ្យមនិងអ្នកជាប់ពន្ធធំត្រូវមានកាតព្វកិច្ចដូចខាងក្រោម៖

១- អនុវត្តកាតព្វកិច្ចបញ្ជិកាគណនេយ្យដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រា៦នៃច្បាប់នេះ និងត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំជូនរដ្ឋបាលសារពើពន្ធតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់ក្នុងរយៈពេល៣(បី)ខែ ក្រោយពីដំណាច់ឆ្នាំជាប់ពន្ធនីមួយៗ ដោយភ្ជាប់ជាមួយនូវតារាងតុល្យការគណនីលទ្ធផល និងព័ត៌មានបន្ថែម។

២- ចំពោះសហគ្រាសដែលមានការខាតបង់ ក៏ត្រូវដាក់លិខិតប្រកាសសារពើពន្ធតាមបែបបទនិងក្នុងរយៈពេលដូចគ្នាដែរ។

**មាត្រា៣០ .-** កាតព្វកិច្ចរបស់អ្នកជាប់ពន្ធតូច

អ្នកជាប់ពន្ធតូចមានកាតព្វកិច្ចដូចខាងក្រោម៖

១- ត្រូវដាក់លិខិតប្រកាសនិងបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ជូនរដ្ឋបាលសារពើពន្ធជារៀងរាល់ឆ្នាំក្នុងរយៈពេល៣(បី)ខែ ក្រោយដំណាច់ឆ្នាំប្រតិទិននីមួយៗតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់។

២- ក្នុងករណីមិនបានកាន់កត់ត្រាបញ្ជីចំណូលចំណាយតាមការកំណត់របស់រដ្ឋបាលសារពើពន្ធ ចំនួនប្រាក់ចំណូលជាប់ពន្ធត្រូវកំណត់ដោយរដ្ឋបាលសារពើពន្ធ បន្ទាប់ពីបានត្រួតពិនិត្យនិងគណនាតាមអត្រាចំណូលទៅតាមមុខរបរអាជីវកម្ម ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣១ .-** កាតព្វកិច្ចរបស់ភ្នាក់ងារកាត់ទុក

១- បុគ្គលឬអ្នកទទួលភារៈបើកប្រាក់ដែលកាត់ទុកប្រាក់ពន្ធតាមមាត្រា២៥និងមាត្រា២៦នៃច្បាប់នេះត្រូវដាក់លិខិតប្រកាសសារពើពន្ធនិងបង់ប្រាក់ពន្ធដែលបានកាត់ទុកជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ពីខែដែលបានធ្វើការទូទាត់។

២- សហគ្រាសត្រូវដាក់លិខិតប្រកាសពន្ធបង់មុនលើការបែងចែកភាគលាភ ដូចមានចែងក្នុងមាត្រា[illegible]នៃច្បាប់នេះ និងបង់ពន្ធជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ពីខែដែលការបែងចែកត្រូវបានទូទាត់។



https://www.moj.gov.kh/kh/law-regular

**មាត្រា៣២ ._** កាតព្វកិច្ចបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល

អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធនិងបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលជូនរដ្ឋបាលសារពើពន្ធជារៀងរាល់ខែ តាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ពីខែដែលប្រតិបត្តិការអាជីវកម្មបានកើតឡើង។

## ផ្នែកទី៨
## ប្រភពប្រាក់ចំណូល

**មាត្រា៣៣ ._** ប្រាក់ចំណូលប្រភពកម្ពុជា

ដោយមិនមានការកម្រិតត្រឹមតែប្រាក់ចំណូលដូចខាងក្រោមនេះ ប្រាក់ចំណូលប្រភពកម្ពុជារួមមាន៖

១_ ការប្រាក់ដែលបង់ដោយសហគ្រាសនិវាសនជន ក្រុមហ៊ុនសហកម្មសិទ្ធិនិវាសនជន ឬស្ថាប័នរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

២_ ភាគលាភដែលបានបែងចែកដោយសហគ្រាសនិវាសនជន។

៣_ ប្រាក់ចំណូលពីសេវាកម្មដែលបានបំពេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៤_ ប្រាក់ចំណូលពីការគ្រប់គ្រងនិងសេវាបច្ចេកទេស ដែលបានទូទាត់ដោយបុគ្គលនិវាសនជន។

៥_ ប្រាក់ចំណូលដែលបានមកពីចលនទ្រព្យឬអចលនទ្រព្យក្នុងករណីដែលទ្រព្យនោះស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៦_ ប្រាក់សួយសារដែលបានមកពីការប្រើប្រាស់ឬសិទ្ធិប្រើប្រាស់ទ្រព្យអរូបីដែលបានទូទាត់ដោយអ្នកជាប់ពន្ធនិវាសនជនឬអ្នកជាប់ពន្ធអនិវាសនជនតាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ដែលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៧_ ផលចំណេញពីការលក់ចលនទ្រព្យ ឬអចលនទ្រព្យ រួមទាំងទ្រព្យអរូបី ដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬផលចំណេញពីការផ្ទេរផលប្រយោជន៍ណាមួយនៃចលនទ្រព្យឬអចលនទ្រព្យរួមទាំង ទ្រព្យអរូបី ដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៨_ បុព្វលាភធានារ៉ាប់រងឬធានារ៉ាប់រងបន្តចំពោះហានិភ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៩_ ផលចំណេញពីការលក់ចលនទ្រព្យដែលជាចំណែកនៃទ្រព្យអាជីវកម្មរបស់គ្រឹះស្ថានអចិន្ត្រៃយ៍របស់អ្នកជាប់ពន្ធអនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

១០_ ប្រាក់ចំណូលពីសកម្មភាពអាជីវកម្មរបស់អ្នកជាប់ពន្ធអនិវាសនជន តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣៤ ._** ប្រាក់ចំណូលប្រភពបរទេស

រាល់ប្រាក់ចំណូលដែលមិនមែនជាប្រាក់ចំណូលប្រភពកម្ពុជាដូចមានចែងក្នុងមាត្រា៣៣នៃច្បាប់នេះត្រូវចាត់ទុកជាប្រាក់ចំណូលប្រភពបរទេស។

**មាត្រា៣៥ ._** ការកំណត់ប្រភពចំណូល

ក្នុងករណីដែលគ្មានព័ត៌មានគ្រប់គ្រាន់ដើម្បីកំណត់ប្រភពចំណូល ឬប្រសិនបើវិធាននានាដែលបានចែងមកហើយពុំអាចឆ្លុះបញ្ចាំងឱ្យបានច្បាស់លាស់នូវប្រាក់ចំណូលពីប្រភពណាមួយបានទេនោះ រដ្ឋបាលសារពើពន្ធជាអ្នកកំណត់ប្រភពនៃប្រាក់ចំណូលនោះ។



https://www.moj.gov.kh/kh/law-regular

## ផ្នែកទី៩
## គណនាប្រាក់ពន្ធប្រចាំឆ្នាំត្រូវបង់

**មាត្រា៣៦ ._** ឥណទានពន្ធបរទេស

១_ អ្នកជាប់ពន្ធនិវាសនជនដែលបានទទួលប្រាក់ចំណូលប្រភពបរទេសនិងបានបង់ពន្ធតាមច្បាប់ពន្ធដារបរទេស ត្រូវបានទទួលនូវឥណទានពន្ធសម្រាប់កាត់កងពីប្រាក់ពន្ធលើប្រាក់ចំណូលដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែត្រូវមានឯកសារបញ្ជាក់អំពីការបង់ពន្ធនៅបរទេសនោះ។

២_ដើម្បីគណនាប្រាក់ពន្ធដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជាមុនពេលកាត់កងឥណទានពន្ធនេះ ត្រូវយកចំនួនសរុបនៃប្រាក់ចំណូលដែលបានទទួលពីប្រភពកម្ពុជានិងប្រភពបរទេសមកគិត។

៣_ ឥណទានពន្ធត្រូវបានកំណត់ដាច់ដោយឡែកពីគ្នាសម្រាប់ប្រាក់ពន្ធដែលបានបង់ដោយនិវាសនជនកម្ពុជានៅប្រទេសក្រៅនីមួយៗ។ ប៉ុន្តែឥណទានពន្ធដែលអនុញ្ញាតឱ្យកាត់កងសម្រាប់ឆ្នាំជាប់ពន្ធគឺចំនួនដែលទាបជាងគេក្នុងចំណោម៖

ក_ ប្រាក់ពន្ធដែលបានបង់ជាក់ស្តែងនៅប្រទេសក្រៅណាមួយ។

ខ_ ចំនួនដែលបានមកពីការយកប្រាក់ពន្ធលើប្រាក់ចំណូលសរុបពីគ្រប់ប្រភព សម្រាប់រយៈពេលជាមួយគ្នាដែលគណនាតាមអត្រាពន្ធក្នុងមាត្រា២០នៃច្បាប់នេះ ទៅគុណនឹងផលចែករវាងប្រាក់ចំណូលដែលបានទទួលនៅប្រទេសក្រៅនោះ និងប្រាក់ចំណូលសរុបពីគ្រប់ប្រភព។

៤_ ឥណទានពន្ធបរទេសអាចផ្តល់ឱ្យបាន លុះណាតែអ្នកជាប់ពន្ធនិវាសនជនបានបំពេញបែបបទព្រមទាំងផ្តល់ឯកសារនានាដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ ជាពិសេសសេចក្តីបញ្ជាក់របស់អ្នកទូទាត់ប្រាក់ពន្ធនៅបរទេសដោយរដ្ឋបាលសារពើពន្ធបរទេសនោះ។

៥_ ក្នុងករណីឥណទានពន្ធមានចំនួនលើសពីបំណុលពន្ធ ចំនួនលើសនោះអាចយោងទៅប្រើនៅឆ្នាំបន្តបន្ទាប់រហូតដល់ឆ្នាំទី៥(ប្រាំ)គិតពីឆ្នាំបន្ទាប់នៃឆ្នាំដែលឥណទានពន្ធនោះបានកើតឡើង។ ប្រសិនបើមានឥណទានពន្ធច្រើនឆ្នាំ ត្រូវយកឥណទានពន្ធទាំងនោះមកប្រើតាមលំដាប់ឆ្នាំដែលបានកើតឡើង។

**មាត្រា៣៧ ._** ការគណនាបំណុលពន្ធលើប្រាក់ចំណូល

ការគណនាបំណុលពន្ធលើប្រាក់ចំណូលត្រូវបានកំណត់ដូចខាងក្រោម៖

១_ គណនាបំណុលពន្ធសរុបតាមមាត្រា២០នៃច្បាប់នេះ។

២_ ដកឥណទានពន្ធដែលបានបង់តាមមាត្រា២៣ និងឥណទានពន្ធបរទេសតាមមាត្រា៣៦នៃច្បាប់នេះ ប៉ុន្តែមិនឱ្យលើសបំណុលពន្ធក្នុងកថាខណ្ឌទី១នៃមាត្រានេះទេ។

**មាត្រា៣៨ ._** ការគណនាប្រាក់ពន្ធត្រូវបង់ឬឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធ

ការគណនាប្រាក់ពន្ធត្រូវបង់ឬឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធត្រូវបានកំណត់ដូចខាងក្រោម៖

១_ ក្នុងករណីដែលលទ្ធផលគណនាតាមមាត្រា៣៧នៃច្បាប់នេះ មានចំនួនច្រើនជាងផលបូកនៃចំនួនប្រាក់ពន្ធដែលបានកាត់ទុកក្នុងនាមអ្នកជាប់ពន្ធដោយភ្នាក់ងារកាត់ទុកនានាតាមមាត្រា២៥នៃច្បាប់នេះ និងប្រាក់រំដោះពន្ធលើប្រាក់ចំណូលដែលអ្នកជាប់ពន្ធបានបង់ប្រចាំឆ្នាំតាមមាត្រា២៨នៃច្បាប់នេះ អ្នកជាប់ពន្ធត្រូវបង់បន្ថែមចំនួនដែលលម្អៀងនោះជូនរដ្ឋបាលសារពើពន្ធ។



https://www.moj.gov.kh/kh/law-regular

២- ប្រសិនបើលទ្ធផលគណនាតាមមាត្រា៣៧នៃច្បាប់នេះ មានចំនួនតិចជាងផលបូកនៃចំនួនប្រាក់ពន្ធដែលបានកាត់ទុកក្នុងនាមអ្នកជាប់ពន្ធដោយភ្នាក់ងារកាត់ទុកនានាតាមមាត្រា២៥នៃច្បាប់នេះ និងចំនួនប្រាក់រំដោះពន្ធលើប្រាក់ចំណូលដែលអ្នកជាប់ពន្ធបានបង់សម្រាប់ឆ្នាំជាប់ពន្ធតាមមាត្រា២៨នៃច្បាប់នេះ ក្រោយពីបានគណនាបំណុលពន្ធអប្បបរមារួចហើយ អ្នកជាប់ពន្ធអាចសុំបង្វិលសងវិញនូវចំនួនដែលលម្អៀង ឬយោងទៅប្រើជាប្រាក់រំដោះសម្រាប់ឆ្នាំបន្ទាប់។

៣- មុននឹងធ្វើការទូទាត់ប្រាក់ពន្ធតាមកថាខណ្ឌទី១នៃមាត្រានេះ ឬក៏សុំបង្វិលសង ឬយោងទៅប្រើជាប្រាក់រំដោះសម្រាប់ឆ្នាំបន្ទាប់តាមកថាខណ្ឌទី២នៃមាត្រានេះ អ្នកជាប់ពន្ធត្រូវតែកំណត់ជាមុននូវបំណុលពន្ធអប្បបរមា តាមនីតិវិធីដូចមានចែងក្នុងមាត្រា៣៩នៃច្បាប់នេះ។

**មាត្រា៣៩ .-** ការគណនាប្រាក់ពន្ធអប្បបរមា ប្រាក់ពន្ធត្រូវបង់ ឬឥណទានសម្រាប់ឆ្នាំជាប់ពន្ធ

ការគណនាប្រាក់ពន្ធអប្បបរមា ប្រាក់ពន្ធត្រូវបង់ ឬឥណទានពន្ធសម្រាប់ឆ្នាំជាប់ពន្ធ ត្រូវបានកំណត់ដូចខាងក្រោម៖

១- អ្នកជាប់ពន្ធត្រូវបង់ពន្ធអប្បបរមានៅពេលធ្វើការទូទាត់ប្រាក់ពន្ធលើប្រាក់ចំណូល។ ពន្ធអប្បបរមាត្រូវបង់អាចត្រូវបានកាត់បន្ថយដោយបំណុលពន្ធលើប្រាក់ចំណូលក្នុងឆ្នាំជាប់ពន្ធជាមួយគ្នាតាមមាត្រា២០នៃច្បាប់នេះ។

២- ក្នុងករណីបំណុលពន្ធលើប្រាក់ចំណូលលើសពីបំណុលពន្ធអប្បបរមា៖

ក- អ្នកជាប់ពន្ធត្រូវទូទាត់ប្រាក់ពន្ធត្រូវបង់តាមមាត្រា៣៧នៃច្បាប់នេះ នៅពេលដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។

ខ- ប្រសិនបើចំនួនទឹកប្រាក់ដែលបានកាត់ទុកតាមមាត្រា២៥និងមាត្រា២៨នៃច្បាប់នេះ មានចំនួនលើសពីបំណុលពន្ធអប្បបរមា អ្នកជាប់ពន្ធអាចស្នើសុំជាឥណទានពន្ធបាន។

គ- ក្នុងករណីដូចក្នុងកថាខណ្ឌទី២នៃមាត្រានេះ អ្នកជាប់ពន្ធមិនជាប់ពន្ធអប្បបរមាទេ។

៣- ប្រសិនបើបំណុលពន្ធលើប្រាក់ចំណូលតិចជាងបំណុលពន្ធអប្បបរមា៖

ក- ឥណទានពន្ធរបស់អ្នកជាប់ពន្ធតាមកថាខណ្ឌទី២នៃមាត្រា៣៨នៃច្បាប់នេះ ត្រូវបានកាត់បន្ថយដោយទឹកប្រាក់លម្អៀងខាងលើ។

ខ- ឥណទានពន្ធដែលបានកាត់បន្ថយក្នុងការអនុវត្តតាមវាក្យខណ្ឌ ក នៃកថាខណ្ឌនេះ ត្រូវចាត់ជាការទូទាត់ប្រាក់ពន្ធអប្បបរមាសម្រាប់ឆ្នាំជាប់ពន្ធ។

# ជំពូកទី៣

# ពន្ធលើប្រាក់បៀវត្ស

## ផ្នែកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា៤០ .-** កម្មវត្ថុនៃពន្ធ

ពន្ធលើប្រាក់បៀវត្ស គឺជាពន្ធប្រចាំខែកំណត់លើប្រាក់បៀវត្សដែលបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបម្រើការងារ។



https://www.moj.gov.kh/kh/law-regular

**មាត្រា៤១ .-** វិសាលភាពនៃពន្ធ

១- រូបវន្តបុគ្គលនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជានិងប្រាក់បៀវត្សប្រភពបរទេស។

២- រូបវន្តបុគ្គលអនិវាសនជន ត្រូវជាប់ពន្ធលើប្រាក់បៀវត្សចំពោះប្រាក់បៀវត្សប្រភពកម្ពុជា។

**មាត្រា៤២ .-** និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងជំពូកនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- និវាសនជន ក្នុងករណីដែលប្រើចំពោះនិយោជិត អ្នកជាប់ពន្ធ ឬរូបវន្តបុគ្គល មានន័យថា ដែលមាននិវាសនដ្ឋានឬមានកន្លែងស្នាក់នៅជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី១៨២(មួយរយប៉ែតសិបពីរ)ថ្ងៃ នៅក្នុងរយៈពេល១២(ដប់ពីរ)ខែណាមួយដែលបានបញ្ចប់ក្នុងឆ្នាំជាប់ពន្ធចរន្ត។

២- អនិវាសនជន មានន័យថា រូបវន្តបុគ្គលណាមួយដែលមិនមែនជានិវាសនជនតាមកថាខណ្ឌទី១នៃមាត្រានេះ និងទទួលប្រាក់បៀវត្សប្រភពកម្ពុជា។

៣- វៀរលែងតែមានបទប្បញ្ញត្តិផ្ទុយ ការប្រើពាក្យ និយោជិត អ្នកជាប់ពន្ធ និងរូបវន្តបុគ្គល សំដៅដល់ទាំងនិវាសនជននិងអនិវាសនជន ដូចមានចែងក្នុងមាត្រានេះ។

៤- និយោជក រួមមានស្ថាប័នរដ្ឋ នីតិបុគ្គលនិវាសនជន ក្រុមហ៊ុនសហកម្មសិទ្ធិនិវាសនជន គ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា អង្គការ សមាគម គណបក្សនយោបាយ ឬរូបវន្តបុគ្គលនិវាសនជនដែលប្រកបអាជីវកម្ម។

៥- និយោជិត សំដៅដល់ រូបវន្តបុគ្គលដែលបានទទួលប្រាក់បៀវត្សពីសកម្មភាពបម្រើការងាររបស់ខ្លួន រួមបញ្ចូលទាំងអ្នកទទួលខុសត្រូវឬអភិបាលរបស់សហគ្រាស អ្នករាជការសាធារណៈនិងពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត លើកលែងតែសមាជិករដ្ឋសភានិងព្រឹទ្ធសភា។

៦- ប្រាក់បៀវត្សប្រភពកម្ពុជា សំដៅដល់ ប្រាក់បៀវត្សដែលបានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញសកម្មភាពបម្រើការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដោយឡែកចំពោះប្រាក់បៀវត្សដែលអនិវាសនជនបានទទួលក្នុងការផ្ដល់ជំនួយបច្ចេកទេស ត្រូវចាត់ទុកថាមានប្រភពនៅក្នុងប្រទេសដែលអ្នកទូទាត់ប្រាក់បៀវត្សនោះស្នាក់នៅ។

៧- បរទេស៖

ក- ពេលណាប្រើជាមួយរូបវន្តបុគ្គល មានន័យថា អនិវាសនជន។

ខ- ពេលណាប្រើក្នុងការកំណត់ប្រភពប្រាក់ចំណូល មានន័យថា ក្រៅព្រះរាជាណាចក្រកម្ពុជា។

៨- ប្រាក់បៀវត្ស សំដៅដល់ បៀវត្ស ប្រាក់ឈ្នួល លាភការ ប្រាក់បំណាច់ បុព្វលាភ ប្រាក់ម៉ោងបន្ថែម ប្រាក់រង្វាន់ និងអត្ថប្រយោជន៍បន្ថែម ដែលបានទូទាត់ឱ្យដល់និយោជិតឬដែលបានទូទាត់ដើម្បីជាប្រយោជន៍ផ្ទាល់ឬប្រយោលដល់និយោជិត ចំពោះការបំពេញសកម្មភាពបម្រើការងារ។


https://www.moj.gov.kh/kh/law-regular

## ផ្នែកទី២
## ប្រាក់បៀវត្សរ៍លើកលែងពន្ធ

**មាត្រា៤៣ ._** ប្រាក់បៀវត្សរបស់មន្ត្រីការទូតនិងមន្ត្រីបរទេសដទៃទៀត

ការលើកលែងពន្ធលើប្រាក់បៀវត្សរបស់មន្ត្រីការទូតនិងមន្ត្រីបរទេសដទៃទៀតត្រូវបានកំណត់ដូចខាងក្រោម៖

១_ ត្រូវបានលើកលែងពន្ធលើប្រាក់បៀវត្សចំពោះ៖

ក_ ប្រាក់បៀវត្សដែលមន្ត្រីនិងនិយោជិតនៃបេសកកម្មទូតឬកុងស៊ុលរបស់រដ្ឋាភិបាលបរទេសណាមួយដែលកាន់លិខិតឆ្លងដែនការទូតឬផ្លូវការរបស់ប្រទេសនោះ បានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារជាផ្លូវការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ខ_ ប្រាក់បៀវត្សដែលតំណាង មន្ត្រី និងនិយោជិតបរទេសរបស់អង្គការអន្តរជាតិនិងរបស់ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសនៃរដ្ឋាភិបាលដទៃទៀត បានទទួលក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារជាផ្លូវការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២_ ការលើកលែងពន្ធក្នុងមាត្រានេះ ត្រូវឈរលើគោលការណ៍បដិការរវាងរដ្ឋាភិបាលដែលពាក់ព័ន្ធ។

**មាត្រា៤៤ ._** ប្រាក់ចំណូលលើកលែងពន្ធរបស់និយោជិត

ប្រាក់ចំណូលលើកលែងពន្ធរបស់និយោជិតត្រូវបានកំណត់ដូចខាងក្រោម៖

១_ ប្រាក់សំណងដោយពិតប្រាកដនូវចំណាយខាងវិជ្ជាជីវៈ ដែលបានចាយដោយនិយោជិតតាមសេចក្តីបង្គាប់ និងសម្រាប់ជាប្រយោជន៍នៃនិយោជក ហើយដែលបានបំពេញលក្ខខណ្ឌ៣(បី)ដូចខាងក្រោម៖

- បានចាយក្នុងផលប្រយោជន៍ផ្ទាល់និងដាច់ខាតរបស់សហគ្រាស
- មិនបង្ហាញលក្ខណៈហួសប្រមាណឬស្តុកស្តម្ភហួសហេតុ
- បានបង្ហាញជាភស្តុតាងដោយវិក្កយបត្រយលម្អិតនិងបានទូទាត់ស្រេចបាច់ ហើយដែលបានធ្វើក្នុងនាមអ្នកបានទទួលប្រាក់សំណងនូវចំណាយពិតប្រាកដ។

២_ ប្រាក់បំណាច់នានាក្នុងករណីរំលាយកិច្ចសន្យាក្នុងកម្រិតដែលមានបញ្ញត្តក្នុងច្បាប់ស្តីពីការងារ និងប្រភេទនៃប្រាក់បំណាច់ដែលទទួលបាននូវការលើកលែងពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៣_ លាភការបន្ថែមសម្រាប់បង្កើតបេឡាសោធននិងធានាសុខុមាលភាពសង្គម ឬមានចរិតលក្ខណៈខាងសង្គមកិច្ច ក្នុងករណីដែលបានបញ្ញត្តក្នុងច្បាប់ស្តីពីការងារនិងច្បាប់ស្តីពីរបបសន្តិសុខសង្គម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៤_ ការផ្តល់ឱ្យដោយឥតយកថ្លៃឬយកថ្លៃទាបជាងថ្លៃដើមនូវឯកសណ្ឋានឬបរិក្ខារសម្រាប់វិជ្ជាជីវៈពិសេស។

៥_ ប្រាក់បំណាច់ម៉ោការសម្រាប់ចំណាយបេសកកម្មនិងការធ្វើដំណើរ។ ប្រាក់បំណាច់នេះមិនត្រូវគិតបញ្ចូលជាមួយប្រាក់សំណងពិតប្រាកដនូវចំណាយដូចមានចែងក្នុងមាត្រានេះឡើយ។



https://www.moj.gov.kh/kh/law-regular

## ផ្នែកទី៣
## មូលដ្ឋានគិតពន្ធនិងអត្រាពន្ធ

**មាត្រា៤៥ .-** មូលដ្ឋានគិតពន្ធប្រចាំខែ

វៀរលែងតែអត្ថប្រយោជន៍បន្ថែមដែលត្រូវកំណត់ពន្ធតាមមាត្រា៤៨នៃច្បាប់នេះ មូលដ្ឋានគិតពន្ធប្រចាំខែរបស់និវាសនជន គឺជាប្រាក់បៀវត្សជាប់ពន្ធដោយអនុញ្ញាតឱ្យកាត់កងនូវ៖

១- ប្រាក់កាត់ទុកដែលជាកាតព្វកិច្ចក្នុងការប្រតិបត្តិតាមច្បាប់ស្តីពីការងារនិងច្បាប់ស្តីពីរបបសន្តិសុខសង្គម។

២- ការទូទាត់នានាដែលត្រូវបានលើកលែងពន្ធដូចមានចែងក្នុងមាត្រា៤៤នៃច្បាប់នេះ។

**មាត្រា៤៦ .-** ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ

ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែត្រូវបានកំណត់ដូចខាងក្រោម៖

១- ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែរបស់និយោជិតនិវាសនជនរួមមាន៖

ក- ប្រាក់បៀវត្សដែលបានទទួលពីប្រភពកម្ពុជា។

ខ- ប្រាក់បៀវត្សដែលបានទទួលពីប្រភពបរទេស។

គ- ប្រាក់បុរេប្រទាន ប្រាក់ឱ្យខ្ចី ឬប្រាក់រំដោះដែលនិយោជកបានបើកឱ្យនិយោជិត។ ប្រាក់បុរេប្រទាន ប្រាក់ឱ្យខ្ចី ឬប្រាក់រំដោះត្រូវបូកបន្ថែមលើបៀវត្សជាប់ពន្ធនៃខែដែលប្រាក់ទាំងនោះបានបើកហើយត្រូវកាត់បន្ថយពីប្រាក់បៀវត្សក្នុងខែដែលនិយោជិតបានបង់សងវិញ។

២- ផ្អែកលើការបង្ហាញភស្តុតាងនៃស្ថានភាពគ្រួសារ និយោជិតនិវាសនជនណាមួយដែលមានកូនស្ថិតក្នុងបន្ទុកនិង/ឬសហព័ទ្ធដែលធ្វើតែជាមេផ្ទះនាពេលដែលត្រូវបង់ពន្ធ ត្រូវបានទទួលនូវការបន្ថយមូលដ្ឋានកំណត់ពន្ធតាមចំនួនដែលត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៣- ចំពោះអ្នកជាប់ពន្ធអនិវាសនជន ប្រាក់បៀវត្សជាប់ពន្ធ គឺជាប្រាក់បៀវត្សប្រភពកម្ពុជាដែលត្រូវជាប់ពន្ធតាមបទប្បញ្ញត្តិទាំងឡាយនៃជំពូកនេះ។

**មាត្រា៤៧ .-** អត្រាពន្ធលើប្រាក់បៀវត្សប្រចាំខែ

សម្រាប់និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវបង់ត្រូវកំណត់តាមអត្រាកំណើនតាមថ្នាក់០(សូន្យ)ភាគរយ ៥(ប្រាំ)ភាគរយ ១០(ដប់)ភាគរយ ១៥(ដប់ប្រាំ)ភាគរយ និង ២០(ម្ភៃ)ភាគរយ លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែនិងត្រូវកាត់ទុកដោយនិយោជក។ ការកំណត់កម្រិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤៨ .-** ការកំណត់ប្រាក់ពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែម

១- ចំពោះអត្ថប្រយោជន៍បន្ថែមជារៀងរាល់ខែ និយោជកត្រូវកាត់ទុកនិងបង់ប្រាក់ពន្ធតាមអត្រា ២០(ម្ភៃ)ភាគរយនៃតម្លៃសរុបរបស់អត្ថប្រយោជន៍បន្ថែមដែលបានផ្តល់ឱ្យនិយោជិតទាំងអស់។ តម្លៃនៃអត្ថប្រយោជន៍បន្ថែម គឺជាតម្លៃទីផ្សារ រួមទាំងពន្ធអាករទាំងអស់។

២- វិធាននិងនីតិវិធីនៃការលើកលែងពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែមត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL
https://www.moj.gov.kh/kh/law-regular

**មាត្រា៤៩ .-** ការកំណត់ប្រាក់ពន្ធលើប្រាក់បៀវត្សរបស់អ្នកជាប់ពន្ធអនិវាសនជន

វៀរលែងតែអត្ថប្រយោជន៍បន្ថែមដែលត្រូវកំណត់ពន្ធតាមមាត្រា៤៨នៃច្បាប់នេះ សម្រាប់អ្នកជាប់ពន្ធអនិវាសនជន ប្រាក់ពន្ធត្រូវកាត់ទុកដោយអ្នកបើកប្រាក់ឱ្យតាមអត្រា២០(ម្ភៃ)ភាគរយ លើរាល់ការទូទាត់ប្រាក់បៀវត្សជាប់ពន្ធដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា៤៦នៃច្បាប់នេះ។ ពន្ធកាត់ទុកនេះ គឺជាពន្ធចុងក្រោយនៃពន្ធលើប្រាក់បៀវត្សសម្រាប់អនិវាសនជនជាអ្នកទទួលប្រាក់បៀវត្ស។

**មាត្រា៥០ .-** ឥណទានពន្ធបរទេស

អ្នកជាប់ពន្ធនិវាសនជនដែលបានទទួលប្រាក់បៀវត្សប្រភពបរទេសនិងបានបង់ពន្ធតាមច្បាប់ពន្ធដារបរទេស ត្រូវបានទទួលនូវឥណទានពន្ធសម្រាប់កាត់កងពីប្រាក់ពន្ធលើប្រាក់បៀវត្សដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែត្រូវមានឯកសារបញ្ជាក់អំពីការបង់ពន្ធនៅបរទេសនោះ។ ការគណនាប្រាក់ពន្ធដែលត្រូវបង់និងឥណទានពន្ធត្រូវកំណត់ដូចខាងក្រោម៖

១- ដើម្បីគណនាប្រាក់ពន្ធដែលត្រូវបង់នៅព្រះរាជាណាចក្រកម្ពុជា មុនពេលកាត់ឥណទានពន្ធនេះ ត្រូវយកចំនួនសរុបប្រាក់បៀវត្សដែលបានទទួលពីប្រភពកម្ពុជានិងប្រភពបរទេសមកគិត។

២- ឥណទានពន្ធត្រូវបានកំណត់ដាច់ដោយឡែកពីគ្នាសម្រាប់ប្រាក់ពន្ធដែលបានបង់ដោយនិវាសនជនកម្ពុជានៅប្រទេសក្រៅនីមួយៗ។ ប៉ុន្តែឥណទានពន្ធផ្តល់ឱ្យសម្រាប់ពន្ធលើប្រាក់បៀវត្សដែលបានបង់នៅប្រទេសក្រៅ គឺជាចំនួនដែលទាបជាងគេក្នុងចំណោម៖

- ក- ប្រាក់ពន្ធដែលបានបង់ជាក់ស្តែងនៅប្រទេសក្រៅណាមួយ។
- ខ- ចំនួនដែលបានមកពីការយកប្រាក់ពន្ធលើប្រាក់បៀវត្សសរុបពីគ្រប់ប្រភព ក្នុងរយៈពេលជាមួយគ្នាដែលគណនាតាមអត្រាកំណើនតាមថ្នាក់ក្នុងមាត្រា៤៧នៃច្បាប់នេះ ទៅគុណនឹងផលចែករវាងប្រាក់បៀវត្សដែលបានទទួលនៅប្រទេសក្រៅនោះ និងប្រាក់បៀវត្សសរុបពីគ្រប់ប្រភព។

៣- ការបង្វិលសងឥណទានពន្ធបរទេសអាចធ្វើទៅបាន លុះណាតែអ្នកជាប់ពន្ធនិវាសនជនបានបំពេញបែបបទ ព្រមទាំងផ្តល់ឯកសារនានាកំណត់ដោយរដ្ឋបាលសារពើពន្ធ ជាពិសេសសេចក្តីបញ្ជាក់របស់និយោជកនិងរដ្ឋបាលសារពើពន្ធនៃទីកន្លែងបម្រើការងារនៅបរទេសនោះ។

## ផ្នែកទី៤
## ភាតព្វកិច្ចរបស់និយោជកនិងនិយោជិត

**មាត្រា៥១ .-** កាតព្វកិច្ចកាត់ទុកប្រាក់ពន្ធ

កាតព្វកិច្ចកាត់ទុកប្រាក់ពន្ធត្រូវបានកំណត់ដូចខាងក្រោម៖

១- ពន្ធនេះ គឺជាកាតព្វកិច្ចរបស់រូបវន្តបុគ្គលដែលបានទទួលប្រាក់បៀវត្ស រួមទាំងរូបវន្តបុគ្គលបរទេស វៀរលែងតែមានបទប្បញ្ញត្តិផ្ទុយដែលមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិ។

២- ពន្ធលើប្រាក់បៀវត្ស ត្រូវប្រមូលតាមរបៀបកាត់ទុកជាមុនជារៀងរាល់ខែដោយនិយោជកទៅតាមពេលបើកប្រាក់បៀវត្ស។

៣_ ប្រសិនបើនិយោជកស្នាក់នៅបរទេស តំណាងដែលនិយោជកបានចាត់តាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺជាអ្នកទទួលភារៈកាត់ទុកពន្ធលើប្រាក់បៀវត្សមុនពេលបើកប្រាក់បៀវត្សឱ្យនិយោជិត និងត្រូវប្រកាសបង់ប្រាក់ពន្ធទាំងនោះជូនរដ្ឋបាលសារពើពន្ធ។

៤_ និយោជកឬតំណាងនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់និយោជកបរទេស និងនិយោជិតត្រូវទទួលខុសត្រូវរួមគ្នាក្នុងការបង់ពន្ធលើប្រាក់បៀវត្សក្នុងព្រះរាជាណាចក្រកម្ពុជា ដោយពុំកំណត់ថា ប្រាក់បៀវត្សបានបើកឱ្យនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬនៅបរទេសឡើយ។ ក្នុងករណីមិនបានកាត់ទុកប្រាក់ពន្ធលើប្រាក់បៀវត្ស និយោជកត្រូវទទួលខុសត្រូវចំពោះច្បាប់នេះ។

**មាត្រា៥២ ._** ការកាត់ទុកប្រាក់ពន្ធ ការកាន់កាប់បញ្ជិកា និងរបាយការណ៍

និយោជកដែលបើកប្រាក់បៀវត្សត្រូវជាប់ពន្ធ ត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

១_ កាត់ទុកប្រាក់ពន្ធមុនពេលបើកប្រាក់បៀវត្ស។

២_ រាយការណ៍ជូនរដ្ឋបាលសារពើពន្ធនិងនិយោជិតអំពីស្ថានភាពប្រាក់ពន្ធដែលបានកាត់ទុក។

៣_ កាន់កាប់និងថែរក្សាបញ្ជិកា។

**មាត្រា៥៣ ._** កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ

១_ ពន្ធលើប្រាក់បៀវត្សត្រូវដល់កំណត់និងត្រូវបង់នៅពេលបើកប្រាក់បៀវត្ស។

២_ ភ្នាក់ងារកាត់ទុកមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធលើប្រាក់បៀវត្សជារៀងរាល់ខែ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ពីខែដែលប្រាក់បៀវត្សបានកើតឡើង។

**មាត្រា៥៤ ._** វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើប្រាក់បៀវត្សត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

# ជំពូកទី៤

# អាករលើតម្លៃបន្ថែម

## ផ្នែកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា៥៥ ._** កម្មវត្ថុនៃអាករ

អាករលើតម្លៃបន្ថែមត្រូវអនុវត្តលើការផ្គត់ផ្គង់ជាប់អាករនូវទំនិញឬសេវា។

**មាត្រា៥៦ ._** វិសាលភាពនៃអាករ

អាករលើតម្លៃបន្ថែមអនុវត្តលើរាល់ការផ្គត់ផ្គង់ជាប់អាករនូវទំនិញឬសេវានៅក្នុងព្រះរាជាណាចក្រកម្ពុជា៖



https://www.moj.gov.kh/kh/law-regular

**មាត្រា៥៧ .-** និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងជំពូកនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១_ ទំនិញ សំដៅដល់ ទ្រព្យរូបីក្រៅពីដីធ្លីនិងប្រាក់កាស។

២_ សេវា សំដៅដល់ ការផ្តល់អ្វីមួយដែលមានតម្លៃក្រៅពីទំនិញ ដីធ្លី និងប្រាក់កាស។

៣_ ការផ្គត់ផ្គង់ទំនិញ សំដៅដល់ ការផ្ទេរសិទ្ធិប្រើប្រាស់ ឬសិទ្ធិចាត់ចែងក្នុងឋានៈជាម្ចាស់កម្មសិទ្ធិទំនិញ ទោះបីមានសំណងឬគ្មានសំណងក្តី។ ការផ្គត់ផ្គង់សេវាបន្ទាប់បន្សំដែលទាក់ទិននឹងការផ្គត់ផ្គង់ទំនិញ ត្រូវចាត់ទុកដូចជាការផ្គត់ផ្គង់ទំនិញ។

៤_ ការផ្គត់ផ្គង់សេវា សំដៅដល់ ការផ្គត់ផ្គង់ដែលមិនមែនជាការផ្គត់ផ្គង់ទំនិញ ដីធ្លី ឬប្រាក់កាស ដែលធ្វើឡើងដើម្បីបានទទួលសំណងឬគ្មានសំណងក្តី។ ការផ្គត់ផ្គង់ទំនិញបន្ទាប់បន្សំដែលទាក់ទិននឹងការផ្គត់ផ្គង់សេវា ត្រូវចាត់ទុកដូចជាការផ្គត់ផ្គង់សេវា។

៥_ បុគ្គល សំដៅដល់ បុគ្គលឬក្រុមបុគ្គលដែលធ្វើអាជីវកម្ម ហើយនិងបុគ្គលណាមួយទៀតដែលទាក់ទិនជាមួយនឹងបុគ្គលនោះ។

៦_ ទាក់ទិន ចំពោះបុគ្គលណាមួយ មានន័យថា៖

- ក_ បុគ្គលណាមួយដែលមានកម្មសិទ្ធិចាប់ពី២០(ម្ភៃ)ភាគរយឡើងទៅលើតម្លៃឬសិទ្ធិបោះឆ្នោតនៃភាគកម្មនៅក្នុងដើមទុនផ្ទាល់នៃបុគ្គលដែលលើកយកមកពិចារណា។
- ខ_ មានការគ្រប់គ្រងរួមគ្នា ឬមាននាយករួមគ្នាជាមួយបុគ្គល។
- គ_ ជាសមាជិកគ្រួសារ ឬជាសហព័ទ្ធ ឬជាសមាជិកក្រុមគ្រួសារនៃសហព័ទ្ធរបស់បុគ្គល។
- ឃ_ បានទិញចាប់ពី៣០(សាមសិប)ភាគរយឡើងទៅនៃធាតុចេញសរុបរបស់បុគ្គលក្នុងរយៈពេល៣(បី)ខែបន្តបន្ទាប់។

៧_ អាករ ក្នុងជំពូកនេះ សំដៅដល់ អាករលើតម្លៃបន្ថែម។

## ផ្នែកទី២
## គោលការណ៍ទូទៅ

**មាត្រា៥៨ .-** បុគ្គលជាប់អាករ

បុគ្គលជាប់អាករ សំដៅដល់ បុគ្គលដែលត្រូវជាប់ពន្ធតាមរបបស្វ័យប្រកាសហើយដែលធ្វើការផ្គត់ផ្គង់ជាប់អាករដូចមានចែងក្នុងមាត្រា៥៩នៃច្បាប់នេះ។ សម្រាប់គោលដៅនៃមាត្រានេះ បុគ្គលអនិវាសនជនដែលផ្គត់ផ្គង់ទំនិញឌីជីថលឬសេវាឌីជីថលមកក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវចាត់ទុកជាបុគ្គលជាប់អាករ។

**មាត្រា៥៩ .-** ការផ្គត់ផ្គង់ជាប់អាករ

លើកលែងតែមានបទប្បញ្ញត្តិផ្ទុយនៅក្នុងជំពូកនេះ ពាក្យ ការផ្គត់ផ្គង់ជាប់អាករ សំដៅដល់៖

១_ ការផ្គត់ផ្គង់ទំនិញឬសេវាដោយបុគ្គលជាប់អាករនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២_ ការដកយកទំនិញឬសេវាមកប្រើប្រាស់ផ្ទាល់ខ្លួនដោយបុគ្គលជាប់អាករ។

៣_ ការផ្តល់ជាអំណោយឬការផ្គត់ផ្គង់ក្រោមតម្លៃពិតនូវទំនិញឬសេវាដោយបុគ្គលជាប់អាករ។

៤_ ការផ្គត់ផ្គង់ទំនិញឌីជីថលឬសេវាឌីជីថលមកក្នុងព្រះរាជាណាចក្រកម្ពុជាដូចមានចែងក្នុងមាត្រា៥៨ នៃច្បាប់នេះ។

៥_ ការនាំចូលទំនិញមកក្នុងដែនគយនៃព្រះរាជាណាចក្រកម្ពុជា។



https://www.moj.gov.kh/kh/law-regular

**មាត្រា៦០ ._ តម្លៃជាប់អាករ**

តម្លៃជាប់អាករត្រូវបានកំណត់ដូចខាងក្រោម៖

១_ តម្លៃជាប់អាករនៃការផ្គត់ផ្គង់ គឺជាថ្លៃទំនិញឬសេវាដែលអ្នកលក់យកពីអ្នកទិញ។ តម្លៃជាប់អាករ រួមមានតម្លៃដឹកជញ្ជូន និងតម្លៃលើខ្នង់ដទៃទៀតដែលត្រូវទូទាត់ឱ្យអ្នកលក់ចំពោះការផ្គត់ផ្គង់នោះ រួមបញ្ចូលអាករគ្រប់ប្រភេទ លើកលែងតែអាករលើតម្លៃបន្ថែម។

២_ ក្នុងករណីដែលការទូទាត់ចំពោះការផ្គត់ផ្គង់ជាប់អាករជាសំណងអ្វីមួយក្រៅពីប្រាក់កាសដើម្បីជាផលប្រយោជន៍ផ្ទាល់ឬប្រយោលដល់អ្នកលក់ សំណងនោះត្រូវគិតបញ្ចូលក្នុងតម្លៃជាប់អាករតាមតម្លៃទីផ្សារ។

៣_ តម្លៃជាប់អាកររបស់ទំនិញនាំចូល គឺជាតម្លៃគិតពន្ធគយ រួមបញ្ចូលទាំងពន្ធគយនិងអាករនានានៅពេលនាំចូល។

៤_ ប្រសិនបើតម្លៃជាប់អាកររបស់ទំនិញឬសេវាដែលបានផ្គត់ផ្គង់មិនតំណាងឱ្យតម្លៃពិតទេនោះ រដ្ឋបាលសារពើពន្ធអាចកំណត់ចេញនូវតម្លៃមួយសម្រាប់ទំនិញឬសេវា ហើយតម្លៃនោះត្រូវចាត់ទុកជាតម្លៃត្រឹមត្រូវរហូតដល់ពេលមានភស្តុតាងបញ្ជាក់ផ្សេងដែលរដ្ឋបាលសារពើពន្ធបានយល់ព្រម។

៥_តម្លៃជាប់អាករនៃទំនិញដែលបានប្រើប្រាស់រួច ដែលបុគ្គលជាប់អាករបានទិញពីអ្នកប្រើប្រាស់ដើម្បីលក់ជាប្រចាំឬលក់ជំនួសមុខឱ្យអ្នកប្រើប្រាស់ គឺជាចំនួនលម្អៀងរវាងថ្លៃលក់និងថ្លៃទិញ ឬប្រាក់កម្រៃដែលបានមកពីការលក់ទំនិញនោះ។

**មាត្រា៦១ ._ ពេលផ្គត់ផ្គង់**

ពេលផ្គត់ផ្គង់ត្រូវបានកំណត់ដូចខាងក្រោម៖

១_ អាករលើតម្លៃបន្ថែមត្រូវដល់កំណត់និងត្រូវបង់នៅពេលផ្គត់ផ្គង់។

២_ ពេលផ្គត់ផ្គង់ទំនិញឬសេវា គឺជាពេលដែលអ្នកលក់ត្រូវចេញវិក្កយបត្រ ឬជាពេលដែលអ្នកលក់បានចេញវិក្កយបត្រ ប្រសិនបើវិក្កយបត្រនោះត្រូវបានចេញមុនពេលដែលអ្នកលក់ត្រូវចេញវិក្កយបត្រ។

៣_វិក្កយបត្រអាករលើតម្លៃបន្ថែម ត្រូវចេញយ៉ាងយឺតបំផុត៧(ប្រាំពីរ)ថ្ងៃ ក្រោយការបញ្ជូនទំនិញឬការបំពេញសេវា ឬក្រោយការទូទាត់ក្នុងករណីដែលការទូទាត់ធ្វើឡើងមុនការបញ្ជូនទំនិញឬការបំពេញសេវា។ ប្រសិនបើការបញ្ជូនទំនិញពុំមានវិក្កយបត្រភ្ជាប់ជាមួយទេ ត្រូវភ្ជាប់ឯកសារបញ្ជូនទំនិញដែលបានកត់ត្រាត្រឹមត្រូវក្នុងទិនានុប្បវត្តិបញ្ជូនទំនិញ។

៤_ចំពោះការផ្គត់ផ្គង់ទំនិញឬសេវាដែលធ្វើឡើងជាបន្ត ឬដែលមានការទូទាត់ច្រើនលើក ពេលផ្គត់ផ្គង់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៥_ចំពោះការនាំចូលទំនិញ ពេលផ្គត់ផ្គង់ គឺជាពេលដែលអ្នកនាំចូលដាក់លិខិតប្រកាសជូនរដ្ឋបាលគយស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៦២ ._ ទីកន្លែងផ្គត់ផ្គង់**

ទីកន្លែងផ្គត់ផ្គង់ត្រូវបានកំណត់ដូចខាងក្រោម៖

១_ ការផ្គត់ផ្គង់ទំនិញត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើទំនិញនោះត្រូវបានប្រគល់ឱ្យ ទោះបីមានលក្ខណៈជាការផ្ទេរសិទ្ធិប្រើប្រាស់ឬសិទ្ធិចាត់ចែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ចំពោះករណីដែលការផ្គត់ផ្គង់ត្រូវមានការដឹកជញ្ជូន ការផ្គត់ផ្គង់ត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើទំនិញស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅពេលដែលការដឹកជញ្ជូនត្រូវបានចាប់ផ្តើម។



https://www.moj.gov.kh/kh/law-regular

២- ការផ្គត់ផ្គង់សេវាត្រូវចាត់ទុកថាបានធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើសេវានោះបានបំពេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា វៀរលែងតែៈ

ក- ការផ្គត់ផ្គង់សេវាជាប់ទាក់ទិននឹងអចលនទ្រព្យត្រូវកំណត់ថា សេវានោះបានធ្វើឡើងនៅទីកន្លែងដែលអចលនទ្រព្យនោះស្ថិតនៅ។

ខ- ការផ្គត់ផ្គង់សេវាជាប់ទាក់ទិននឹងការដឹកជញ្ជូនត្រូវកំណត់ថា សេវានោះបានធ្វើឡើងនៅទីកន្លែងនៃការដឹកជញ្ជូននោះ។

៣- ទំនិញត្រូវចាត់ទុកថាបាននាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើទំនិញនោះត្រូវបាននាំចូលមកក្នុងដែនគយនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៦៣ .-** ការផ្គត់ផ្គង់មិនជាប់អាករ

ការផ្គត់ផ្គង់មិនជាប់អាករមានដូចខាងក្រោមៈ

១- សេវាសិក្សាអប់រំ។

២- សេវាប្រៃសណីយ៍សាធារណៈ។

៣- សេវារបស់មន្ទីរពេទ្យនិងគ្លីនិក សេវាខាងវេជ្ជសាស្ត្រនិងទន្តសាស្ត្រ និងការលក់ទំនិញបន្ទាប់បន្សំខាងវេជ្ជសាស្ត្រនិងទន្តសាស្ត្រដែលទាក់ទិននឹងការបំពេញសេវាទាំងនេះ។

៤- សេវាដឹកជញ្ជូនអ្នកដំណើរដោយប្រព័ន្ធដឹកជញ្ជូនសាធារណៈ ដែលជាកម្មសិទ្ធិទាំងស្រុងរបស់រដ្ឋ។

៥- សេវាធានារ៉ាប់រង។

៦- ការផ្គត់ផ្គង់ថាមពលអគ្គិសនីនិងការផ្គត់ផ្គង់ទឹកស្អាត។

៧- ផលិតផលកសិកម្មមិនទាន់កែច្នៃផលិតក្នុងស្រុក។

៨- សេវាប្រមូលសំរាមនិងកាកសំណល់រឹងឬរាវ។

៩- សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

១០- ការនាំចូលសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនដែលរួចពន្ធគយក្នុងកម្រិតតម្លៃដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

១១- សកម្មភាពមិនស្វែងរកចំណេញដើម្បីបម្រើផលប្រយោជន៍សាធារណៈ ដែលបានទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦៤ .-** ការផ្គត់ផ្គង់មិនជាប់អាករចំពោះបេសកកម្មទូតនិងអង្គការអន្តរជាតិ

ការផ្គត់ផ្គង់មិនជាប់អាករចំពោះបេសកកម្មទូតនិងអង្គការអន្តរជាតិត្រូវបានកំណត់ដូចខាងក្រោមៈ

១- ការនាំចូលឬការទិញក្នុងស្រុកនូវទំនិញឬសេវាដោយបេសកកម្មទូតនិងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត សម្រាប់យកមកប្រើនៅក្នុងការបំពេញមុខងារជាផ្លូវការរបស់ខ្លួន ត្រូវកំណត់ថាជាការផ្គត់ផ្គង់មិនជាប់អាករ។ ការផ្គត់ផ្គង់មិនជាប់អាករត្រូវបានផ្តល់ឱ្យតែក្នុងករណីមានការបញ្ជាក់ពីប្រធានបេសកកម្មជូនរដ្ឋបាលសារពើពន្ធថា ទំនិញទាំងនោះបាននាំចូលមកសម្រាប់គោលដៅនៃការប្រើប្រាស់ខាងលើតែប៉ុណ្ណោះ។



https://www.moj.gov.kh/kh/law-regular

២_ ការនាំចូលឬការទិញក្នុងស្រុកនូវទំនិញឬសេវាសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់បុគ្គលិកផ្លូវការនៃបេសកកម្មទូតនិងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត ដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ត្រូវកំណត់ថាជាការផ្គត់ផ្គង់មិនជាប់អាករចំពោះតែមុខទំនិញទាំងឡាយណាដែលមានចុះនៅក្នុងបញ្ជីរាយមុខទំនិញដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៣_ ការផ្គត់ផ្គង់មិនជាប់អាករនៅក្នុងមាត្រានេះ ត្រូវឈរលើគោលការណ៍បដិការរវាងរដ្ឋាភិបាលពាក់ព័ន្ធ។

## ផ្នែកទី៣
## អត្រាអាករនិងការកំណត់ប្រាក់អាករ

**មាត្រា៦៥ ._** អត្រាអាករ

អត្រាអាករត្រូវបានកំណត់ដូចខាងក្រោម៖

១_ អាករលើតម្លៃបន្ថែមត្រូវកំណត់តាមអត្រា១០(ដប់)ភាគរយ លើតម្លៃជាប់អាករនៃការផ្គត់ផ្គង់ជាប់អាករនីមួយៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២_ អាករលើតម្លៃបន្ថែមត្រូវកំណត់តាមអត្រា០(សូន្យ)ភាគរយ លើតម្លៃជាប់អាករនៃការផ្គត់ផ្គង់ជាប់អាករនីមួយៗចំពោះទំនិញនាំចេញពីព្រះរាជាណាចក្រកម្ពុជា ឬការផ្គត់ផ្គង់សេវាជាប់អាករដែលបានបំពេញនៅក្រៅព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងមាត្រា៦២នៃច្បាប់នេះ។

៣_ រដ្ឋបាលសារពើពន្ធអាចប្រើប្រាស់ឯកសារមួយចំនួន ដើម្បីបញ្ជាក់ថាមានការនាំចេញជាក់ស្តែង ក្នុងនោះមានជាអាទិ៍ ប្រតិវេទន៍គយនាំចេញរបស់រដ្ឋបាលគយ ឯកសារនាំចូលរបស់ប្រទេសនាំចូល លិខិតឥណទានបានប្រើប្រាស់ និងការទូទាត់ដែលធនាគារក្នុងស្រុកបានទទួល។

**មាត្រា៦៦ ._** ការកំណត់ប្រាក់អាករ

ប្រាក់អាករត្រូវបានកំណត់ដូចខាងក្រោម៖

១_ អាករដែលបានកំណត់ក្នុងមាត្រា៦៥នៃច្បាប់នេះ ត្រូវចាត់ទុកជាបំណុលចំពោះរដ្ឋនៅពេលផ្គត់ផ្គង់។

២_ ប្រាក់អាករត្រូវបង់ជូនរដ្ឋស្មើនឹងប្រាក់អាករលើធាតុចេញសរុបតាមអត្រាក្នុងមាត្រា៦៥នៃច្បាប់នេះ ដកឥណទានអាករលើធាតុចូលដែលបានអនុញ្ញាតសរុបក្នុងខែជាមួយគ្នា។

**មាត្រា៦៧ ._** អចលកម្មរូបីដែលឈប់ប្រើប្រាស់ក្នុងអាជីវកម្ម

ក្នុងករណីអចលកម្មរូបីនៃអាជីវកម្មណាមួយដែលបានទទួលឥណទានអាករដូចមានចែងក្នុងមាត្រា៦៣នៃច្បាប់នេះ ត្រូវឈប់ប្រើប្រាស់នៅក្នុងអាជីវកម្មរបស់បុគ្គលជាប់អាករ ទ្រព្យនោះត្រូវចាត់ទុកថាបានលក់និងត្រូវជាប់អាករតាមតម្លៃទីផ្សារនៅពេលឈប់ប្រើប្រាស់។


https://www.moj.gov.kh/kh/law-regular

**មាត្រា៦៨ .-** ឥណទានអាករលើធាតុចូលនិងការផ្គត់ផ្គង់មិនជាប់អាករ

ឥណទានអាករលើធាតុចូលនិងការផ្គត់ផ្គង់មិនជាប់អាករត្រូវបានកំណត់ដូចខាងក្រោម៖

១- ប្រាក់អាករដែលបុគ្គលជាប់អាករបានបង់លើទំនិញឬសេវាសម្រាប់ប្រើប្រាស់ក្នុងអាជីវកម្មដែលបុគ្គលជាប់អាករម្នាក់ទៀតបានផ្គត់ផ្គង់ឱ្យ ឬប្រាក់អាករដែលបានបង់ដោយបុគ្គលជាប់អាករក្នុងឋានៈជាអ្នកនាំចូលលើទំនិញឬសេវានាំចូលសម្រាប់ប្រើប្រាស់នៅក្នុងអាជីវកម្មរបស់ខ្លួន ត្រូវក្លាយជាឥណទានអាករលើធាតុចូលសម្រាប់កាត់កងចេញពីអាករលើធាតុចេញ។ ធាតុចូល មានន័យថា ទំនិញឬសេវាដែលបានទិញចូល ហើយធាតុចេញ មានន័យថា ទំនិញឬសេវាដែលបានលក់ចេញ។

២- ក្នុងករណីទំនិញឬសេវាទិញចូលត្រូវបានប្រើប្រាស់មួយចំណែកជាការផ្គត់ផ្គង់ជាប់អាករ និងមួយចំណែកទៀតជាការផ្គត់ផ្គង់មិនជាប់អាករ ឥណទានអាករត្រូវបានអនុញ្ញាតឱ្យតែចំពោះចំណែកដែលបានប្រើប្រាស់ជាការផ្គត់ផ្គង់ជាប់អាករ។

៣- ចំពោះការផ្គត់ផ្គង់មិនជាប់អាករនូវទំនិញឬសេវាដល់បេសកកម្មទូតនិងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត ដូចមានចែងក្នុងមាត្រា៦៤នៃច្បាប់នេះ អ្នកផ្គត់ផ្គង់ត្រូវបានអនុញ្ញាតនូវឥណទានអាករលើធាតុចូលដោយពុំគិតពីលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រានេះ។

**មាត្រា៦៩ .-** ឯកសារចាំបាច់សម្រាប់សុំឥណទានអាករលើធាតុចូល

ការស្នើសុំឥណទានអាករលើធាតុចូលត្រូវភ្ជាប់មកជាមួយនូវ៖

១- វិក្កយបត្រអាករលើតម្លៃបន្ថែម ដែលបានធ្វើឡើងស្របតាមមាត្រា៧៨នៃច្បាប់នេះ។

២- ប្រតិវេទន៍គយនាំចូលដែលបានធ្វើឡើងស្របតាមច្បាប់ស្តីពីគយ និងបង្កាន់ដៃបង់ប្រាក់ពន្ធ ឬបង្កាន់ដៃបង់ប្រាក់ផ្សេងៗរបស់រដ្ឋបាលគយ។

**មាត្រា៧០ .-** អាករលើធាតុចូលដែលមិនអនុញ្ញាតឱ្យប្រើជាឥណទាន

អាករលើធាតុចូលដែលមិនអនុញ្ញាតឱ្យប្រើជាឥណទាន រួមមានប្រាក់អាករដែលបុគ្គលជាប់អាករបានបង់លើការចំណាយ ជាអាទិ៍មាន ការទទួលភ្ញៀវ ការកម្សាន្តឬសម្រាកលំហែ ការទិញរថយន្ត ឬការទិញផលិតផលតេលសិលាមួយចំនួន។

## ផ្នែកទី៤
## ការបង់ប្រាក់អាករ

**មាត្រា៧១ .-** កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់អាករ

បុគ្គលជាប់អាករត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់អាករជារៀងរាល់ខែយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់។



https://www.moj.gov.kh/kh/law-regular

**មាត្រា៧២ .-** ការចាត់ចែងចំពោះចំនួនឥណទានលើស

ប្រសិនបើអាករលើធាតុចូលដែលបុគ្គលជាប់អាករបានបង់តាមមាត្រា៦៥នៃច្បាប់នេះ មានចំនួនច្រើនជាងអាករលើធាតុចេញដែលបុគ្គលនោះប្រមូលសម្រាប់ខែណាមួយៈ

១- ចំនួនលើសត្រូវប្រើជាឥណទានអាករចំពោះប្រាក់អាករដែលបុគ្គលនៅជំពាក់ខែកន្លងទៅ។

២- ចំនួនលើសដែលនៅសល់ទៀតនោះ ត្រូវចាត់ទុកជាឥណទានអាករលើធាតុចូលនៃមាត្រា៦៨នៃច្បាប់នេះ សម្រាប់ខែបន្ទាប់។

**មាត្រា៧៣ .-** ការបង្វិលសងប្រាក់អាករឱ្យអ្នកនាំចេញ

រដ្ឋបាលសារពើពន្ធអាចបង្វិលសងនូវៈ

១- ឥណទានអាករលើធាតុចូលលើសប្រចាំខែ តាមការស្នើសុំរបស់បុគ្គលជាប់អាករដែលមានសកម្មភាពនាំចេញជាចម្បង ប្រសិនបើបុគ្គលនោះបានបង្ហាញឯកសារបញ្ជាក់ច្បាស់លាស់ក្នុងការនាំចេញ និងបានប្រតិបត្តិត្រឹមត្រូវនូវកាតព្វកិច្ចកាន់បញ្ជិកានិងឯកសារផ្សេងៗទៀត។

២- ប្រាក់អាករដែលទេសចរបរទេសបានបង់លើការទិញទំនិញពីបុគ្គលជាប់អាករ សម្រាប់យកទៅប្រើប្រាស់នៅក្រៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៧៤ .-** ការបង្វិលសងប្រាក់អាករក្នុងករណីមានឥណទានអាករលើសចាប់ពី៣(បី)ខែឡើងទៅ

ប្រសិនបើបុគ្គលជាប់អាករមានឥណទានអាករលើធាតុចូលលើសចាប់ពី៣(បី)ខែឡើងទៅ បុគ្គលនោះអាចដាក់ពាក្យសុំបង្វិលសងប្រាក់អាករនៅដំណាច់ខែទី៣(បី) ឬនៅក្នុងខែណាមួយជាបន្តមកទៀត។ ដើម្បីទទួលបានការបង្វិលសងប្រាក់អាករសម្រាប់ខែណាមួយ ពាក្យសុំត្រូវដាក់ស្នើក្នុងរយៈពេល២០(ម្ភៃ)ថ្ងៃក្រោយដំណាច់ខែទាំងនោះ។

**មាត្រា៧៥ .-** ការអនុវត្តអាករលើតម្លៃបន្ថែមចំពោះគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់

ការផ្គត់ផ្គង់ធាតុចូលផលិតកម្មក្នុងស្រុកសម្រាប់បម្រើដល់ការអនុវត្តគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដូចមានចែងក្នុងបទប្បញ្ញត្តិពាក់ព័ន្ធនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាត្រូវជាប់អាករលើតម្លៃបន្ថែមតាមអត្រា០(សូន្យ)ភាគរយ។

**មាត្រា៧៦ .-** ការទទួលខុសត្រូវចំពោះការប្រមូលនិងការបង់អាករ

ការទទួលខុសត្រូវចំពោះការប្រមូលនិងការបង់អាករត្រូវបានកំណត់ដូចខាងក្រោមៈ

១- បុគ្គលជាប់អាករឬអ្នកនាំចូល មានកាតព្វកិច្ចត្រូវបង់អាករតាមមាត្រា៦៥នៃច្បាប់នេះ លើរាល់ការផ្គត់ផ្គង់ជាប់អាករដែលបុគ្គលជាប់អាករឬអ្នកនាំចូលបានអនុវត្ត។

២- លក្ខខណ្ឌពិសេសបញ្ជាក់អំពីការទទួលខុសត្រូវរបស់អ្នកទិញចំពោះប្រាក់អាករ ក្នុងករណីដែលអ្នកផ្គត់ផ្គង់មិនមានគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្នុងករណីដែលមានឧបសគ្គផ្សេងទៀតដើម្បីប្រមូលប្រាក់អាករពីអ្នកផ្គត់ផ្គង់ ត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។


https://www.moj.gov.kh/kh/law-regular

៣_ បុគ្គលណាមួយដែលបានធ្វើការផ្គត់ផ្គង់ទំនិញឬសេវា ក្នុងនាមម្ចាស់កម្មសិទ្ធិនិងមិនមែនក្នុងឋានៈជានិយោជិតរបស់បុគ្គលណាមួយហើយដែលមានការគ្រប់គ្រងលើការផ្គត់ផ្គង់ ត្រូវចាត់ទុកថាជាបុគ្គលជាប់អាករសម្រាប់ការផ្គត់ផ្គង់នោះ។

## ផ្នែកទី៥
## បទប្បញ្ញត្តិខាងរដ្ឋបាល

**មាត្រា៧៧ ._** ការចុះបញ្ជី

ការចុះបញ្ជីត្រូវបានកំណត់ដូចខាងក្រោម៖

១_ បុគ្គលជាប់អាករដូចមានចែងក្នុងមាត្រា៥៨នៃច្បាប់នេះ ត្រូវធ្វើការចុះបញ្ជីសម្រាប់អាករលើតម្លៃបន្ថែមក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ក្រោយថ្ងៃដែលបុគ្គលនោះក្លាយជាបុគ្គលជាប់អាករ។

២_ ចំពោះបុគ្គលដែលមានការតម្រូវឱ្យធ្វើការចុះបញ្ជី ហើយមិនបានធ្វើការចុះបញ្ជី រដ្ឋបាលសារពើពន្ធអាចធ្វើការចុះបញ្ជីបុគ្គលនោះ ចាប់តាំងពីពេលដែលបុគ្គលនោះត្រូវមកធ្វើការចុះបញ្ជី។ បុគ្គលដែលត្រូវបានចុះបញ្ជីតាមបែបនេះ ត្រូវទទួលខុសត្រូវចំពោះប្រាក់អាករទាំងអស់ក្នុងមាត្រា៦៥នៃច្បាប់នេះ ចាប់តាំងពីកាលបរិច្ឆេទដែលបុគ្គលនោះត្រូវមកធ្វើការចុះបញ្ជី។

៣_ សម្រាប់ក្រុមបុគ្គលទាក់ទិនពីរនាក់ឬច្រើននាក់ ដែលក្នុងនោះបុគ្គលម្នាក់ឬច្រើននាក់មិនមែនជាបុគ្គលជាប់អាករទេនោះ រដ្ឋបាលសារពើពន្ធអាចចាត់ទុកបុគ្គលជាប់អាករណាមួយថាបានចុះបញ្ជីសម្រាប់សកម្មភាពសេដ្ឋកិច្ចទាក់ទិនទាំងមូលឬភាគណាមួយ។ ប្រសិនបើគ្មានបុគ្គលទាក់ទិនណាម្នាក់ជាបុគ្គលជាប់អាករទេនោះ រដ្ឋបាលសារពើពន្ធអាចចុះបញ្ជីនូវបុគ្គលក្នុងក្រុមម្នាក់ឬច្រើននាក់សម្រាប់សកម្មភាពសេដ្ឋកិច្ចទាក់ទិនទាំងមូលឬភាគណាមួយ។

៤_ សម្រាប់គោលដៅនៃការចុះបញ្ជីនិងដោយមានការយល់ព្រមពីរដ្ឋបាលសារពើពន្ធ ចំពោះបុគ្គលជាប់អាករមួយក្រុមដែលជាប់ទាក់ទិនគ្នាដូចមានចែងក្នុងមាត្រា៥៧នៃច្បាប់នេះ សកម្មភាពរបស់សមាជិកនានានៅក្នុងក្រុម អាចចាត់ទុកជាសកម្មភាពរបស់សមាជិកជ្រើសតាំងតែម្នាក់ប៉ុណ្ណោះ។ ក្នុងករណីនេះ សមាជិកម្នាក់ៗនៅក្នុងក្រុមត្រូវមានការទទួលខុសត្រូវរួមគ្នានិងយ៉ាងពេញលេញចំពោះការប្រតិបត្តិតាមបទប្បញ្ញត្តិនៃជំពូកនេះ។

**មាត្រា៧៨ ._** វិក្កយបត្រអាករលើតម្លៃបន្ថែម

វិក្កយបត្រអាករលើតម្លៃបន្ថែមត្រូវបានកំណត់ដូចខាងក្រោម៖

១_ បុគ្គលជាប់អាករដែលធ្វើការផ្គត់ផ្គង់ ត្រូវចេញវិក្កយបត្រអាករដោយមានដាក់ចំណងជើងថាវិក្កយបត្រអាករ ហើយមានចុះលេខរៀងត្រឹមត្រូវឱ្យទៅអ្នកទិញដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស និងត្រូវចេញវិក្កយបត្រធម្មតាទៅឱ្យអ្នកទិញដែលមិនស្ថិតនៅក្រោមរបបស្វ័យប្រកាស។

២_ បុគ្គលទាំងឡាយមិនអាចចេញវិក្កយបត្រឬឯកសារផ្សេងទៀតបញ្ជាក់នូវទឹកប្រាក់ណាមួយថាជាប្រាក់អាករលើការផ្គត់ផ្គង់ទំនិញឬសេវាបានទេ លើកលែងតែបុគ្គលនោះជាបុគ្គលជាប់អាករបានចុះបញ្ជីស្របតាមមាត្រា៧៧នៃច្បាប់នេះ ហើយទំនិញឬសេវាផ្គត់ផ្គង់គឺជាទំនិញឬសេវាជាប់អាករ។


https://www.moj.gov.kh/kh/law-regular

៣- ក្រៅពីទណ្ឌកម្មដទៃទៀត ប្រសិនបើវិក្កយបត្រណាមួយត្រូវបានរកឃើញថាក្លែងបន្លំជាវិក្កយបត្រអាករលើតម្លៃបន្ថែម ហើយវិក្កយបត្រនោះបានបង្ហាញថា មានទឹកប្រាក់អាករមួយចំនួនត្រូវបង់ បុគ្គលអ្នកចេញវិក្កយបត្រត្រូវបង់ជូនរដ្ឋបាលសារពើពន្ធក្នុងរយៈពេល៧(ប្រាំពីរ)ថ្ងៃ ក្រោយកាលបរិច្ឆេទចេញវិក្កយបត្រនូវទឹកប្រាក់ដែលបានចុះលើវិក្កយបត្រនោះ ទោះបីជាទឹកប្រាក់អាករត្រូវបង់មែនឬមិនមែនក្ដី។

៤- ក្នុងករណីមានការលក់រាយ ដែលក្នុងនោះ ការលក់ភាគច្រើនមិនបានធ្វើជាមួយបុគ្គលជាប់អាករ វិក្កយបត្រដែលតម្រូវដោយកថាខណ្ឌទី១នៃមាត្រានេះ ត្រូវចាត់ទុកថាបានបំពេញគ្រប់គ្រាន់ ប្រសិនបើអ្នកលក់បានផ្ដល់បង្កាន់ដៃទទួលប្រាក់លម្អិតដែលបានកត់ត្រាក្នុងបញ្ជីបេឡា ឬក៏ឯកសារផ្សេងទៀត។

៥- ចំពោះការនាំចូល ប្រតិវេទន៍គយដែលបានបំពេញត្រឹមត្រូវនិងដែលមានសេចក្ដីបញ្ជាក់អំពីការបង់ប្រាក់អាករ ត្រូវប្រើប្រាស់ជាឯកសារត្រួតពិនិត្យដើម្បីកំណត់លក្ខណៈអាចទទួលបាននូវឥណទានអាករ។

**មាត្រា៧៩ .-** ការមិនបានចេញវិក្កយបត្រអាករលើតម្លៃបន្ថែម

ការមិនបានចេញវិក្កយបត្រអាករត្រូវទទួលរងទណ្ឌកម្មដូចខាងក្រោម៖

១- ក្រៅពីទណ្ឌកម្មដទៃទៀត ប្រសិនបើរដ្ឋបាលសារពើពន្ធរកឃើញជាលើកទី២(ពីរ)ថា គ្រឹះស្ថានអាជីវកម្មណាមួយរបស់បុគ្គលជាប់អាករមិនបានចេញវិក្កយបត្រតាមការតម្រូវនោះ រដ្ឋបាលសារពើពន្ធអាចបិទគ្រឹះស្ថានអាជីវកម្មនោះក្នុងរយៈពេលមានកំណត់មួយដែលមិនលើសពី៧(ប្រាំពីរ)ថ្ងៃ។

២- ប្រសិនបើគ្រឹះស្ថានអាជីវកម្មណាមួយដែលធ្លាប់ត្រូវបានបិទដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ នៅតែប្រព្រឹត្តអំពើល្មើសបែបនោះជាថ្មីទៀត គ្រឹះស្ថានអាជីវកម្មនោះអាចត្រូវបានបិទជាថ្មីទៀតក្នុងរយៈពេលមានកំណត់មួយដែលមិនលើសពី៧(ប្រាំពីរ)ថ្ងៃ។

**មាត្រា៨០ .-** បញ្ជី កំណត់ត្រា និងព័ត៌មាន

បញ្ជី កំណត់ត្រា និងព័ត៌មានសម្រាប់អាករលើតម្លៃបន្ថែម ត្រូវបានកំណត់ដូចខាងក្រោម៖

១- បុគ្គលជាប់អាករ ត្រូវប្រើប្រាស់ប្រព័ន្ធកត់ត្រាសាច់ប្រាក់ដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ និងត្រូវរក្សាទុកនូវច្បាប់ចម្លងវិក្កយបត្រទាំងអស់ដែលបានចេញនិងវិក្កយបត្រទាំងអស់ដែលបានទទួល។

២- បុគ្គលជាប់អាករ ត្រូវកត់ត្រានិងរក្សាទុកឱ្យបានត្រឹមត្រូវនូវបញ្ជីកំណត់ត្រានៃរាល់កិច្ចការជំនួញដែលបានធ្វើ ហើយត្រូវមានគណនីតាមដានទឹកប្រាក់អាករដែលបានប្រមូលលើការលក់និងទឹកប្រាក់អាករដែលបានបង់លើការទិញនានារបស់ខ្លួន ព្រមទាំងសេចក្ដីកែតម្រូវផ្សេងៗលើតម្លៃលក់ឬទឹកប្រាក់អាករទៅតាមបែបបទដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ។

៣- កិច្ចការដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រានេះ ត្រូវធ្វើប្រចាំថ្ងៃ ហើយត្រូវធ្វើការបូកសរុប និងគណនាសមតុល្យនៅដំណាច់ខែនីមួយៗ។ បុគ្គលជាប់អាករត្រូវធ្វើជារៀងរាល់ខែនូវសម្រង់អាករលើតម្លៃបន្ថែមទៅតាមបែបបទកំណត់ដោយរដ្ឋបាលសារពើពន្ធ។

៤- វិក្កយបត្រ កំណត់ត្រា និងឯកសារផ្សេងទៀត ដែលជាប់ទាក់ទិននឹងអាករនេះ ត្រូវរក្សាទុកតាមលំដាប់ថ្ងៃខែ តាមបែបបទ និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់ក្នុងរយៈពេល១០(ដប់)ឆ្នាំក្រោយការបញ្ចប់កិច្ចការជំនួញចុងក្រោយបំផុតដែលជាប់ទាក់ទិននឹងឯកសារទាំងនេះ។

៥- ប្រព័ន្ធកត់ត្រាសាច់ប្រាក់ ឯកសារ និងកំណត់ត្រាទាំងអស់ដែលត្រូវរក្សាទុកតាមមាត្រានេះ ព្រមទាំងឯកសារនិងកំណត់ត្រាឯទៀតដែលទាក់ទិននឹងអាជីវកម្មរបស់បុគ្គល ត្រូវផ្ដល់ឱ្យរដ្ឋបាលសារពើពន្ធត្រួតពិនិត្យនៅពេលមានការស្នើសុំ។


https://www.moj.gov.kh/kh/law-regular

**មាត្រា៨១ .-** វិធានពិសេសសម្រាប់ការនាំចូល

បទប្បញ្ញត្តិនានានៃជំពូកនេះដែលទាក់ទិននឹងការនាំចូល ត្រូវគ្រប់គ្រងដោយរដ្ឋបាលគយទៅតាមច្បាប់ស្តីពីគយ។

**មាត្រា៨២ .-** ការបញ្ឈប់អាជីវកម្មនិងការផ្ទេរអាជីវកម្ម

វិធាននៃការបញ្ឈប់អាជីវកម្មនិងការផ្ទេរអាជីវកម្មត្រូវបានកំណត់ដូចខាងក្រោម៖

១- ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ក្រោយការបញ្ឈប់អាជីវកម្ម បុគ្គលជាប់អាករត្រូវដាក់លិខិតប្រកាសជូនរដ្ឋបាលសារពើពន្ធតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់ ដោយភ្ជាប់មកជាមួយនូវព័ត៌មានលម្អិតអំពីការលក់និងការទិញនានា ក្រោយពីការប្រកាសសារពើពន្ធចុងក្រោយបំផុត និងព័ត៌មានលម្អិតអំពីទំនិញទាំងអស់នៅក្នុងស្តុកដែលមិនទាន់បង់អាករឬដែលបានទទួលឥណទានអាកររួចហើយ ព្រមទាំងបង់ប្រាក់អាករដល់កំណត់ទាំងនោះ។

២- ការផ្ទេរអាជីវកម្មពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត មិនត្រូវជាប់អាករលើតម្លៃបន្ថែមទេ។

៣- វិធាននិងនីតិវិធីសម្រាប់ការបញ្ឈប់និងការផ្ទេរអាជីវកម្មត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៨៣ .-** ឥណទានអាករសម្រាប់ទំនិញស្តុកចំពោះបុគ្គលចុះបញ្ជីថ្មី

ឥណទានអាករចំពោះទំនិញស្តុកត្រូវបានកំណត់ដូចខាងក្រោម៖

១- ចំពោះបុគ្គលទើបបានចុះបញ្ជី ហើយនៅថ្ងៃចុះបញ្ជីនោះមានស្តុកទំនិញដែលបានបង់អាករលើតម្លៃបន្ថែមរួចហើយ បុគ្គលនោះអាចដាក់ពាក្យសុំឱ្យរដ្ឋបាលសារពើពន្ធអនុញ្ញាតនូវឥណទានអាករ ចំពោះប្រាក់អាករដែលបានបង់លើស្តុកទាំងនោះ បន្ទាប់ពីរដ្ឋបាលសារពើពន្ធបានត្រួតពិនិត្យឃើញថា វិក្កយបត្រឬច្បាប់ចម្លងនៃប្រតិវេទន៍គយរបស់ទំនិញទាំងនោះមានលក្ខណៈត្រឹមត្រូវ។

២- បើមានការឯកភាពចំពោះលក្ខណៈត្រឹមត្រូវនៃឯកសារទាំងនោះហើយ រដ្ឋបាលសារពើពន្ធអាចអនុញ្ញាតនូវឥណទានអាករចំពោះការផ្គត់ផ្គង់ដែលបានធ្វើក្នុងអំឡុងពេល៦០(ហុកសិប)ថ្ងៃ មុនថ្ងៃចុះបញ្ជី។ ឥណទានអាករនេះអាចយកទៅប្រើក្នុងការប្រកាសសារពើពន្ធទាំងឡាយសម្រាប់អាករនេះ ទៅតាមលក្ខខណ្ឌដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ។

**មាត្រា៨៤ .-** វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលអាករ

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលអាករលើតម្លៃបន្ថែមត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



https://www.moj.gov.kh/kh/law-regular

# ជំពូកទី៥
# អាករពិសេស

**មាត្រា៨៥ .-** កម្មវត្ថុនៃអាករ

អាករពិសេសត្រូវអនុវត្តលើទំនិញឬសេវាមួយចំនួនដែលមានលក្ខណៈប្រណីត ឬមិនមែនជាតម្រូវការចាំបាច់ក្នុងជីវភាពប្រចាំថ្ងៃ ឬប៉ះពាល់ដល់សុខភាព សង្គម ឬបរិស្ថាន។

**មាត្រា៨៦ .-** វិសាលភាពនៃអាករ

អាករពិសេសអនុវត្តលើការនាំចូល ការផលិត ឬការចែកចាយទំនិញ ឬការផ្គត់ផ្គង់សេវាដែលជាប់អាករពិសេសសម្រាប់ប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៨៧ .-** និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងជំពូកនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- បុគ្គលជាប់អាករពិសេស សំដៅដល់ អ្នកនាំចូល ឬអ្នកផលិតទំនិញ ឬអ្នកផ្គត់ផ្គង់សេវាជាប់អាករពិសេស។

២- ការនាំចូល សំដៅដល់ សកម្មភាពនាំចូលទំនិញមកក្នុងដែនគយនៃព្រះរាជាណាចក្រកម្ពុជាដោយបុគ្គលណាមួយ។

៣- អ្នកនាំចូល សំដៅដល់ បុគ្គលណាមួយដែលធ្វើការនាំចូលដោយខ្លួនឯងឬដោយបុគ្គលដទៃ។ សម្រាប់គោលដៅនៃកថាខណ្ឌនេះ អ្នកទទួលទំនិញ បុគ្គលជាម្ចាស់កម្មសិទ្ធិ បុគ្គលដែលនឹងទៅជាម្ចាស់កម្មសិទ្ធិ ឬអ្នកមានសិទ្ធិចាត់ចែងលើកម្មសិទ្ធិទំនិញមុនពេលដែលទំនិញនោះឈប់ជាកម្មវត្ថុនៃការត្រួតពិនិត្យគយ ត្រូវបានចាត់ទុកថាជាអ្នកនាំចូលដែរ។

៤- ការផលិត សំដៅដល់ សកម្មភាពបំប្លែងវត្ថុធាតុដើម ផ្គុំ ដំឡើង វេចខ្ចប់ ប្រកបំពេញឱ្យទៅជាផលិតផលពាក់កណ្តាលសម្រេចឬផលិតផលសម្រេច។

៥- អ្នកផលិត សំដៅដល់ បុគ្គលណាមួយដែលធ្វើការផលិតទំនិញ ឬបុគ្គលណាមួយដែលជួលបុគ្គលដទៃទៀតផលិតទំនិញឱ្យខ្លួន។

៦- អ្នកចែកចាយ សំដៅដល់ បុគ្គលដែលធ្វើការផ្គត់ផ្គង់ទំនិញដែលនាំចូល ឬផលិតដោយខ្លួនឯង ឬទិញបន្តពីអ្នកនាំចូលឬពីអ្នកផលិត។

៧- ការផ្គត់ផ្គង់ សំដៅដល់ ការលក់ ឬការដកយកមកប្រើប្រាស់ផ្ទាល់ខ្លួន ឬការផ្តល់ជាអំណោយ ឬលក់ក្រោមតម្លៃពិតនូវទំនិញឬសេវាដោយបុគ្គលជាប់អាករពិសេស។

៨- តែមប្រើអាករ សំដៅដល់ សន្លឹកតែមប្រើសម្រាប់បិទលើទំនិញជាប់អាករពិសេសដើម្បីបញ្ជាក់ថាបានបង់អាករពិសេស។

៩- អាករ ក្នុងជំពូកនេះ សំដៅដល់ អាករពិសេស។



https://www.moj.gov.kh/kh/law-regular

**មាត្រា៨៨ ._** ទំនិញឬសេវាជាប់អាករពិសេស

ដោយមិនកំណត់ត្រឹមតែដូចខាងក្រោមនេះ ទំនិញឬសេវាដែលជាប់អាករពិសេស៖

១- ទំនិញមួយចំនួនមានជាអាទិ៍៖

ក- ផលិតផលតេលសិលា៖

- ប្រេងសាំង
- ប្រេងម៉ាស៊ូត
- ប្រេងសាំងយន្តហោះ
- ប្រេងរំអិល។

ខ- ភេសជ្ជៈ៖

- ភេសជ្ជៈគ្មានជាតិសុរា មានជាអាទិ៍ ភេសជ្ជៈដែលមានជាតិឧស្ម័ន មានដាក់ស្ករ ឬសារជាតិផ្អែម ឬក្លិនផ្សេងៗ និងភេសជ្ជៈគ្មានជាតិសុរាដទៃទៀត លើកលែងតែទឹកនិងទឹករ៉ែ ទឹកដោះគោ និងទឹកដមផ្លែឈើឬបន្លែ
- ស្រា
- ស្រាបៀរ
- ភេសជ្ជៈមេវ៉ែផ្សេងទៀត។

គ- បារី បារីស៊ីហ្គា និងបារីគ្រប់ប្រភេទ។

ឃ- គ្រឿងអេឡិចត្រូនិក។

ង- ទោចក្រយានយន្ត។

ច- រថយន្ត។

ឆ- គ្រឿងបន្លាស់យានយន្ត។

ជ- ផលិតផលប្លាស្ទិក។

ឈ- ផលិតផលគ្រឿងសម្អាង។

ញ- ផលិតផលកញ្ចក់ជាគ្រឿងសំណង់។

ដ- ស៊ីម៉ងត៍។

២- សេវាមួយចំនួនមានជាអាទិ៍៖

ក- សេវាទូរគមនាគមន៍។

ខ- សេវាដឹកជញ្ជូនអ្នកដំណើរផ្លូវអាកាស។

គ- សេវាលំហែកម្សាន្ត។

៣- រាជរដ្ឋាភិបាលអាចចេញអនុក្រឹត្យកំណត់បន្ថែមឬព្យួរនូវមុខទំនិញឬសេវាជាប់អាករពិសេសតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៨៩ ._** អត្រាអាករពិសេស

១- អត្រាអាករពិសេសត្រូវកំណត់ជាអត្រាភាគរយលើតម្លៃទំនិញឬសេវាដែលជាមូលដ្ឋានគិតអាករពិសេស ឬជាតម្លៃកំណត់ទៅលើទម្ងន់ ចំណុះ ទំហំ ឬបរិមាណ។

២- អត្រាអាករពិសេសត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



https://www.moj.gov.kh/kh/law-regular

**មាត្រា៩០ ._** មូលដ្ឋានគិតអាករពិសេស

មូលដ្ឋានគិតអាករពិសេសត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៩១ ._** វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលអាករ

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលអាករពិសេសត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៦
## អាករសម្រាប់បំភ្លឺសាធារណៈ

**មាត្រា៩២ ._** កម្មវត្ថុនៃអាករ

អាករសម្រាប់បំភ្លឺសាធារណៈត្រូវអនុវត្តលើការផ្គត់ផ្គង់ផលិតផលសុរា មេរ៉ៃ ឬថ្នាំជក់។

**មាត្រា៩៣ ._** វិសាលភាពនៃអាករ

អាករសម្រាប់បំភ្លឺសាធារណៈអនុវត្តលើការផ្គត់ផ្គង់នូវផលិតផលសុរា មេរ៉ៃ ឬថ្នាំជក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៩៤ ._** និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងជំពូកនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១_ សុរា សំដៅដល់ ផលិតផលគ្រប់ប្រភេទដែលមានជាតិអាល់កុល។

២_ មេរ៉ៃ សំដៅដល់ ទឹកស្រវឹងដែលធ្វើឡើងដោយការត្រាំគ្រឿងផ្សំផ្សេងៗ ដែលមានជាអាទិ៍ ស្រាបៀរ ឬភេសជ្ជៈមានជាតិស្រវឹង។

៣_ ថ្នាំជក់ សំដៅដល់ ផលិតផលទាំងមូលឬមួយផ្នែកដែលធ្វើដោយស្លឹកថ្នាំជក់ជាវត្ថុធាតុដើម ហើយដែលផលិតសម្រាប់យកទៅជក់។

៤_ អាករ ក្នុងជំពូកនេះ សំដៅដល់ អាករសម្រាប់បំភ្លឺសាធារណៈ។

**មាត្រា៩៥ ._** អត្រាអាករ

អត្រាអាករសម្រាប់បំភ្លឺសាធារណៈត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៩៦ ._** មូលដ្ឋានគិតអាករ

មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៩៧ ._** ពេលផ្គត់ផ្គង់

១_ អាករសម្រាប់បំភ្លឺសាធារណៈត្រូវកំណត់និងត្រូវបង់នៅពេលផ្គត់ផ្គង់ដំបូង។

២_ វិធាននៃការផ្គត់ផ្គង់ត្រូវអនុវត្តស្របតាមវិធាននៃការផ្គត់ផ្គង់សម្រាប់អាករលើតម្លៃបន្ថែមដូចមានចែងក្នុងកថាខណ្ឌទី១ ដល់កថាខណ្ឌទី៤នៃមាត្រា៦១នៃច្បាប់នេះ។



https://www.moj.gov.kh/kh/law-regular

**មាត្រា៩៨ .–** កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់អាករ

បុគ្គលជាប់អាករត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់អាករសម្រាប់បំភ្លឺសាធារណៈជារៀងរាល់ខែយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ពីខែដែលផលិតផលត្រូវបានផ្គត់ផ្គង់។

**មាត្រា៩៩ .–** វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលអាករ

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលអាករសម្រាប់បំភ្លឺសាធារណៈត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៧
## អាករលើការស្នាក់នៅ

**មាត្រា១០០ .–** កម្មវត្ថុនៃអាករ

អាករលើការស្នាក់នៅត្រូវអនុវត្តលើការផ្គត់ផ្គង់សេវាស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១០១ .–** វិសាលភាពនៃអាករ

អាករលើការស្នាក់នៅអនុវត្តលើការផ្គត់ផ្គង់សេវាស្នាក់នៅក្នុងសណ្ឋាគារក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១០២ .–** និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងជំពូកនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោមៈ

១_សណ្ឋាគារ សំដៅដល់ ទីកន្លែងផ្គត់ផ្គង់សេវាស្នាក់នៅមានលក្ខណៈជាបន្ទប់ គ្រែ និងមានផ្តល់នូវសម្បទានិងសេវាផ្សេងៗទៀតទៅតាមប្រភេទទីកន្លែងផ្តល់សេវាស្នាក់នៅនីមួយៗ ដូចជា សណ្ឋាគារ សណ្ឋាគារអាផាតម៉ិន សណ្ឋាគារស្វីត សណ្ឋាគាររីសត ម៉ូតែល ឡូដ បឹងកាឡូ ផ្ទះសំណាក់ឬផ្ទះភ្ញៀវ កន្លែងបោះជំរំទេសចរណ៍ និងទីកន្លែងផ្តល់សេវាស្នាក់នៅដទៃទៀតដែលមានលក្ខណៈប្រហាក់ប្រហែល ទោះបីជាដាក់ឈ្មោះថាជាអ្វីក៏ដោយ។ ពាក្យ **សណ្ឋាគារ** មិនរួមបញ្ចូលផ្ទះជួល ឬផ្ទះល្វែងជួលរយៈពេលខ្លីនិងរយៈពេលវែងទេ។

២_អាករ ក្នុងជំពូកនេះ សំដៅដល់ អាករលើការស្នាក់នៅ។

**មាត្រា១០៣ .–** អត្រាអាករ

អាករលើការស្នាក់នៅត្រូវកំណត់តាមអត្រា២(ពីរ)ភាគរយ។

**មាត្រា១០៤ .–** មូលដ្ឋានគិតអាករ

មូលដ្ឋានគិតអាករលើការស្នាក់នៅ គឺជាថ្លៃស្នាក់នៅ រួមបញ្ចូលទាំងបន្ទុកផ្សេងៗ ព្រមទាំងពន្ធអាករនានា លើកលែងតែអាករលើតម្លៃបន្ថែមនិងអាករលើការស្នាក់នៅខ្លួនឯង។

**មាត្រា១០៥ .–** ពេលផ្គត់ផ្គង់

វិធាននៃការផ្គត់ផ្គង់សេវាស្នាក់នៅត្រូវអនុវត្តស្របតាមវិធាននៃការផ្គត់ផ្គង់សេវាសម្រាប់អាករលើតម្លៃបន្ថែម ដូចមានចែងក្នុងមាត្រា៦១នៃច្បាប់នេះ។



https://www.moj.gov.kh/kh/law-regular

**មាត្រា១០៦ .-** កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់អាករ

បុគ្គលជាប់អាករត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់អាករលើការស្នាក់នៅជារៀងរាល់ខែយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ពីខែដែលសេវាស្នាក់នៅត្រូវបានផ្តត់ផ្គង់។

**មាត្រា១០៧ .-** វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលអាករ

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលអាករលើការស្នាក់នៅត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៨
## ពន្ធប៉ាតង់

**មាត្រា១០៨ .-** កម្មវត្ថុនៃពន្ធ

ពន្ធប៉ាតង់ គឺជាពន្ធប្រចាំឆ្នាំដែលត្រូវបានកំណត់លើសកម្មភាពអាជីវកម្មនីមួយៗរបស់អ្នកជាប់ពន្ធដោយផ្អែកលើប្រភេទអ្នកជាប់ពន្ធនិងកម្រិតផលរបរ។

**មាត្រា១០៩ .-** វិសាលភាពនៃពន្ធ

ពន្ធប៉ាតង់អនុវត្តលើអ្នកជាប់ពន្ធដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១១០ .-** ការលើកលែងពន្ធ

ពន្ធប៉ាតង់ត្រូវបានលើកលែងដូចខាងក្រោម៖

១- ស្ថាប័នរដ្ឋ បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត។

២- សកម្មភាពរបស់អង្គការណាមួយដែលត្រូវបានរៀបចំឡើង និងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬអប់រំ និងគ្មានចំណែកណាមួយនៃទ្រព្យឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជន។

៣- គ្រប់សកម្មភាពអាជីវកម្មដែលមានផលរបរប្រចាំឆ្នាំក្រោមកម្រិតផលរបរអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដូចមានកំណត់ក្នុងមាត្រា៦នៃច្បាប់នេះ។

**មាត្រា១១១ .-** អត្រាពន្ធ

អត្រាពន្ធប៉ាតង់ត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១១២ .-** កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ

១- ពន្ធប៉ាតង់ត្រូវបង់ក្នុងអំឡុងពេលចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ។

២- អ្នកជាប់ពន្ធដែលចាប់ផ្តើមប្រកបអាជីវកម្មក្នុងរយៈពេល៦(ប្រាំមួយ)ខែដើមឆ្នាំ ត្រូវបង់ប្រាក់ពន្ធប៉ាតង់ពេញមួយឆ្នាំ ប៉ុន្តែប្រសិនបើចាប់ផ្តើមប្រកបអាជីវកម្មក្នុងរយៈពេល៦(ប្រាំមួយ)ខែចុងឆ្នាំ អ្នកជាប់ពន្ធត្រូវបង់ប្រាក់ពន្ធប៉ាតង់ពាក់កណ្តាល។


https://www.moj.gov.kh/kh/law-regular

**មាត្រា១១៣ ._** សកម្មភាពនិងទីកន្លែងប្រកបអាជីវកម្មជាប់ពន្ធ

សកម្មភាពនិងទីកន្លែងប្រកបអាជីវកម្មជាប់ពន្ធត្រូវកំណត់ដូចខាងក្រោម៖

១_ អ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មច្រើន ត្រូវបង់ពន្ធប៉ាតង់ផ្សេងគ្នាទៅតាមសកម្មភាពអាជីវកម្មនីមួយៗ។

២_ សកម្មភាពជាឧបសម្ព័ន្ធនានានៃសកម្មភាពអាជីវកម្ម ត្រូវបានចាត់ទុកថាជាសកម្មភាពអាជីវកម្មតែមួយ។

៣_ អ្នកជាប់ពន្ធដែលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់មុខរបរអាជីវកម្មតែមួយនៅក្នុងរាជធានី ខេត្តតែមួយ ត្រូវបង់ពន្ធប៉ាតង់តែមួយ។

៤_ អ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មនៅក្នុងរាជធានី ខេត្តផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់ទៅតាមរាជធានី ខេត្តដែលអាជីវកម្មនោះស្ថិតនៅ។

៥_ អ្នកជាប់ពន្ធដែលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់សកម្មភាពអាជីវកម្មតែមួយដែលស្ថិតនៅតាមរាជធានី ខេត្តផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់អប្បបរមាសម្រាប់ប្រភេទអ្នកជាប់ពន្ធនីមួយៗ ទៅតាមរាជធានី ខេត្តដែលអាជីវកម្មនោះស្ថិតនៅ។

៦_ ករណីមានការផ្លាស់ប្តូរទីកន្លែងទៅរាជធានី ខេត្តផ្សេង ឬផ្លាស់ប្តូរសកម្មភាពអាជីវកម្មថ្មី ត្រូវបង់ប្រាក់ពន្ធប៉ាតង់ថ្មីម្តងទៀត។

**មាត្រា១១៤ ._** បណ្ណពន្ធប៉ាតង់

១_ រដ្ឋបាលសារពើពន្ធត្រូវចេញបណ្ណពន្ធប៉ាតង់ជូនអ្នកជាប់ពន្ធបន្ទាប់ពីប្រាក់ពន្ធប៉ាតង់ត្រូវបានបង់រួចរាល់។

២_ អ្នកជាប់ពន្ធមានកាតព្វកិច្ចដាក់តាំងបង្ហាញបណ្ណពន្ធប៉ាតង់ដែលមានសុពលភាពនៅតាមទីតាំងប្រកបអាជីវកម្មរបស់ខ្លួន។

**មាត្រា១១៥ ._** វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ

វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៩
## ពន្ធលើផ្ទាំងផ្សព្វផ្សាយ

**មាត្រា១១៦ ._** កម្មវត្ថុនៃពន្ធ

ពន្ធលើផ្ទាំងផ្សព្វផ្សាយត្រូវអនុវត្តលើផ្ទាំងផ្សព្វផ្សាយគ្រប់ប្រភេទ។

**មាត្រា១១៧ ._** វិសាលភាពនៃពន្ធ

ពន្ធលើផ្ទាំងផ្សព្វផ្សាយអនុវត្តលើការផ្សព្វផ្សាយតាមគ្រប់រូបភាពទាំងចល័តនិងអចល័តនៅក្នុងព្រះរាជាណាចក្រកម្ពុជា។



https://www.moj.gov.kh/kh/law-regular

**មាត្រា១១៨ .-** និយមន័យ

សម្រាប់គោលដៅនៃបទប្បញ្ញត្តិស្តីពីពន្ធលើផ្ទាំងផ្សព្វផ្សាយ ពាក្យ **ផ្ទាំងផ្សព្វផ្សាយ** សំដៅដល់៖

១- បណ្ណប្រកាសផ្សាយពាណិជ្ជកម្មធ្វើឡើងដោយកៅស៊ូ ក្រដាសធម្មតា កំណាត់ ឬវត្ថុផ្សេងៗ។

២- ស្លាកអាជីវកម្មដ្ឋានសម្រាប់ដាក់សម្គាល់ឈ្មោះ ទីតាំង ទីស្នាក់ការ ការិយាល័យ ឬទីកន្លែងប្រកបអាជីវកម្មនានា។

៣- ផ្ទាំងអក្សរ ឬផ្ទាំងរូបភាពសម្រាប់គោលបំណងពាណិជ្ជកម្ម។

**មាត្រា១១៩ .-** ការលើកលែងពន្ធ

ពន្ធលើផ្ទាំងផ្សព្វផ្សាយត្រូវបានលើកលែងចំពោះផ្ទាំងផ្សព្វផ្សាយក្នុងគោលបំណងមិនស្វែងរកប្រាក់ចំណេញដូចខាងក្រោម៖

១- ស្លាករបស់ស្ថាប័នរដ្ឋ។

២- ស្លាករបស់ស្ថានទូតឬស្ថានកុងស៊ុលបរទេស អង្គការជាតិនិងអង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត អង្គការមិនមែនរដ្ឋាភិបាលនិងសមាគមនានា។

៣- ផ្ទាំងផ្សព្វផ្សាយដែលមានគោលដៅអប់រំសង្គមជាប្រយោជន៍សាធារណៈ មានជាអាទិ៍ការថែរក្សានិងការពារបរិស្ថាន ការបញ្ឈប់អំពើហិង្សាក្នុងគ្រួសារ ការការពារធនធានធម្មជាតិ ការអប់រំចរាចរណ៍ និងការអប់រំសុខភាព។

**មាត្រា១២០ .-** អត្រាពន្ធនិងមូលដ្ឋានគិតពន្ធ

អត្រាពន្ធនិងមូលដ្ឋានគិតពន្ធលើផ្ទាំងផ្សព្វផ្សាយត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១២១ .-** កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ

ពន្ធលើផ្ទាំងផ្សព្វផ្សាយត្រូវបង់ក្នុងអំឡុងពេលចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ។

**មាត្រា១២២ .-** ការខកខានមិនបានដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ

ប្រសិនបើអ្នកជាប់ពន្ធមិនបានបង់ពន្ធលើផ្ទាំងផ្សព្វផ្សាយដូចមានចែងក្នុងជំពូកនេះ អាជ្ញាធរមានសមត្ថកិច្ចមិនត្រូវចេញលិខិតអនុញ្ញាតទាក់ទិននឹងស្លាកឬផ្ទាំងផ្សព្វផ្សាយដែលមិនទាន់បានបង់ពន្ធលើផ្ទាំងផ្សព្វផ្សាយឡើយ។

**មាត្រា១២៣ .-** វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើផ្ទាំងផ្សព្វផ្សាយត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



https://www.moj.gov.kh/kh/law-regular

## ជំពូកទី១០
## ពន្ធលើប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែ
## ផ្នែកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១២៤ .-** កម្មវត្ថុនៃពន្ធ

ពន្ធលើប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែអនុវត្តលើការធ្វើប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១២៥ .-** វិសាលភាពនៃពន្ធ

បទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែអនុវត្តលើប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែនៅក្នុងបូរណភាពទឹកដីនិងអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា រួមទាំងបាតសមុទ្រនិងស្រទាប់ដីក្រោមបាតសមុទ្រនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខនិងតំបន់ខ្ពង់រាបបាតសមុទ្រ ព្រមទាំងតំបន់ផ្សេងៗទៀតដែលព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិអធិបតេយ្យ។

**មាត្រា១២៦ .-** និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងជំពូកនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- សម្រាប់គោលដៅនៃប្រតិបត្តិការប្រេងកាត៖

ក- ប្រេងកាត សំដៅដល់ ប្រេងឆៅ ឧស្ម័នធម្មជាតិ និងអ៊ីដ្រូកាបួផ្សេងទៀត ទោះបីជាស្ថិតក្នុងសភាពរឹង រាវ ឧស្ម័ន ស្ថានភាពធម្មជាតិ និងរាល់សារធាតុផ្សេងទៀតដែលជាសមាសធាតុផ្សំជាមួយអ៊ីដ្រូកាបួនោះ។

ខ- កិច្ចព្រមព្រៀងប្រេងកាត សំដៅដល់ កិច្ចសន្យាបែងចែកផលប្រេងកាត ឬទម្រង់កិច្ចសន្យាណាមួយដែលត្រូវបានផ្តល់ឱ្យក្រោមច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត និងបទប្បញ្ញត្តិពាក់ព័ន្ធរវាងរាជរដ្ឋាភិបាលកម្ពុជានិងអ្នកជាប់ពន្ធពាក់ព័ន្ធ ដើម្បីធ្វើប្រតិបត្តិការប្រេងកាត។

គ- ប្រតិបត្តិការប្រេងកាត សំដៅដល់ រាល់សកម្មភាពស្វែងរុករក អភិវឌ្ឍ និងផលិតប្រេងកាតដែលបានធ្វើឡើងនៅក្នុងតំបន់ចុះកិច្ចព្រមព្រៀងប្រេងកាត ស្របតាមកិច្ចព្រមព្រៀងប្រេងកាត។

ឃ- តំបន់ចុះកិច្ចព្រមព្រៀង សំដៅដល់ តំបន់ដែលជាកម្មវត្ថុនៃកិច្ចព្រមព្រៀងប្រេងកាត ដែលបានអនុញ្ញាតផ្តល់ឱ្យពីដំបូង រួមបញ្ចូលទាំងផ្នែកណាមួយនៃតំបន់នោះដែលត្រូវបានប្រគល់សងវិញ ដោយអនុលោមទៅតាមកិច្ចព្រមព្រៀងប្រេងកាត។

ង- គម្រោងអភិវឌ្ឍន៍ សំដៅដល់ ផែនការអភិវឌ្ឍន៍ កម្មវិធីការងារអភិវឌ្ឍន៍ និងសកម្មភាពការងារអភិវឌ្ឍន៍នានា ដើម្បីអភិវឌ្ឍនិងធ្វើផលិតកម្មប្រេងកាតនៅក្នុងតំបន់ចុះកិច្ចព្រមព្រៀងដែលបានយល់ព្រមដោយស្ថាប័ន។


https://www.moj.gov.kh/kh/law-regular

ច_ ផែនការបិទការដ្ឋាននិងស្ដារបរិស្ថានឡើងវិញ សំដៅដល់ ផែនការបិទការដ្ឋាននិងស្ដារបរិស្ថានឡើងវិញរបស់អ្នកជាប់ពន្ធដែលបានយល់ព្រមដោយស្ថាប័នក្រោមកិច្ចព្រមព្រៀងប្រេងកាត ស្របតាមច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត។

ឆ_ ចំណាយបុរេសនា សំដៅដល់ ចំណាយក្នុងការស្វែងរុករកដើម្បីកំណត់សក្ដានុពលភូគព្ភសាស្ត្រប្រេងកាតដំហានដំបូងដោយមិនមានសិទ្ធិធ្វើការអភិវឌ្ឍនិងផលិតកម្ម។

ជ_ ចំណាយស្វែងរុករក សំដៅដល់ ចំណាយក្នុងការអង្កេតផ្នែកភូគព្ភសាស្ត្រ សិលាវិទ្យារូបភូគព្ភសាស្ត្រ គីមីភូគព្ភសាស្ត្រ ឋានលេខា ចំណាយវិភាគទិន្នន័យ ចំណាយទស្សនាទានវិស្វកម្មមុនពេលអភិវឌ្ឍន៍ ចំណាយលើការខួងស្វែងរុករក ខួងវាយតម្លៃ ការសិក្សាលើសមិទ្ធិលទ្ធភាព ផលប៉ះពាល់បរិស្ថាន ចំណាយរដ្ឋបាលទូទៅ និងចំណាយផ្សេងៗទៀតដែលកើតឡើងនៅក្នុងប្រតិបត្តិការប្រេងកាត ដើម្បីកំណត់វត្តមាន ទីតាំង បរិមាណ និងគុណភាពនៃជម្រកធនធានប្រេងកាត។

ឈ_ ចំណាយអភិវឌ្ឍន៍ សំដៅដល់ ចំណាយដែលបានកើតឡើងបន្ទាប់ពីស្ថាប័នបានយល់ព្រមចំពោះគម្រោងអភិវឌ្ឍន៍ ដើម្បីសាងសង់មធ្យោបាយផលិតកម្មសម្រាប់ប្រតិបត្តិការប្រេងកាតមានជាអាទិ៍ការរៀបចំទីតាំង ការខួងអណ្ដូង ការសាងសង់អណ្ដូងសម្រាប់ផលិតកម្ម និងការសាងសង់បំពង់បង្ហូរប្រេងកាតដែលជាមធ្យោបាយផលិតកម្ម ការចំណាយលើការទិញទ្រព្យរូបីនិងទ្រព្យអរូបី ព្រមទាំងសកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងការអភិវឌ្ឍរបស់អ្នកចុះកិច្ចព្រមព្រៀងប្រេងកាត ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងលិខិតអនុញ្ញាតផលិតកម្មចេញដោយស្ថាប័ន។

ញ_ ប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋាននិងស្ដារបរិស្ថានឡើងវិញ សំដៅដល់ ប្រាក់បម្រុងដែលត្រូវបានអនុញ្ញាតឱ្យកាត់កងជាមុនសម្រាប់ចំណាយបិទការដ្ឋាននិងស្ដារបរិស្ថានឡើងវិញស្របតាមផែនការនិងលក្ខខណ្ឌកំណត់ដោយស្ថាប័ន។

ដ_ ចំណាយសរុបសម្រាប់បិទការដ្ឋាននិងស្ដារបរិស្ថានឡើងវិញ សំដៅដល់ ចំណាយសរុបសម្រាប់បិទការដ្ឋាននិងស្ដារបរិស្ថានឡើងវិញនៅក្នុងតំបន់ចុះកិច្ចព្រមព្រៀងដែលបានយល់ព្រមដោយស្ថាប័នតាមគម្រោងបិទការដ្ឋាននិងស្ដារបរិស្ថានឡើងវិញរបស់អ្នកជាប់ពន្ធស្របតាមកិច្ចព្រមព្រៀងប្រេងកាត។

ឋ_ ពេលចាប់ផ្ដើមផលិតកម្មពាណិជ្ជកម្ម សំដៅដល់ ពេលដែលអ្នកជាប់ពន្ធចាប់ផ្ដើមធ្វើផលិតកម្មពាណិជ្ជកម្មស្របតាមការកំណត់ក្នុងកិច្ចព្រមព្រៀងប្រេងកាតឬការកំណត់ដោយស្ថាប័ន។

២_ សម្រាប់គោលដៅនៃប្រតិបត្តិការធនធានរ៉ែ៖

ក_ ធនធានរ៉ែ សំដៅដល់ សារធាតុទាំងឡាយ ទោះបីជាក្នុងទម្រង់រឹង រាវ ឧស្ម័ន ដែលកកើតឡើងដោយធម្មជាតិតាមដំណើរវិវត្តភូគព្ភសាស្ត្រ ឬជាលទ្ធផលនៃការជីកយកពីក្នុងដីលើដី ក្នុងសមុទ្រ ក្រោមបាតសមុទ្រ មានជាអាទិ៍ ត្បូងថ្ម ធ្យូងថ្ម រ៉ែអលោហៈ រ៉ែលោហៈ ទឹកខនិជ ថ្ម ក្រួស ខ្សាច់ និងដីឥដ្ឋ។ ពាក្យ **ធនធានរ៉ែ** មិនរាប់បញ្ចូលប្រេងកាតដូចមានចែងក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌទី១នៃមាត្រានេះទេ។



https://www.moj.gov.kh/kh/law-regular

ខ_ អាជ្ញាបណ្ណធនធានរ៉ែ សំដៅដល់ លិខិតអនុញ្ញាតដែលផ្តល់សិទ្ធិឱ្យអ្នកជាប់ពន្ធ ដោយស្ថាប័នដើម្បីធ្វើប្រតិបត្តិការធនធានរ៉ែ។

គ_ ប្រតិបត្តិការធនធានរ៉ែ សំដៅដល់ សកម្មភាពទាំងឡាយដែលបានអនុញ្ញាតក្រោមលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណធនធានរ៉ែ។ ប្រតិបត្តិការធនធានរ៉ែត្រូវបានបែងចែកជាដំណាក់កាលបុរេសនា ដំណាក់កាលស្វែងរុករក និងដំណាក់កាលអាជីវកម្មធនធានរ៉ែ។

ឃ_ ដែនអាជ្ញាបណ្ណ សំដៅដល់ ដែនដែលត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការធនធានរ៉ែនិងជាកម្មវត្ថុនៃអាជ្ញាបណ្ណ រួមបញ្ចូលទាំងផ្នែកណាមួយនៃដែនដែលត្រូវបានបោះបង់ចោលដោយអនុលោមទៅតាមអាជ្ញាបណ្ណធនធានរ៉ែនោះ។

ង_ ផែនការបិទការដ្ឋានរ៉ែនិងការស្តារបរិស្ថានឡើងវិញ សំដៅដល់ ផែនការស្តារបរិស្ថានរបស់អ្នកជាប់ពន្ធដែលបានយល់ព្រមដោយស្ថាប័នក្រោមអាជ្ញាបណ្ណធនធានរ៉ែ។ ការស្តារការដ្ឋានរួមបញ្ចូលទាំងការលុបអណ្តូងរ៉ែ ការដាំដើមឈើឡើងវិញ ការសម្អាតនានាក្នុងដែនអាជ្ញាបណ្ណ។

ច_ ចំណាយបុរេសនា សំដៅដល់ ចំណាយដែលទាក់ទិននឹងការស្វែងរុករកជំហានដំបូងនៅស្រទាប់ដីលើដោយប្រើប្រាស់ឧបករណ៍សាមញ្ញដែលមានការប៉ះពាល់បន្តិចបន្តួចដល់ផ្ទៃដីដើម្បីកំណត់វត្តមានធនធានរ៉ែ។

ឆ_ ចំណាយស្វែងរុករក សំដៅដល់ ចំណាយក្នុងការសិក្សាស្រាវជ្រាវក្នុងបំណងរកឱ្យឃើញធ្វើតេស្តសន្និស្សន៍រ៉ែ ដើម្បីកំណត់សក្តានុពល ទំហំ គុណភាព បរិមាណ ព្រមទាំងលទ្ធភាពសេដ្ឋកិច្ចអាជីវកម្មតាមរយៈការធ្វើបុរេសនា ការស្រាវជ្រាវភូគព្ភសាស្ត្រ រូបភូគព្ភសាស្ត្រ និងគីមីភូគព្ភសាស្ត្រ ការជីកកកាយ ការខួង ការដឹកជញ្ជូន និងការធ្វើវិភាគដី ដីល្បាប់ ទឹក ថ្ម និងគំរូរ៉ែផ្សេងៗទៀត ព្រមទាំងចំណាយរដ្ឋបាលទូទៅ និងចំណាយផ្សេងៗទៀតដែលកើតឡើងនៅក្នុងប្រតិបត្តិការធនធានរ៉ែ ដើម្បីកំណត់វត្តមាន ទីតាំង បរិមាណ និងគុណភាពនៃជម្រកធនធានរ៉ែ។

ជ_ ចំណាយអភិវឌ្ឍន៍ សំដៅដល់ ចំណាយដែលបានកើតឡើងដើម្បីអភិវឌ្ឍជម្រកធនធានរ៉ែឱ្យចាប់ផ្តើមដំណើរការផលិតកម្មពាណិជ្ជកម្មបាន មានជាអាទិ៍ការគូសប្លង់ ការសាងសង់ការដំឡើងបរិក្ខារសម្រាប់ផលិតកម្ម ការធ្វើអណ្តូងផលិតកម្ម ការខួងអណ្តូងផលិតកម្ម និងព្រមទាំងសកម្មភាពទាំងឡាយណាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍរបស់អ្នកជាប់ពន្ធស្របតាមលក្ខខណ្ឌដែលមានចែងក្នុងលិខិតអនុញ្ញាតផលិតកម្មចេញដោយស្ថាប័ន។

ឈ_ ប្រាក់បម្រុងសម្រាប់ចំណាយស្តារការដ្ឋាន សំដៅដល់ ប្រាក់បម្រុងដែលអនុញ្ញាតឱ្យកាត់កងជាមុនសម្រាប់ចំណាយស្តារការដ្ឋានឡើងវិញដែលនឹងត្រូវបានធ្វើឡើងស្របតាមផែនការស្តារការដ្ឋាន។

ញ_ ចំណាយសរុបដែលបានយល់ព្រមសម្រាប់ស្តារការដ្ឋាន សំដៅដល់ ចំណាយសរុបសម្រាប់ស្តារការដ្ឋានឡើងវិញនៅក្នុងដែនទទួលអាជ្ញាបណ្ណដែលបានយល់ព្រមដោយស្ថាប័នតាមផែនការស្តារការដ្ឋានរបស់អ្នកជាប់ពន្ធ ស្របតាមអាជ្ញាបណ្ណឬកិច្ចព្រមព្រៀងវិនិយោគធនធានរ៉ែ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីធនធានរ៉ែ។

ដ_ ពេលចាប់ផ្តើមផលិតកម្មពាណិជ្ជកម្ម សំដៅដល់ ពេលដែលអ្នកជាប់ពន្ធចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មស្របតាមការកំណត់ក្នុងអាជ្ញាបណ្ណធនធានរ៉ែ។



https://www.moj.gov.kh/kh/law-regular

៣_ សម្រាប់គោលដៅនៃជំពូកនេះ៖

ក_ អ្នកជាប់ពន្ធ សំដៅដល់ រូបវន្តបុគ្គលឬនីតិបុគ្គលដែលបានចុះកិច្ចព្រមព្រៀងប្រេងកាតជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ឬដែលទទួលបានអាជ្ញាបណ្ណធនធានរ៉ែ។

ខ_ ស្ថាប័ន សំដៅដល់ ក្រសួងរ៉ែនិងថាមពល ឬស្ថាប័នរាជរដ្ឋាភិបាលដែលទទួលបន្ទុកគ្រប់គ្រងវិស័យប្រេងកាតឬគ្រប់គ្រងវិស័យរ៉ែ។

## ផ្នែកទី២
## អត្រាពន្ធលើប្រាក់ចំណូល

**មាត្រា១២៧ ._** អត្រាពន្ធលើប្រាក់ចំណូល

១_ អ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការប្រេងកាត និងអ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការធនធានរ៉ែ ដូចមានចែងក្នុងមាត្រា១២៦នៃច្បាប់នេះ ត្រូវជាប់ពន្ធលើប្រាក់ចំណូលតាមអត្រា៣០(សាមសិប)ភាគរយនៃប្រាក់ចំណូលជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធ។ សម្រាប់គោលដៅនៃច្បាប់នេះ ពាក្យ ប្រាក់ចំណូលជាប់ពន្ធ សំដៅដល់ប្រាក់ចំណូលសុទ្ធដែលបានមកពីការយកចំណូលដុលសម្រេចបានពីប្រតិបត្តិការប្រេងកាតឬធនធានរ៉ែដកចំណាយនានាដែលអនុញ្ញាតដោយច្បាប់នេះ។

២_ បន្ថែមលើអត្រាពន្ធដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ អ្នកជាប់ពន្ធត្រូវជាប់ពន្ធលើប្រាក់ចំណូលលើសកម្រិតតាមអត្រាកំណើនតាមថ្នាក់ដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រានេះ ដោយផ្អែកលើសមាមាត្រនៃប្រាក់ចំណូលលើសកម្រិត។ សមាមាត្រនៃប្រាក់ចំណូលលើសកម្រិតនៃឆ្នាំជាប់ពន្ធចរន្តណាមួយ គឺជាផលចែករវាងទឹកប្រាក់បូកបង្គរនៃចំណូល និងទឹកប្រាក់បូកបង្គរនៃចំណាយពីប្រតិបត្តិការប្រេងកាត ឬធនធានរ៉ែមកទល់នឹងឆ្នាំជាប់ពន្ធចរន្តនោះ។

៣_ អត្រាពន្ធលើប្រាក់ចំណូលលើសកម្រិតមានដូចក្នុងតារាងខាងក្រោម៖

| ថ្នាក់ | សមាមាត្រនៃប្រាក់ចំណូលលើសកម្រិត | | | | អត្រាពន្ធលើប្រាក់ចំណូលលើសកម្រិត |
|---|---|---|---|---|---|
| ១ | | | ដល់ | ១,៣ | ០(សូន្យ)ភាគរយ |
| ២ | លើសពី | ១,៣ | ដល់ | ១,៦ | ១០(ដប់)ភាគរយ |
| ៣ | លើសពី | ១,៦ | ដល់ | ២ | ២០(ម្ភៃ)ភាគរយ |
| ៤ | លើសពី | ២ | ឡើងទៅ | | ៣០(សាមសិប)ភាគរយ |

៤_ អ្នកជាប់ពន្ធត្រូវបានលើកលែងពីការបង់ពន្ធអប្បបរមាដូចមានចែងក្នុងមាត្រា២៤នៃច្បាប់នេះ។

## ផ្នែកទី៣
## ការកាត់កង

**មាត្រា១២៨ ._** គោលការណ៍និងកំហិតនៃការកាត់កងចំណាយ

១_ អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យគណនាប្រាក់ចំណូលជាប់ពន្ធដោយធ្វើការកាត់កងចំណាយនានាដូចមានចែងក្នុងមាត្រា១២៩ ដល់មាត្រា១៣៣នៃច្បាប់នេះ នៅដំណាច់ឆ្នាំជាប់ពន្ធដែលសកម្មភាពអាជីវកម្មពាណិជ្ជកម្មបានកើតឡើង រួមទាំងចំណាយចរន្តពាក់ព័ន្ធផ្សេងទៀតនៅក្នុងឆ្នាំជាប់ពន្ធនីមួយៗ។



https://www.moj.gov.kh/kh/law-regular

២_ ចំណាយដែលទាក់ទិននឹងប្រតិបត្តិការប្រេងកាតឬធនធានរ៉ែនៅក្នុងតំបន់ចុះកិច្ចព្រមព្រៀងណាមួយ ឬដែនអាជ្ញាបណ្ណណាមួយសម្រាប់ឆ្នាំជាប់ពន្ធណាមួយ ត្រូវបានអនុញ្ញាតឱ្យកាត់កងតែពីប្រាក់ចំណូលដុលសរុបពីប្រតិបត្តិការប្រេងកាតឬធនធានរ៉ែក្នុងតំបន់ចុះកិច្ចព្រមព្រៀង ឬដែនអាជ្ញាបណ្ណនៃឆ្នាំជាប់ពន្ធនោះប៉ុណ្ណោះ។

៣_ ប្រសិនបើនៅក្នុងឆ្នាំជាប់ពន្ធណាមួយ ចំណាយសរុបដែលទាក់ទិននឹងប្រតិបត្តិការប្រេងកាតឬធនធានរ៉ែនៅក្នុងតំបន់ចុះកិច្ចព្រមព្រៀង ឬដែនអាជ្ញាបណ្ណលើសពីចំណូលដុលសរុបដែលនាំឱ្យមានលទ្ធផលខាតបង់ ការខាតបង់ត្រូវបានចាត់ទុកជាបន្ទុកសម្រាប់កាត់កងពីប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានក្នុងឆ្នាំជាប់ពន្ធបន្ទាប់។ ប្រសិនបើប្រាក់ចំណូលជាប់ពន្ធនោះមិនគ្រប់គ្រាន់សម្រាប់កាត់កងជាស្ថាពរទេ ចំណែកនៃការខាតបង់ដែលនៅសេសសល់ត្រូវយោងទៅឆ្នាំជាប់ពន្ធបន្តបន្ទាប់រហូតដល់ឆ្នាំជាប់ពន្ធទី១០(ដប់)។ ក្នុងករណីដែលមានការខាតបង់លើសពី១(មួយ)ឆ្នាំ ការយោងការខាតបង់ត្រូវអនុវត្តតាមលំដាប់ឆ្នាំដែលការខាតបង់ទាំងឡាយបានកើតឡើង។

៤_ ការខាតបង់ដែលកើតមានឡើងក្នុងតំបន់ចុះកិច្ចព្រមព្រៀងឬដែនអាជ្ញាបណ្ណណាមួយ មិនអាចយោងយកទៅកាត់កងក្នុងតំបន់ចុះកិច្ចព្រមព្រៀងឬដែនអាជ្ញាបណ្ណដទៃទៀតឡើយ។

**មាត្រា១២៩ ._** ចំណាយការប្រាក់

អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យកាត់កងចំណាយការប្រាក់តាមវិធានសមាមាត្របំណុល៣(បី) ធៀបនឹងដើមទុន១(មួយ)។

**មាត្រា១៣០ ._** ប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ ឬចំណាយស្តារការដ្ឋាន

ប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ ឬចំណាយស្តារការដ្ឋាន ត្រូវបានកំណត់ដូចខាងក្រោម៖

១_ សម្រាប់ប្រតិបត្តិការប្រេងកាត៖

ក_ ប្រសិនបើអ្នកជាប់ពន្ធមានផែនការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញដែលបានយល់ព្រមដោយស្ថាប័ន ទឹកប្រាក់ដែលបានតម្រូវឱ្យអ្នកជាប់ពន្ធបង់ចូលមូលនិធិសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ ត្រូវបានចាត់ទុកជាប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ។ ប្រាក់បម្រុងនេះ ត្រូវបានអនុញ្ញាតជាសំវិធានធន និងត្រូវបានអនុញ្ញាតឱ្យកាត់កងក្នុងឆ្នាំជាប់ពន្ធ ដើម្បីគណនាប្រាក់ចំណូលជាប់ពន្ធ។ ក្នុងករណីអ្នកជាប់ពន្ធគ្មានផែនការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញដែលបានយល់ព្រមដោយស្ថាប័នទេ ប្រាក់បម្រុងតាមកថាខណ្ឌនេះមិនត្រូវបានអនុញ្ញាតឡើយ។

ខ_ ប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ ត្រូវបានគណនាដោយផ្អែកទៅតាមចំណាយសរុបដែលបានយល់ព្រមដោយស្ថាប័នសម្រាប់បិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ។ ប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញក្នុងឆ្នាំនីមួយៗ និងឆ្នាំដែលប្រាក់បម្រុងត្រូវបានអនុញ្ញាតឱ្យចាប់ផ្តើមកាត់កង ត្រូវកំណត់តាមផែនការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ។



https://www.moj.gov.kh/kh/law-regular

គ- ប្រសិនបើចំណាយសរុបជាក់ស្តែងនៃការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញមានចំនួនលើសពីចំនួនសរុបនៃទឹកប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ ចំនួនលើសនោះត្រូវបានអនុញ្ញាតឱ្យកាត់កងពីប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ។

ឃ- ប្រសិនបើនៅចុងបញ្ចប់នៃការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញចំណាយសរុបជាក់ស្តែងនៃការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញមានចំនួនតិចជាងចំនួនសរុបនៃទឹកប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ ចំនួនលម្អៀងនោះត្រូវគិតបញ្ចូលក្នុងប្រាក់ចំណូលជាប់ពន្ធសម្រាប់ឆ្នាំជាប់ពន្ធដែលបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញនោះបានបញ្ចប់។

២- សម្រាប់ប្រតិបត្តិការធនធានរ៉ែ៖

ក- ប្រសិនបើអ្នកជាប់ពន្ធមានផែនការបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញដែលបានយល់ព្រមដោយស្ថាប័ន ទឹកប្រាក់ដែលបានតម្រូវឱ្យអ្នកជាប់ពន្ធបង់ចូលមូលនិធិសម្រាប់ចំណាយស្តារការដ្ឋាន ត្រូវបានចាត់ទុកជាប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញ។ ប្រាក់បម្រុងនេះ ត្រូវបានអនុញ្ញាតជាសំវិធានធន និងត្រូវបានអនុញ្ញាតឱ្យកាត់កងក្នុងឆ្នាំជាប់ពន្ធដើម្បីគណនាប្រាក់ចំណូលជាប់ពន្ធ។ ក្នុងករណីអ្នកជាប់ពន្ធគ្មានផែនការបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញដែលបានយល់ព្រមដោយស្ថាប័នទេ ប្រាក់បម្រុងតាមកថាខណ្ឌនេះ មិនត្រូវបានអនុញ្ញាតឡើយ។

ខ- ប្រាក់បម្រុងសម្រាប់ចំណាយស្តារការដ្ឋាន ត្រូវបានគណនាដោយផ្អែកទៅតាមចំណាយសរុបដែលបានយល់ព្រមដោយស្ថាប័នសម្រាប់បិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញ។ ប្រាក់បម្រុងសម្រាប់ចំណាយស្តារការដ្ឋានក្នុងឆ្នាំនីមួយៗ និងឆ្នាំដែលប្រាក់បម្រុងត្រូវបានអនុញ្ញាតឱ្យចាប់ផ្តើមកាត់កង ត្រូវកំណត់តាមផែនការបិទការដ្ឋានរ៉ែនិងការស្តារបរិស្ថានឡើងវិញ។

គ- ប្រសិនបើចំណាយសរុបជាក់ស្តែងនៃការបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញមានចំនួនលើសពីចំនួនសរុបនៃទឹកប្រាក់បម្រុងសម្រាប់ចំណាយស្តារការដ្ឋាន ចំនួនលើសនោះត្រូវបានអនុញ្ញាតឱ្យកាត់កងពីប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ។

ឃ- ប្រសិនបើនៅចុងបញ្ចប់នៃការបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញ ចំណាយសរុបជាក់ស្តែងនៃការបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញមានចំនួនតិចជាងចំនួនសរុបនៃទឹកប្រាក់បម្រុងសម្រាប់ចំណាយស្តារការដ្ឋាន ចំនួនលម្អៀងនោះត្រូវគិតបញ្ចូលក្នុងប្រាក់ចំណូលជាប់ពន្ធសម្រាប់ឆ្នាំជាប់ពន្ធដែលការបិទការដ្ឋានរ៉ែនិងការស្តារបរិស្ថានឡើងវិញនោះបានបញ្ចប់។

៣- វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ ឬចំណាយស្តារការដ្ឋាន ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងស្ថាប័ន។



https://www.moj.gov.kh/kh/law-regular

**មាត្រា១៣១ ._** វិធីរំលស់

វិធីរំលស់ត្រូវបានកំណត់ដូចខាងក្រោម៖

១_ អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍តាមវិធីរំលស់ស្មើភាគតាមមាត្រា១៣២នៃច្បាប់នេះ។ អ្នកជាប់ពន្ធមិនត្រូវធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍តាមមាត្រា១៥នៃច្បាប់នេះទេ។

២_ ចំពោះទ្រព្យរូបីនិងទ្រព្យអរូបីក្រៅពីចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ដែលបានទិញឬបានបង្កើតក្រោយពេលចាប់ផ្ដើមធ្វើផលិតកម្មពាណិជ្ជកម្មក្នុងតំបន់ចុះកិច្ចព្រមព្រៀងឬដែនអាជ្ញាបណ្ណ អ្នកជាប់ពន្ធត្រូវធ្វើរំលស់ទ្រព្យរូបីតាមវាក្យខណ្ឌ ក ដល់វាក្យខណ្ឌ ឃ នៃកថាខណ្ឌទី១នៃមាត្រា១៣នៃច្បាប់នេះ និងធ្វើរំលស់ទ្រព្យអរូបីតាមមាត្រា១៤នៃច្បាប់នេះ។

**មាត្រា១៣២ ._** រំលស់ស្មើភាគ

រំលស់ស្មើភាគសម្រាប់ប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែ ត្រូវបានកំណត់ដូចខាងក្រោម៖

១_ សម្រាប់ប្រតិបត្តិការប្រេងកាត៖

ក_ អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា និងចំណាយស្វែងរុករកតាមវិធីរំលស់ស្មើភាគតាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មក្រោមគម្រោងអភិវឌ្ឍន៍ឬ៥(ប្រាំ)ឆ្នាំ ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង។

ខ_ អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយអភិវឌ្ឍន៍តាមវិធីរំលស់ស្មើភាគតាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មរបស់មធ្យោបាយផលិតកម្មនីមួយៗក្រោមគម្រោងអភិវឌ្ឍន៍ឬ១០(ដប់)ឆ្នាំ សម្រាប់ប្រតិបត្តិការប្រេងកាតដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង។

គ_ ក្នុងករណីអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មរបស់មធ្យោបាយផលិតកម្មណាមួយក្រោមគម្រោងអភិវឌ្ឍន៍ត្រូវបានកែប្រែ អ្នកជាប់ពន្ធត្រូវធ្វើការកែតម្រូវការធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ដែលនៅសល់តាមអាយុកាលរំពឹងទុកដែលកែប្រែ ដោយមិនត្រូវឱ្យលើសពីអាយុកាលរំលស់តាមវាក្យខណ្ឌ ក និងវាក្យខណ្ឌ ខ នៃកថាខណ្ឌនេះឡើយ។

២_ សម្រាប់ប្រតិបត្តិការធនធានរ៉ែ៖

ក_ អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា និងចំណាយស្វែងរុករកតាមវិធីរំលស់ស្មើភាគតាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មក្រោមគម្រោងអភិវឌ្ឍន៍ឬ៥(ប្រាំ)ឆ្នាំ ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង។

ខ_ អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយអភិវឌ្ឍន៍តាមវិធីរំលស់ស្មើភាគតាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មក្រោមគម្រោងអភិវឌ្ឍន៍ឬ៧(ប្រាំពីរ)ឆ្នាំ ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង។



https://www.moj.gov.kh/kh/law-regular

គ_ ក្នុងករណីអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មក្រោមគម្រោងអភិវឌ្ឍន៍ត្រូវបានកែប្រែ អ្នកជាប់ពន្ធត្រូវធ្វើការកែតម្រូវការធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ដែលនៅសល់តាមអាយុកាលរំពឹងទុកដែលកែប្រែ ដោយមិនត្រូវឱ្យលើសពីអាយុកាលរំលស់តាមវាក្យខណ្ឌ ក និងវាក្យខណ្ឌ ខ នៃកថាខណ្ឌនេះឡើយ។

ឃ_ ក្នុងករណីអ្នកជាប់ពន្ធមានគម្រោងអភិវឌ្ឍន៍ដែលមានរយៈពេលតិចជាង១(មួយ)ឆ្នាំ ចំណាយអភិវឌ្ឍន៍នេះអាចបញ្ចូលទៅធ្វើរំលស់ក្នុងចំណាយបុរេសនានិងចំណាយស្វែងរុករក។

**មាត្រា១៣៣ ._** ពេលធ្វើរំលស់

ពេលធ្វើរំលស់ត្រូវបានកំណត់ដូចខាងក្រោម៖

១_ អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ដែលបានកើតឡើងមុនពេលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មដំបូងនៅដំណាច់ឆ្នាំជាប់ពន្ធ ដែលអ្នកជាប់ពន្ធចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មដំបូងក្នុងតំបន់ចុះកិច្ចព្រមព្រៀងឬដែនអាជ្ញាបណ្ណ។

២_ ក្រោយពេលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មដំបូងក្នុងតំបន់ចុះកិច្ចព្រមព្រៀងឬដែនអាជ្ញាបណ្ណ ប្រសិនបើអ្នកជាប់ពន្ធធ្វើបុរេសនា ឬស្វែងរុករក ឬសាងសង់បន្តនូវមធ្យោបាយផលិតកម្មដទៃទៀតក្រោមគម្រោងអភិវឌ្ឍន៍ក្នុងតំបន់ចុះកិច្ចព្រមព្រៀងឬដែនអាជ្ញាបណ្ណ អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍តាមពេលដូចខាងក្រោម៖

ក_ នៅដំណាច់ឆ្នាំជាប់ពន្ធនីមួយៗចំពោះចំណាយបុរេសនា ឬចំណាយស្វែងរុករកទៅតាមលំដាប់ឆ្នាំដែលចំណាយនោះបានកើតឡើង។

ខ_ នៅដំណាច់ឆ្នាំជាប់ពន្ធដែលមធ្យោបាយផលិតកម្មនីមួយៗត្រូវបានដាក់ឱ្យប្រើប្រាស់ចំពោះចំណាយអភិវឌ្ឍន៍។

រំលស់ត្រូវធ្វើដាច់ដោយឡែកៗពីគ្នាសម្រាប់មធ្យោបាយផលិតកម្មនីមួយៗក្រោមគម្រោងអភិវឌ្ឍន៍ស្របតាមមាត្រា១៣២នៃច្បាប់នេះ ហើយត្រូវបូកសរុបបញ្ចូលគ្នាសម្រាប់កាត់កងក្នុងឆ្នាំជាប់ពន្ធ។

៣_ ចំពោះទ្រព្យរូបីនិងទ្រព្យអរូបីក្រៅពីចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ដែលបានទិញឬបានបង្កើតក្រោយពេលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មក្នុងតំបន់ចុះកិច្ចព្រមព្រៀងឬដែនអាជ្ញាបណ្ណ អ្នកជាប់ពន្ធត្រូវធ្វើរំលស់នៅដំណាច់ឆ្នាំជាប់ពន្ធ ដែលទ្រព្យទាំងនោះត្រូវបានដាក់ឱ្យប្រើប្រាស់។

## ផ្នែកទី៤
## ការផ្ទេរអត្ថប្រយោជន៍

**មាត្រា១៣៤ ._** ការផ្ទេរអត្ថប្រយោជន៍និងការអភិវឌ្ឍនិងផលិតកម្មរួម

១_ ក្នុងករណីមានការផ្ទេរមួយផ្នែកឬទាំងស្រុងនៃអត្ថប្រយោជន៍ដែលជាសិទ្ធិឬចំណែកក្នុងកិច្ចព្រមព្រៀងប្រេងកាត ឬអាជ្ញាបណ្ណធនធានរ៉ែតាមរូបភាពលក់ទិញ ដោះដូរ ឬធ្វើអំណោយ អ្នកជាប់ពន្ធដែលជាអ្នកផ្ទេរ និងបុគ្គលជាអ្នកទទួលបន្តត្រូវអនុវត្តដូចខាងក្រោម៖

ក_ អ្នកជាប់ពន្ធដែលជាអ្នកផ្ទេរត្រូវកត់ត្រាចំណូលទទួលបានពីការផ្ទេរអត្ថប្រយោជន៍ក្នុងកិច្ចព្រមព្រៀងប្រេងកាត ឬអាជ្ញាបណ្ណធនធានរ៉ែជាចំណូលពីប្រតិបត្តិការប្រេងកាត ឬធនធានរ៉ែដែលជាកម្មវត្ថុនៃពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងជំពូកទី២នៃច្បាប់នេះ។



https://www.moj.gov.kh/kh/law-regular

ខ_ បុគ្គលជាអ្នកទទួលបន្តត្រូវៈ

- បន្តអនុវត្តកាតព្វកិច្ចសារពើពន្ធពីអ្នកជាប់ពន្ធដែលជាអ្នកផ្ទេរចំពោះអត្ថប្រយោជន៍ដែលជាសិទ្ធិឬចំណែកដែលបានទទួល
- បន្តធ្វើរំលស់ទ្រព្យរូបី ទ្រព្យអរូបី ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍តាមវិធាននិងនីតិវិធី និងមូលដ្ឋានដែលអ្នកជាប់ពន្ធដែលជាអ្នកផ្ទេរបានធ្វើរំលស់កន្លងមក
- ក្នុងករណីការផ្ទេរអត្ថប្រយោជន៍ក្នុងកិច្ចព្រមព្រៀងប្រេងកាតឬអាជ្ញាបណ្ណធនធានរ៉ែមានតម្លៃលើសពីតម្លៃពិតគណនេយ្យ តម្លៃលម្អៀងនោះត្រូវបានចាត់ទុកជាមូលនិធិពាណិជ្ជកម្ម។ បុគ្គលជាអ្នកទទួលបន្តត្រូវធ្វើរំលស់មូលនិធិពាណិជ្ជកម្មនេះតាមវិធីរំលស់ស្មើភាគតាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មដែលនៅសល់ឬ ១០(ដប់)ឆ្នាំ សម្រាប់ប្រតិបត្តិការប្រេងកាត និង៧(ប្រាំពីរ)ឆ្នាំសម្រាប់ប្រតិបត្តិការធនធានរ៉ែដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង
- ក្នុងករណីការផ្ទេរអត្ថប្រយោជន៍ក្នុងកិច្ចព្រមព្រៀងប្រេងកាតឬអាជ្ញាបណ្ណធនធានរ៉ែមានតម្លៃតិចជាងតម្លៃពិតគណនេយ្យ តម្លៃលម្អៀងនោះត្រូវបានចាត់ទុកជាចំណូល។ បុគ្គលជាអ្នកទទួលបន្តត្រូវកត់ត្រាជាចំណូលសម្រាប់ឆ្នាំបន្តបន្ទាប់ដោយបែងចែកចំណូលទាំងនេះតាមសមាមាត្រនៃអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មដែលនៅសល់ឬ១០(ដប់)ឆ្នាំ សម្រាប់ប្រតិបត្តិការប្រេងកាត និង៧(ប្រាំពីរ)ឆ្នាំសម្រាប់ប្រតិបត្តិការធនធានរ៉ែដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង។

២_ ចំពោះអ្នកជាប់ពន្ធពីរឬច្រើនដែលត្រូវបានអនុញ្ញាតឱ្យចុះកិច្ចព្រមព្រៀងអភិវឌ្ឍន៍និងផលិតកម្មរួមដើម្បីធ្វើប្រតិបត្តិការរួមគ្នាក្នុងការអភិវឌ្ឍនិងផលិតកម្មលើជម្រកប្រេងកាតមួយឬច្រើន ដែលស្ថិតនៅក្នុងតំបន់ចុះកិច្ចព្រមព្រៀងប្រេងកាតផ្សេងគ្នា វិធាននិងនីតិវិធីដែលត្រូវអនុវត្តត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៥
## ភាតព្វកិច្ចអ្នកជាប់ពន្ធ

**មាត្រា១៣៥ ._** កាតព្វកិច្ចរបស់អ្នកជាប់ពន្ធ

១_ អ្នកជាប់ពន្ធអនិវាសនជនដែលចុះកិច្ចព្រមព្រៀងប្រេងកាត ឬអាជ្ញាបណ្ណធនធានរ៉ែជាមួយរាជរដ្ឋាភិបាលកម្ពុជាដូចមានចែងក្នុងមាត្រា១២៦នៃច្បាប់នេះ ត្រូវបង្កើតជាក្រុមហ៊ុនក្នុងស្រុកមួយសម្រាប់តំបន់ចុះកិច្ចព្រមព្រៀងមួយស្របតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេលយ៉ាងតិច ១៥(ដប់ប្រាំ)ថ្ងៃមុនពេលចាប់ផ្តើមសកម្មភាពសេដ្ឋកិច្ច។

២_ អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាសសារពើពន្ធនិងបង់ប្រាក់ពន្ធអាករប្រចាំខែ ប្រចាំឆ្នាំ ជូនរដ្ឋបាលសារពើពន្ធតាមការកំណត់នៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ។

៣_ ប្រតិបត្តិករដែលជាតំណាងអ្នកជាប់ពន្ធទាំងអស់ក្នុងតំបន់ចុះកិច្ចព្រមព្រៀងឬដែនអាជ្ញាបណ្ណត្រូវផ្តល់របាយការណ៍និងឯកសារនានានៃប្រតិបត្តិការអាជីវកម្មក្នុងតំបន់ចុះកិច្ចព្រមព្រៀងឬដែនអាជ្ញាបណ្ណតាមការតម្រូវរបស់រដ្ឋបាលសារពើពន្ធ។



https://www.moj.gov.kh/kh/law-regular

**មាត្រា១៣៦ ._** ការលើកទឹកចិត្តផ្នែកសារពើពន្ធ

ការផ្តល់ការលើកទឹកចិត្តផ្នែកសារពើពន្ធចំពោះកិច្ចព្រមព្រៀងប្រេងកាតឬអាជ្ញាបណ្ណធនធានរ៉ែណាមួយ ដែលបានធ្វើឡើងមុនពេលចូលជាធរមាននៃបទប្បញ្ញត្តិនៃជំពូកនេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៣៧ ._** ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ

អ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការប្រេងកាត និងអ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការធនធានរ៉ែដូចមានចែងក្នុងមាត្រា១២៦នៃច្បាប់នេះ ត្រូវអនុវត្តបទប្បញ្ញត្តិក្នុងជំពូកនេះនិងបទប្បញ្ញត្តិដទៃទៀតស្តីពីពន្ធដារ។ ក្នុងករណីដែលមានភាពមិនស្របគ្នា បទប្បញ្ញត្តិនៃជំពូកនេះមានឧត្តមានុភាពលើបទប្បញ្ញត្តិដទៃទៀតស្តីពីពន្ធដារ។

**មាត្រា១៣៨ ._** វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើប្រតិបត្តិការប្រេងកាតឬប្រតិបត្តិការធនធានរ៉ែត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី១១
## ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ

**មាត្រា១៣៩ ._** កម្មវត្ថុនៃពន្ធ

ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យត្រូវអនុវត្តលើការជួលអចលនទ្រព្យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៤០ ._** វិសាលភាពនៃពន្ធ

ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យអនុវត្តលើកម្មសិទ្ធិករ ឬសិទ្ធិវន្តរបស់កម្មសិទ្ធិករនៃអចលនទ្រព្យដែលមិនមែនជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។

**មាត្រា១៤១ ._** និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងជំពូកនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១_ អចលនទ្រព្យ សំដៅដល់៖

- ក_ អគារនិងសំណង់ផ្សេងៗ ដូចជាផ្ទះ រោងចក្រ សណ្ឋាគារ ការិយាល័យព្រមទាំងឧបសម្ព័ន្ធរបស់វា។
- ខ_ យន្តូបករណ៍ដែលជាប់ជាមួយគ្រឹះស្ថានឧស្សាហកម្ម។
- គ_ ឋបនភណ្ឌពាណិជ្ជកម្ម ឧស្សាហកម្មដែលនៅនឹងកន្លែង អគារធំៗ ឬឃ្លាំងស្តុកទំនិញ។
- ឃ_ លំនៅឋានចល័តសម្រាប់ស្នាក់នៅឬប្រកបអាជីវកម្មផ្សេងៗ។
- ង_ ដីធ្លីដែលគ្មានសំណង់។

២_ សិទ្ធិវន្ត សំដៅដល់ អ្នកមានសិទ្ធិលើទ្រព្យតាមរយៈការផ្តល់ឱ្យដោយម្ចាស់កម្មសិទ្ធិនៃទ្រព្យ។

៣_ ថ្លៃឈ្នួលអចលនទ្រព្យ សំដៅដល់ ប្រាក់ឈ្នួលដុលដែលបានចុះកិច្ចសន្យាឬបានព្រមព្រៀងជាមួយអ្នកជួលដោយផ្អែកលើតម្លៃទីផ្សារ។



https://www.moj.gov.kh/kh/law-regular

**មាត្រា១៤២ .-** អត្រាពន្ធ

ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យត្រូវបានកំណត់តាមអត្រា១០(ដប់)ភាគរយនៃថ្លៃឈ្នួលអចលនទ្រព្យ។

**មាត្រា១៤៣ .-** ការលើកលែងពន្ធ

ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យត្រូវបានលើកលែងដូចខាងក្រោម៖

១- ថ្លៃឈ្នួលពីការជួលអចលនទ្រព្យរបស់រាជរដ្ឋាភិបាលឬក្រសួង ស្ថាប័នរាជរដ្ឋាភិបាល។

២- ថ្លៃឈ្នួលពីការជួលអចលនទ្រព្យរបស់បេសកកម្មការទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត។

៣- ថ្លៃឈ្នួលពីការជួលអចលនទ្រព្យរបស់អង្គការឬសមាគមណាមួយដែល៖

ក- ត្រូវបានរៀបចំឡើងនិងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬអប់រំ។

ខ- គ្មានចំណែកណាមួយនៃថ្លៃឈ្នួលត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជន។

៤- ប្រាក់ដែលអ្នកជួលបានតម្កល់ទុកជាប្រាក់ធានា ហើយនៅពេលចប់កិច្ចសន្យា កម្មសិទ្ធិករត្រូវប្រគល់គ្រប់ចំនួនឱ្យអ្នកជួលវិញ។

៥- ថ្លៃឈ្នួលដែលបានកាត់ទុកប្រាក់ពន្ធរួចហើយដោយសហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសតាមមាត្រា២៥និងមាត្រា២៦នៃច្បាប់នេះ។

៦- ថ្លៃឈ្នួលពីការជួលអចលនទ្រព្យរបស់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដែលបានគិតបញ្ចូលក្នុងប្រាក់ចំណូលជាប់ពន្ធរបស់សហគ្រាសរួចហើយ។

**មាត្រា១៤៤ .-** កាតព្វកិច្ចរបស់កម្មសិទ្ធិករឬសិទ្ធិវន្ត

កម្មសិទ្ធិករឬសិទ្ធិវន្តរបស់កម្មសិទ្ធិករមានកាតព្វកិច្ចដូចខាងក្រោម៖

១- ត្រូវចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធនៅក្នុងភូមិសាស្ត្រដែលអចលនទ្រព្យស្ថិតនៅក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃចុះកិច្ចសន្យាជួល ឬចាប់ពីថ្ងៃមានការប្រែប្រួលអំពីកិច្ចសន្យាតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់។

២- ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមករដ្ឋបាលសារពើពន្ធក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃក្រោយពេលឈប់ជួល ដោយត្រូវចុះកាលបរិច្ឆេទនិងមានហត្ថលេខាត្រឹមត្រូវរបស់កម្មសិទ្ធិករឬអ្នកតំណាងដែលមានសិទ្ធិ។

៣- ត្រូវចេញបង្កាន់ដៃទទួលប្រាក់ជូនអ្នកជួលក្នុងពេលទទួលប្រាក់ឈ្នួលម្តងៗ។

៤- ត្រូវដាក់លិខិតប្រកាសបង់ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យជូនរដ្ឋបាលសារពើពន្ធទៅតាមកាលកំណត់ដូចខាងក្រោម៖

ក- ជារៀងរាល់ខែយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ ប្រសិនបើកិច្ចសន្យាតម្រូវឱ្យមានការបង់ប្រាក់ប្រចាំខែ។

ខ- យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ពីខែដែលត្រូវធ្វើការទូទាត់ទៅតាមចំនួនទឹកប្រាក់សរុប ប្រសិនបើកិច្ចសន្យាតម្រូវឱ្យមានការបង់ប្រាក់សរុបសម្រាប់រយៈពេលច្រើនខែ។



https://www.moj.gov.kh/kh/law-regular

**មាត្រា១៤៥ .-** កាតព្វកិច្ចរបស់អ្នកជួល

អ្នកជួលត្រូវមានកាតព្វកិច្ចបង្ហាញបង្កាន់ដៃទទួលប្រាក់ដែលកម្មសិទ្ធិករផ្តល់ជូន និងត្រូវផ្តល់ព័ត៌មានផ្សេងៗទៀតដែលទាក់ទិននឹងការជួលដល់រដ្ឋបាលសារពើពន្ធ។

**មាត្រា១៤៦ .-** វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើថ្លៃឈ្នួលអចលនទ្រព្យត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

# ជំពូកទី១២
# ពន្ធលើអចលនទ្រព្យ

**មាត្រា១៤៧ .-** កម្មវត្ថុនៃពន្ធ

ពន្ធលើអចលនទ្រព្យត្រូវអនុវត្តលើអចលនទ្រព្យដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៤៨ .-** វិសាលភាពនៃពន្ធ

ពន្ធលើអចលនទ្រព្យអនុវត្តលើអចលនទ្រព្យដែលស្ថិតនៅក្នុងរដ្ឋបាលរាជធានី ខេត្តនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៤៩ .-** និយមន័យ

សម្រាប់គោលដៅនៃបទប្បញ្ញត្តិស្តីពីពន្ធលើអចលនទ្រព្យ ពាក្យ **អចលនទ្រព្យ** សំដៅដល់ ដី ផ្ទះ អគារ និងសំណង់ផ្សេងៗ។

**មាត្រា១៥០ .-** អត្រាពន្ធ

ពន្ធលើអចលនទ្រព្យត្រូវប្រមូលប្រចាំឆ្នាំតាមអត្រា០,១(សូន្យក្បៀសមួយ)ភាគរយ។

**មាត្រា១៥១ .-** មូលដ្ឋានគិតពន្ធ

មូលដ្ឋានគិតពន្ធលើអចលនទ្រព្យត្រូវផ្អែកលើតម្លៃអចលនទ្រព្យដែលកំណត់ដោយគណៈកម្មការវាយតម្លៃអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យ។ មូលដ្ឋានគិតពន្ធលើអចលនទ្រព្យ និងគណៈកម្មការវាយតម្លៃអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យ ត្រូវកំណត់និងបង្កើតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៥២ .-** ការលើកលែងពន្ធ

ពន្ធលើអចលនទ្រព្យត្រូវបានលើកលែងដូចខាងក្រោម៖

១-អចលនទ្រព្យដែលជាដីធ្លីកសិកម្ម។

២-អចលនទ្រព្យដែលជាកម្មសិទ្ធិរបស់រាជរដ្ឋាភិបាលឬក្រសួង ស្ថាប័នរាជរដ្ឋាភិបាល។

៣-អចលនទ្រព្យដែលជាកម្មសិទ្ធិរបស់សហគមន៍ឬបុគ្គលណាមួយដែល៖

ក- ត្រូវបានរៀបចំឡើងនិងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនានិងសប្បុរសធម៌។

ខ- គ្មានចំណែកណាមួយនៃអចលនទ្រព្យឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាប្រយោជន៍ឯកជន។



https://www.moj.gov.kh/kh/law-regular

៤_ អចលនទ្រព្យជាកម្មសិទ្ធិរបស់បេសកកម្មការទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត។

៥_ អចលនទ្រព្យដែលជាហេដ្ឋារចនាសម្ព័ន្ធ មានជាអាទិ៍ផ្លូវ ស្ពាន ប្រព័ន្ធផលិតទឹកស្អាតឬផលិតអគ្គិសនី ព្រលានយន្តហោះ កំពង់ផែ ស្ថានីយអយស្ម័យយាន រួមបញ្ចូលទាំងអគារនិងការិយាល័យដែលបម្រើផ្ទាល់ដល់សកម្មភាពនៃហេដ្ឋារចនាសម្ព័ន្ធទាំងនោះ។

**មាត្រា១៥៣ ._** កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ

កម្មសិទ្ធិករ ឬអ្នកកាន់កាប់ ឬអ្នកទទួលប្រយោជន៍ចុងក្រោយនៃអចលនទ្រព្យ ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំឆ្នាំ។

**មាត្រា១៥៤ ._** វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី១៣
## ពន្ធប្រថាប់ត្រា

**មាត្រា១៥៥ ._** កម្មវត្ថុនៃពន្ធ

ពន្ធប្រថាប់ត្រាអនុវត្តលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យនិងចលនទ្រព្យ ការផ្ទេរភាគហ៊ុន កិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវាដែលប្រើប្រាស់ថវិការដ្ឋ និងលិខិតមានលក្ខណៈគតិយុត្ត។

**មាត្រា១៥៦ ._** វិសាលភាពនៃពន្ធ

ពន្ធប្រថាប់ត្រាអនុវត្តលើ៖

១_ ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យនិងចលនទ្រព្យ ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យនិងចលនទ្រព្យក្នុងក្រុមហ៊ុន។

២_ ការផ្ទេរចំណែកណាមួយឬទាំងស្រុងនៃភាគហ៊ុនរបស់ក្រុមហ៊ុន។

៣_ កិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវាដែលប្រើប្រាស់ថវិការដ្ឋ។

៤_ លិខិតមានលក្ខណៈគតិយុត្ត រួមមានលិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងលិខិតស្តីពីការបិទក្រុមហ៊ុន។

**មាត្រា១៥៧ ._** និយមន័យ

ពាក្យសព្ទសំខាន់ៗដែលប្រើក្នុងជំពូកនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១_ ញាតិ សំដៅដល់៖

- រវាងឪពុកម្តាយបង្កើតនិងកូនបង្កើត

- រវាងប្តីនិងប្រពន្ធ



https://www.moj.gov.kh/kh/law-regular

- រវាងយាយតាបង្កើតនិងចៅបង្កើត
- រវាងបងប្អូនបង្កើតនិងបងប្អូនបង្កើត
- រវាងឪពុកម្ដាយក្មេកនិងកូនប្រសា
- រវាងយាយតាក្មេកនិងចៅប្រសា។

២_ប្រទានកម្ម សំដៅដល់ ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យពីមនុស្សរស់ទៅឱ្យញាតិដោយមិនយកថ្លៃ។

៣_ សន្តតិកម្ម សំដៅដល់ ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យពីមនុស្សស្លាប់ទៅឱ្យញាតិ។

៤_ តម្លៃចុះកិច្ចសន្យា សំដៅដល់ តម្លៃដែលមានចែងក្នុងកិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវាដែលប្រើប្រាស់ថវិការដ្ឋ។

៥_ តម្លៃភាគហ៊ុន សំដៅដល់ តម្លៃនៃការផ្ទេរភាគហ៊ុនផ្អែកតាមតម្លៃទីផ្សារ។

៦_ ភាគហ៊ុន សំដៅដល់ ចំណែកណាមួយឬទាំងស្រុងនៃភាគហ៊ុន ឬផលប្រយោជន៍ ឬការលក់អាជីវកម្មរបស់ក្រុមហ៊ុននីតិបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ និងសហគ្រាសឯកបុគ្គលដែលបានចុះបញ្ជីឬមិនបានចុះបញ្ជីនៅក្រសួងឬស្ថាប័នមានសមត្ថកិច្ច។

៧_ អចលនទ្រព្យ សំដៅដល់ ដី ផ្ទះ អគារ និងសំណង់ផ្សេងៗ ទោះបីជាបានចុះបញ្ជីឬមិនបានចុះបញ្ជីដោយរដ្ឋបាលសុរិយោដី។

៨_ ក្រុមហ៊ុនអចលនទ្រព្យ សំដៅដល់ ក្រុមហ៊ុនទាំងឡាយណាដែលកាន់កាប់អចលនទ្រព្យដោយផ្ទាល់ឬដោយប្រយោលដែលមានតម្លៃលើសពី៥០(ហាសិប)ភាគរយនៃតម្លៃទ្រព្យសកម្មសរុបរបស់ក្រុមហ៊ុន។

៩_ ចលនទ្រព្យ សំដៅដល់ មធ្យោបាយដឹកជញ្ជូនឬយានជំនិះគ្រប់ប្រភេទ ដូចជា កប៉ាល់ សាឡង់ ទូក កាណូត អូប៉ូរ រថយន្ត ក្បាលរថយន្តសណ្ដោង រ៉ឺម៉កសណ្ដោង ស៊ីមីរ៉ឺម៉កសណ្ដោង ទោចក្រយានយន្ត ត្រីចក្រយានយន្ត ត្រាក់ទ័រ និងគ្រឿងយន្តប្រហាក់ប្រហែល។

១០_ លិខិតមានលក្ខណៈគតិយុត្ត សំដៅដល់ លិខិតមានលក្ខណៈគតិយុត្តស្ដីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការបិទក្រុមហ៊ុនដែលបានចុះបញ្ជីនៅក្រសួងឬស្ថាប័នមានសមត្ថកិច្ច។

**មាត្រា១៥៨** ._ អត្រាពន្ធ

ពន្ធប្រថាប់ត្រាត្រូវកំណត់តាមអត្រាដូចខាងក្រោម៖

១_៤(បួន)ភាគរយនៃតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យជាសំណង់និង/ឬដី ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន ឬការផ្ទេរភាគហ៊ុន ឬផលប្រយោជន៍ប្រហាក់ប្រហែលរបស់ក្រុមហ៊ុនអចលនទ្រព្យ។

២_ ៤(បួន)ភាគរយនៃតម្លៃចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ចលនទ្រព្យ ឬការដាក់ភាគហ៊ុនជាចលនទ្រព្យក្នុងក្រុមហ៊ុន។

៣_ ០,១(សូន្យក្បៀសមួយ)ភាគរយនៃតម្លៃភាគហ៊ុនចំពោះការផ្ទេរចំណែកណាមួយឬទាំងស្រុងនៃភាគហ៊ុនរបស់ក្រុមហ៊ុន។

៤_ ០,១(សូន្យក្បៀសមួយ)ភាគរយនៃតម្លៃចុះកិច្ចសន្យាចំពោះកិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវាដែលប្រើប្រាស់ថវិការដ្ឋ។

៥_ ១ ០០០ ០០០(មួយលាន)រៀល ចំពោះលិខិតមានលក្ខណៈគតិយុត្ត រួមមានលិខិតស្ដីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងលិខិតស្ដីពីការបិទក្រុមហ៊ុន។



https://www.moj.gov.kh/kh/law-regular

**មាត្រា១៥៩ .-** មូលដ្ឋានគិតពន្ធ

មូលដ្ឋានគិតពន្ធប្រថាប់ត្រាត្រូវបានកំណត់ដូចខាងក្រោម៖

១- តម្លៃអចលនទ្រព្យនិងចលនទ្រព្យត្រូវគិតតាមតម្លៃទីផ្សារនាពេលផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចកំណត់តម្លៃអចលនទ្រព្យនិងចលនទ្រព្យសម្រាប់ធ្វើជាមូលដ្ឋានគិតពន្ធនេះ។

២- តម្លៃភាគហ៊ុនឬផលប្រយោជន៍ប្រហាក់ប្រហែលត្រូវគិតតាមតម្លៃទីផ្សារនាពេលប្រតិបត្តិការផ្ទេរភាគហ៊ុនឬផលប្រយោជន៍ប្រហាក់ហែលនោះកើតឡើង។

៣- តម្លៃបុះកិច្ចសន្យា ត្រូវគិតតាមតម្លៃក្នុងកិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវាដែលប្រើប្រាស់ថវិការដ្ឋ។

៤- លិខិតមានលក្ខណៈគតិយុត្តត្រូវកំណត់ ១ ០០០ ០០០(មួយលាន)រៀល ចំពោះលិខិតមានលក្ខណៈគតិយុត្តនីមួយៗ។

**មាត្រា១៦០ .-** អ្នកជាប់ពន្ធ

ពន្ធប្រថាប់ត្រាត្រូវអនុវត្តចំពោះ៖

១- អ្នកទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យនិងចលនទ្រព្យ។

២- អ្នកទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់ភាគហ៊ុន។

៣- អ្នកទទួលបានកិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវាដែលប្រើប្រាស់ថវិការដ្ឋ។

៤- អ្នកទទួលសិទ្ធិលើលិខិតមានលក្ខណៈគតិយុត្ត។

**មាត្រា១៦១ .-** ការលើកលែងនិងការអនុគ្រោះពន្ធ

ពន្ធប្រថាប់ត្រាត្រូវបានលើកលែងនិងអនុគ្រោះដូចខាងក្រោម៖

១-ការទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់ដីក្នុងលក្ខណៈសម្បទានពីរាជរដ្ឋាភិបាល។

២-ការទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យក្នុងរង្វង់ញាតិ។

៣-ការទទួលកម្មសិទ្ធិទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់១៥០(មួយរយហាសិប)សេះ។

៤- ការទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យនិងចលនទ្រព្យដែលត្រូវកត់ត្រាក្នុងបញ្ជីសារពើភណ្ឌរបស់ស្ថាប័នរដ្ឋនានានៃព្រះរាជាណាចក្រកម្ពុជា។

៥- ការទទួលកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យនិងចលនទ្រព្យរបស់បេសកកម្មការទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត។

៦-ការទិញចលនទ្រព្យរបស់សហគ្រាសនានាធ្វើជាទំនិញដើម្បីលក់វិញ។

**មាត្រា១៦២ .-** កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ

អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធឱ្យបានចប់សព្វគ្រប់ក្នុងរយៈពេល ៣(បី)ថ្ងៃចំពោះ៖

១- ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យនិងចលនទ្រព្យ ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យនិងចលនទ្រព្យក្នុងក្រុមហ៊ុន។

២- ការផ្ទេរចំណែកណាមួយឬទាំងស្រុងនៃភាគហ៊ុនរបស់ក្រុមហ៊ុន។



https://www.moj.gov.kh/kh/law-regular

៣_ កិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវាដែលប្រើប្រាស់ចរិការដ្ឋ។

៤_ លិខិតមានលក្ខណៈគតិយុត្ត រួមមានលិខិតស្ដីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងលិខិតស្ដីពីការបិទក្រុមហ៊ុន។

**មាត្រា១៦៣ ._** ការខកខានមិនបានដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ

ប្រសិនបើម្ចាស់កម្មសិទ្ធិឬអ្នកកាន់កាប់ថ្មីណាមួយមិនបានបង់ប្រាក់ពន្ធប្រថាប់ត្រាៈ

១_ រដ្ឋបាលសុរិយោដីមិនត្រូវចេញឬផ្ទេរវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬបណ្ណសម្គាល់សិទ្ធិអចលនវត្ថុ ឬបណ្ណប្រហាក់ប្រហែលថ្មីនោះទេ។

២_ អាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ មិនត្រូវបញ្ជាក់លើការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យ។

៣_ ស្ថាប័នសាធារណការនិងដឹកជញ្ជូន ឬអាជ្ញាធរមានសមត្ថកិច្ចមិនត្រូវចេញបណ្ណសម្គាល់ថ្មីចំពោះការផ្ទេរកម្មសិទ្ធិលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ វៀរលែងតែទោចក្រយានយន្តត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងជលយានយន្តដែលមានកម្លាំងដល់១៥០(មួយរយហាសិប)សេះ។

**មាត្រា១៦៤ ._** វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធប្រថាប់ត្រាត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី១៤
## ពន្ធលើចំណេញមូលធន

**មាត្រា១៦៥ ._** កម្មវត្ថុនៃពន្ធ

ពន្ធលើចំណេញមូលធនត្រូវអនុវត្តលើចំណេញមូលធនដែលសម្រេចបានពីការលក់ឬផ្ទេរមូលធននៅព្រះរាជាណាចក្រកម្ពុជានិងនៅបរទេសដោយអ្នកជាប់ពន្ធនិវាសនជនជារូបវន្តបុគ្គល និងពីការលក់ឬផ្ទេរមូលធននៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយអ្នកជាប់ពន្ធអនិវាសនជន។

**មាត្រា១៦៦ ._** វិសាលភាពនៃពន្ធ

ពន្ធលើចំណេញមូលធនអនុវត្តលើអ្នកជាប់ពន្ធដែលទទួលបានចំណេញមូលធន។

**មាត្រា១៦៧ ._** និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងជំពូកនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោមៈ

១_ អ្នកជាប់ពន្ធ សំដៅដល់ អ្នកជាប់ពន្ធនិវាសនជន ឬអ្នកជាប់ពន្ធអនិវាសនជនដែលបានលក់ឬផ្ទេរមូលធនទៅឱ្យបុគ្គលដទៃ។

២_ អ្នកជាប់ពន្ធនិវាសនជន សំដៅដល់ រូបវន្តបុគ្គលដែលមាននិវាសនដ្ឋាន ឬមានកន្លែងស្នាក់នៅជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា លើសពី១៨២(មួយរយប៉ែតសិបពីរ)ថ្ងៃ នៅក្នុងរយៈពេល១២(ដប់ពីរ)ខែណាមួយដែលបានបញ្ចប់ក្នុងឆ្នាំជាប់ពន្ធចរន្ត។



https://www.moj.gov.kh/kh/law-regular

៣_ អ្នកជាប់ពន្ធអនិវាសនជន សំដៅដល់ រូបវន្តបុគ្គលឬនីតិបុគ្គលដែលមិនមែនជាអ្នកជាប់ពន្ធនិវាសនជន។

៤_ មូលធន សំដៅដល់ អចលនទ្រព្យ ភតិសន្យា ទ្រព្យវិនិយោគ កេរ្តិ៍ឈ្មោះអាជីវកម្ម កម្មសិទ្ធិបញ្ញា និងរូបិយបណ្ណបរទេស។

៥_ ចំណេញមូលធន សំដៅដល់ ប្រាក់ចំណូលជាប់ពន្ធដែលបានពីការយកចំណូលពីការលក់ឬផ្ទេរមូលធនដកការកាត់កងចំណាយដែលអនុញ្ញាត។

**មាត្រា១៦៨ ._** អត្រាពន្ធ

អត្រាពន្ធលើចំណេញមូលធនត្រូវបានកំណត់តាមអត្រា២០(ម្ភៃ)ភាគរយ។

**មាត្រា១៦៩ ._** ការលើកលែងពន្ធ

ពន្ធលើចំណេញមូលធនត្រូវបានលើកលែងចំពោះការលក់ឬផ្ទេរ៖

១_ ទ្រព្យដែលជាកម្មសិទ្ធិរបស់ស្ថាប័នរដ្ឋ។

២_ ទ្រព្យដែលជាកម្មសិទ្ធិរបស់បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសនៃរដ្ឋាភិបាលដទៃទៀត។

៣_ និវាសនដ្ឋានជាគោលដើមរបស់អ្នកជាប់ពន្ធ។

៤_ អចលនទ្រព្យក្នុងរង្វង់ញាតិ។

៥_ ទ្រព្យសម្រាប់បម្រើប្រយោជន៍សាធារណៈស្របតាមច្បាប់ស្តីពីអស្សាមិករណ៍។

៦_ ដីកសិកម្មជាកម្មសិទ្ធិឬសិទ្ធិកាន់កាប់របស់ប្រជាពលរដ្ឋដែលជាកសិករកំពុងបង្កបង្កើនផលពិតប្រាកដ និងមានអាសយដ្ឋានរស់នៅស្ថិតនៅក្នុងឃុំ/សង្កាត់ដែលដីកសិកម្មនោះស្ថិតនៅ។

**មាត្រា១៧០ ._** វិធាននៃការកាត់កងចំណាយ

វិធាននៃការកាត់កងចំណាយចំពោះចំណេញមូលធនមានដូចខាងក្រោម៖

១_ វិធីកាត់កងចំណាយតាមការកំណត់។

២_ វិធីកាត់កងចំណាយតាមជាក់ស្តែង។

**មាត្រា១៧១ ._** កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ

អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក ត្រូវដាក់លិខិតប្រកាសពន្ធ តាមទម្រង់ដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ និងបង់ប្រាក់ពន្ធលើចំណេញមូលធនជូនរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេលមិនលើសពី៣(បី)ខែ បន្ទាប់ពីសម្រេចបានចំណេញមូលធន។

**មាត្រា១៧២ ._** វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើចំណេញមូលធនត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



https://www.moj.gov.kh/kh/law-regular

# ជំពូកទី១៥
# ពន្ធលើដីធ្លីមិនបានប្រើប្រាស់

**មាត្រា១៧៣ .-** កម្មវត្ថុនៃពន្ធ

ពន្ធលើដីធ្លីមិនបានប្រើប្រាស់ត្រូវអនុវត្តលើដីមានសំណង់និងដីគ្មានសំណង់ដែលមិនបានប្រើប្រាស់។

**មាត្រា១៧៤ .-** វិសាលភាពនៃពន្ធ

ពន្ធលើដីធ្លីមិនបានប្រើប្រាស់អនុវត្តលើដីធ្លីមិនបានប្រើប្រាស់ដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៧៥ .-** និយមន័យ

សម្រាប់គោលដៅនៃបទប្បញ្ញត្តិស្តីពីពន្ធលើដីធ្លីមិនបានប្រើប្រាស់ ពាក្យ ដីធ្លីមិនបានប្រើប្រាស់ សំដៅដល់ ដីមានសំណង់ឬគ្មានសំណង់ដែលមិនបានប្រើប្រាស់។

**មាត្រា១៧៦ .-** អត្រាពន្ធ

ពន្ធលើដីធ្លីមិនបានប្រើប្រាស់ត្រូវប្រមូលប្រចាំឆ្នាំតាមអត្រា២(ពីរ)ភាគរយ។

**មាត្រា១៧៧ .-** មូលដ្ឋានគិតពន្ធ

មូលដ្ឋានគិតពន្ធលើដីធ្លីមិនបានប្រើប្រាស់ត្រូវផ្អែកលើតម្លៃដីដែលកំណត់ដោយគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់។ មូលដ្ឋានគិតពន្ធលើដីធ្លីមិនបានប្រើប្រាស់និងគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ត្រូវកំណត់និងបង្កើតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៧៨ .-** ការលើកលែងពន្ធ

ការលើកលែងពន្ធលើដីធ្លីមិនបានប្រើប្រាស់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៧៩ .-** កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ

កម្មសិទ្ធិករ ឬអ្នកកាន់កាប់ ឬអ្នកទទួលប្រយោជន៍ចុងក្រោយនៃដីធ្លីមិនបានប្រើប្រាស់ ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំឆ្នាំ។

**មាត្រា១៨០ .-** វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



https://www.moj.gov.kh/kh/law-regular

## ជំពូកទី១៦
## ពន្ធលើមធ្យោបាយដឹកជញ្ជូន

**មាត្រា១៨១ .-** កម្មវត្ថុនៃពន្ធ

ពន្ធលើមធ្យោបាយដឹកជញ្ជូនត្រូវអនុវត្តលើមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ។

**មាត្រា១៨២ .-** វិសាលភាពនៃពន្ធ

ពន្ធលើមធ្យោបាយដឹកជញ្ជូនអនុវត្តលើមធ្យោបាយដឹកជញ្ជូននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៨៣ .-** និយមន័យ

សម្រាប់គោលដៅនៃបទប្បញ្ញត្តិស្តីពីពន្ធលើមធ្យោបាយដឹកជញ្ជូន ពាក្យ មធ្យោបាយដឹកជញ្ជូន សំដៅដល់ មធ្យោបាយដឹកជញ្ជូនឬយានជំនិះគ្រប់ប្រភេទ ដូចជា កប៉ាល់ សាឡង់ ទូក កាណូត អូប័រ រថយន្ត ក្បាលរថយន្តសណ្តោង រ៉ឺម៉កសណ្តោង ស៊ីមីរ៉ឺម៉កសណ្តោង ទោចក្រយានយន្ត ត្រីចក្រយានយន្ត ត្រាក់ទ័រ និងគ្រឿងយន្តប្រហាក់ប្រហែល។

**មាត្រា១៨៤ .-** អត្រាពន្ធ

១- ពន្ធលើមធ្យោបាយដឹកជញ្ជូនត្រូវកំណត់ទៅតាមប្រភេទមធ្យោបាយដឹកជញ្ជូនដូចខាងក្រោម៖

ក- រថយន្តដឹកទំនិញ។

ខ- ក្បាលរថយន្តសណ្តោង រ៉ឺម៉កសណ្តោង ស៊ីមីរ៉ឺម៉កសណ្តោង។

គ- រថយន្តដឹកអ្នកដំណើរ។

ឃ- ជលយានឬជលយានយន្ត។

ង- រថយន្តទេសចរណ៍។

ច- យានឬយានយន្តកែច្នៃ។

២- អត្រាពន្ធលើមធ្យោបាយដឹកជញ្ជូនត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៨៥ .-** អ្នកជាប់ពន្ធ

ពន្ធលើមធ្យោបាយដឹកជញ្ជូនត្រូវអនុវត្តលើម្ចាស់កម្មសិទ្ធិនៃមធ្យោបាយដឹកជញ្ជូន។

**មាត្រា១៨៦ .-** ការលើកលែងពន្ធ

ពន្ធលើមធ្យោបាយដឹកជញ្ជូនត្រូវបានលើកលែងចំពោះ៖

១- រថយន្តគិលានសង្គ្រោះ រថយន្តពន្លត់អគ្គិភ័យដែលជាកម្មសិទ្ធិរបស់រដ្ឋ។

២- យានយន្តដែលជាកម្មសិទ្ធិរបស់អង្គភាពកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងនគរបាលជាតិ។

៣- យានយន្តដែលជាកម្មសិទ្ធិរបស់ស្ថានទូតឬស្ថានកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត។

៤- ទោចក្រយានយន្តនិងត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រនិងគ្រឿងយន្តប្រហាក់ប្រហែល និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់១៥០(មួយរយហាសិប)សេះ ឬតិចជាង។



https://www.moj.gov.kh/kh/law-regular

**មាត្រា១៨៧ .-** កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ

ម្ចាស់កម្មសិទ្ធិមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំឆ្នាំ។

**មាត្រា១៨៨ .-** វិធាននិងនីតិវិធីគ្រប់គ្រងប្រមូលពន្ធ

វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី១៧
## វិធាននិងនីតិវិធីសារពើពន្ធ
### ផ្នែកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា១៨៩ .-** កម្មវត្ថុ

១-បទប្បញ្ញត្តិទាំងឡាយនៃជំពូកនេះ កំណត់នូវសិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ អំណាចនិងកាតព្វកិច្ចរបស់រដ្ឋបាលសារពើពន្ធ និងនីតិវិធីនៃការពិនិត្យឡើងវិញនូវប្រាក់ពន្ធបានបង់។

២-បទប្បញ្ញត្តិទាំងឡាយនៃជំពូកនេះ ត្រូវអនុវត្តចំពោះពន្ធគ្រប់ប្រភេទ វៀរលែងតែពន្ធដោយឡែកណាមួយដែលមានចែងផ្សេង។

**មាត្រា១៩០ .-** និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងជំពូកទី១៧ និងជំពូកទី១៨ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១-ពន្ធ សំដៅដល់ ពន្ធនិងអាករទាំងឡាយ។

២-បុគ្គល សំដៅដល់ រូបវន្តបុគ្គលឬនីតិបុគ្គល។

៣-អ្នកជាប់ពន្ធ សំដៅដល់ បុគ្គលដែលមានកាតព្វកិច្ចត្រូវបង់ពន្ធ។

៤-រដ្ឋបាលសារពើពន្ធ សំដៅដល់ អង្គការចាត់តាំងនៃអគ្គនាយកដ្ឋានពន្ធដារ។

៥-មន្ត្រីពន្ធដារ សំដៅដល់ មន្ត្រីរាជការពន្ធដារគ្រប់លំដាប់ថ្នាក់ដែលកំពុងបម្រើការងារក្នុងក្របខ័ណ្ឌនៃអគ្គនាយកដ្ឋានពន្ធដារ។

៦-ការស៊ើបអង្កេត សំដៅដល់ ការធ្វើសវនកម្មពន្ធដារគ្រប់ប្រភេទ រួមទាំងការស៊ើបអង្កេតបទល្មើសលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

៧-លិខិតប្រកាសសារពើពន្ធ សំដៅដល់ ឯកសារដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវឱ្យអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកបំពេញទៅតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់នេះ។

៨-ភ្នាក់ងារកាត់ទុក សំដៅដល់ បុគ្គលដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវឱ្យធ្វើការកាត់ទុក និងបង់ប្រាក់ពន្ធចូលថវិការដ្ឋក្នុងនាមតតិយជន។

៩-សកម្មភាពសេដ្ឋកិច្ច សំដៅដល់ សកម្មភាពរបស់បុគ្គលដែលធ្វើជានិច្ចកាលជាប់បន្តឬ មួយដងម្កាល ដើម្បីរកឬមិនរកចំណេញក្នុងការផ្គត់ផ្គង់ ឬមានបំណងផ្គត់ផ្គង់ទំនិញឬសេវាឱ្យដល់បុគ្គលដទៃក្នុងគោលដៅដើម្បីបានអត្ថប្រយោជន៍អ្វីមួយ។


https://www.moj.gov.kh/kh/law-regular

១០_ពន្ធបន្ថែម សំដៅដល់ ទណ្ឌកម្មជាសាច់ប្រាក់ចំពោះអំពើល្មើសនឹងបទប្បញ្ញត្តិស្តីពីពន្ធដារ ដែលត្រូវបានគណនាតាមអត្រាដែលបានកំណត់ លើមូលដ្ឋានប្រាក់ពន្ធដែលបានបង់ខ្វះឬបង់យឺត។

១១_ការប្រាក់ សំដៅដល់ ការប្រាក់ដែលកើតឡើងពីការបង់ពន្ធខ្វះឬការបង់ពន្ធយឺត ដែលត្រូវបានគណនាតាមអត្រាដែលបានកំណត់ លើមូលដ្ឋានប្រាក់ពន្ធដែលបានបង់ខ្វះឬបង់យឺត។

**មាត្រា១៩១ ._** កិច្ចព្រមព្រៀងអន្តរជាតិ

១_ បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងអន្តរជាតិទាក់ទិននឹងបញ្ហាពន្ធដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី ត្រូវមានវិសាលភាពគ្របដណ្តប់លើបទប្បញ្ញត្តិនៃច្បាប់នេះ។

២_វិធាននិងនីតិវិធីសម្រាប់អនុវត្តបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងអន្តរជាតិទាក់ទិននឹងបញ្ហាពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៩២ ._** ភាសាប្រើនៅក្នុងលិខិតប្រកាសនិងឯកសារសារពើពន្ធ

លិខិតប្រកាសសារពើពន្ធទាំងអស់ ក៏ដូចជាឯកសារនិងលិខិតទាក់ទងផ្សេងៗដែលចាំបាច់សម្រាប់ការកំណត់ពន្ធ ការប្រមូលពន្ធ និងការបង្ខំឱ្យប្រតិបត្តិតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ឬដែលទាក់ទិននឹងបែបបទផ្សេងទៀតក្នុងការកំណត់ពន្ធ ត្រូវធ្វើជាភាសាខ្មែរ។

## ផ្នែកទី២
## សិទ្ធិ អំណាច និងកាតព្វកិច្ច

**មាត្រា១៩៣ ._** សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ

សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធត្រូវបានកំណត់ដូចខាងក្រោម៖

១_ អ្នកជាប់ពន្ធមានសិទ្ធិដូចខាងក្រោម៖

ក_ ទទួលបាននូវការរក្សាទុកជាការសម្ងាត់និងត្រូវបានយកមកប្រើប្រាស់តែក្នុងគោលដៅដែលមានបញ្ជាក់នៅក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារនូវព័ត៌មាននានាទាក់ទិននឹងកិច្ចការអាជីវកម្មរបស់ខ្លួនដែលបានផ្តល់ឱ្យរដ្ឋបាលសារពើពន្ធដូចមានចែងក្នុងមាត្រា១៩៧នៃច្បាប់នេះ។

ខ_ ទទួលព័ត៌មានជាប្រចាំអំពីកិច្ចដំណើរការនៃប្រព័ន្ធពន្ធដារនិងនីតិវិធីនៃការកំណត់ពន្ធដូចមានចែងក្នុងមាត្រា១៩៩និងមាត្រា២១១នៃច្បាប់នេះ។

គ_ ទទួលព័ត៌មានអំពីសិទ្ធិរបស់ខ្លួន រួមទាំងសិទ្ធិក្នុងការប្តឹងតវ៉ាដូចមានចែងក្នុងមាត្រា២១១ និងមាត្រា២៣៨នៃច្បាប់នេះ។

ឃ_ ប្តឹងតវ៉ាដូចមានចែងក្នុងច្បាប់នេះ ចំពោះរាល់សេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធដូចមានចែងក្នុងមាត្រា២១១និងមាត្រា២៣៨នៃច្បាប់នេះ។

ង_ បង់ពន្ធមិនឱ្យលើសពីបទប្បញ្ញត្តិស្តីពីពន្ធដារកំណត់ដូចមានចែងក្នុងមាត្រា២១៣នៃច្បាប់នេះ។



https://www.moj.gov.kh/kh/law-regular

២_ អ្នកជាប់ពន្ធមានកាតព្វកិច្ចដូចខាងក្រោម៖

ក_ ចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធដូចមានចែងក្នុងមាត្រា២០៣នៃច្បាប់នេះ។

ខ_ ដាក់លិខិតប្រកាសសារពើពន្ធនិងផ្តល់ព័ត៌មានតាមការតម្រូវនៃបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចមានចែងក្នុងមាត្រា២០១និងមាត្រា២០៦នៃច្បាប់នេះ។

គ_ បង់ពន្ធតាមកាលបរិច្ឆេទកំណត់ដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ។

ឃ_ កាន់ ថែរក្សា និងត្រូវបង្ហាញបញ្ជី លិខិតយុត្តិការ និងឯកសារផ្សេងៗដល់រដ្ឋបាលសារពើពន្ធ ដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ និងមាត្រា២០១នៃច្បាប់នេះ។

ង_ បង្ហាញខ្លួនចំពោះរដ្ឋបាលសារពើពន្ធតាមកាលបរិច្ឆេទដែលមានចុះក្នុងលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធដូចមានចែងក្នុងមាត្រា២០២នៃច្បាប់នេះ។

ច_ បង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗទៀតដែលរដ្ឋបាលសារពើពន្ធបានកំណត់ទៅតាមកាលបរិច្ឆេទដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ឬដែលរដ្ឋបាលសារពើពន្ធបានជូនដំណឹងជាលាយលក្ខណ៍អក្សរដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ និងមាត្រា២១៣ មាត្រា២៣២ និងមាត្រា២៣៣នៃច្បាប់នេះ។

**មាត្រា១៩៤ .-** អំណាចនិងកាតព្វកិច្ចរបស់រដ្ឋបាលសារពើពន្ធ

អំណាចនិងកាតព្វកិច្ចរបស់រដ្ឋបាលសារពើពន្ធត្រូវបានកំណត់ដូចខាងក្រោម៖

១_ រដ្ឋបាលសារពើពន្ធមានអំណាចដូចខាងក្រោម៖

ក_ កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកដូចមានចែងក្នុងមាត្រា២០៩ និងមាត្រា២១០នៃច្បាប់នេះ។

ខ_ តម្រូវឱ្យអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកបង្ហាញខ្លួនដូចមានចែងក្នុងមាត្រា២០២នៃច្បាប់នេះ។

គ_ កំណត់បញ្ជីឯកសារចាំបាច់នានា និងលិខិតយុត្តិការដែលអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកត្រូវកាន់រក្សាទុកនិងផ្តល់ជូនរដ្ឋបាលសារពើពន្ធដូចមានចែងក្នុងមាត្រា២០១និងមាត្រា២៣០នៃច្បាប់នេះ។

ឃ_ ទាមទារឱ្យអ្នកជាប់ពន្ធ ឬតតិយជនផ្តល់ព័ត៌មានទាក់ទិននឹងអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកដូចមានចែងក្នុងមាត្រា២០២នៃច្បាប់នេះ។

ង_ ចូលលំនៅឋានឬគ្រឹះស្ថានអាជីវកម្មរបស់អ្នកជាប់ពន្ធ ភ្នាក់ងារកាត់ទុក ឬតតិយជន ដើម្បីទទួលបាននូវព័ត៌មានទាក់ទិននឹងអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកដូចមានចែងក្នុងមាត្រា២៣០នៃច្បាប់នេះ។

ច_ ទទួលពីស្ថាប័នរដ្ឋទាំងឡាយនូវព័ត៌មានស្តីពីឬដែលទាក់ទិននឹងអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកដូចមានចែងក្នុងមាត្រា២០៩នៃច្បាប់នេះ។

ឆ_ អនុវត្តវិធានការតឹងទារចំពោះអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកនៅពេលដែលបុគ្គលនោះមិនបានបង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗទៀតតាមការតម្រូវដូចមានចែងក្នុងមាត្រា២១៧ មាត្រា២១៨ មាត្រា២២០ មាត្រា២២១ និងមាត្រា២២២នៃច្បាប់នេះ។

ជ_ កំណត់ឡើងវិញនូវប្រតិបត្តិការអាជីវកម្មក្នុងចំណោមបុគ្គលទាក់ទិនដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ។


https://www.moj.gov.kh/kh/law-regular

ឈ- ច្រានចោលនិង/ឬកំណត់សារជាតុពិតនៃប្រតិបត្តិការទាំងឡាយឡើងវិញក្នុងករណីពិនិត្យឃើញថាអ្នកជាប់ពន្ធបានរៀបចំឬមានប្រតិបត្តិការទាំងឡាយណាដែលបង្ហាញឆន្ទៈមិនពិត ឬគ្មានភាពជាក់ស្តែងក្នុងគោលបំណងដើម្បីបន្ថយឬបំបាត់ប្រាក់ពន្ធដែលត្រូវបង់ ដែលផ្ទុយពីស្មារតីនៃបទប្បញ្ញត្តិស្តីពីពន្ធដារ។

២- រដ្ឋបាលសារពើពន្ធមានកាតព្វកិច្ចដូចខាងក្រោម៖

ក- ប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗទៀតដូចមានចែងក្នុងមាត្រា១៩៥នៃច្បាប់នេះ។

ខ- រក្សាការសម្ងាត់នូវព័ត៌មានដែលអ្នកជាប់ពន្ធឬតតិយជនបានផ្តល់ឱ្យ ហើយផ្តល់ព័ត៌មានទាំងនេះឱ្យដល់តែបុគ្គលណាដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានកំណត់ដូចមានចែងក្នុងមាត្រា១៩៧ និងមាត្រា២៤៤នៃច្បាប់នេះ។

គ- ផ្តល់ព័ត៌មានដល់អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកសំដៅធានាឱ្យការអនុវត្តបានសមស្របទៅតាមបទប្បញ្ញត្តិស្តីពីពន្ធដារដូចមានចែងក្នុងមាត្រា១៩៩នៃច្បាប់នេះ។

ឃ- បង្វិលសងវិញ ឬចាត់ជាឥណទានពន្ធនូវប្រាក់ពន្ធដែលបង់លើសដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ។

ង- ផ្តល់លិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឱ្យអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកដូចមានចែងក្នុងមាត្រា២០៩ ដល់មាត្រា២១១នៃច្បាប់នេះ។

## ផ្នែកទី៣
## រដ្ឋបាលសារពើពន្ធ

**មាត្រា១៩៥ .-** ស្ថាប័នមានសមត្ថកិច្ច

១- ស្ថាប័នដែលទទួលខុសត្រូវគ្រប់គ្រងការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារមានដូចខាងក្រោម៖

ក- អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ខ- ស្ថាប័នដទៃទៀតរបស់រាជរដ្ឋាភិបាលដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានផ្តល់អំណាចឱ្យ។

២- រដ្ឋបាលសារពើពន្ធមានកាតព្វកិច្ចប្រមូលពន្ធ អនុវត្តទណ្ឌកម្មតាមការកំណត់នៃបទប្បញ្ញត្តិស្តីពីពន្ធដារ និងប្តឹងទៅតុលាការក្នុងករណីមានការរំលោភច្បាប់។

៣- រដ្ឋបាលសារពើពន្ធ គឺជាស្ថាប័នដែលមានសមត្ថកិច្ចក្នុងការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាល។ ការសម្រេចឱ្យរួចមួយផ្នែកឬទាំងស្រុងនូវទណ្ឌកម្មរដ្ឋបាល ជាសិទ្ធិអំណាចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រដ្ឋបាលសារពើពន្ធអាចសម្រេចឱ្យរួចមួយផ្នែកឬទាំងស្រុងនូវទណ្ឌកម្មរដ្ឋបាលនេះបាន ក្នុងករណីទទួលបានការធ្វើប្រតិភូកម្មសិទ្ធិអំណាចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៩៦ .-** សិទ្ធិអំណាចក្នុងគ្រាដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

១- ក្នុងករណីដែលប្រទេសជាតិប្រឈមមុខនឹងវិបត្តិសេដ្ឋកិច្ច ហិរញ្ញវត្ថុ ឬគ្រោះអាសន្ន ឬតម្រូវការចាំបាច់បន្ទាន់នានា ក្នុងការធានាលំនឹងជីវភាពនិងសុខុមាលភាពរបស់ប្រជាជន និងធានាប្រក្រតីភាពនៃកិច្ចដំណើរការសេដ្ឋកិច្ចនិងសង្គម រាជរដ្ឋាភិបាលអាចសម្រេចផ្តល់ការអនុគ្រោះ ឬលើកលែង ឬព្យួរប្រភេទពន្ធណាមួយភ្លាម មួយផ្នែកឬទាំងស្រុង តាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

២- ការផ្តល់ការអនុគ្រោះ ឬការលើកលែង ឬការព្យួរប្រភេទពន្ធណាមួយ ដូចមានចែងក្នុងកថាខណ្ឌ ១ខាងលើ នឹងត្រូវដាក់កម្មវត្ថុនៃការធ្វើនិយ័តភាវូបនីយកម្មដោយច្បាប់ហិរញ្ញវត្ថុ នាពេលបន្ទាប់។



https://www.moj.gov.kh/kh/law-regular

**មាត្រា១៩៧.-** ភាពសម្ងាត់នៃព័ត៌មានពន្ធដារ

១- រដ្ឋបាលសារពើពន្ធនិងបុគ្គលគ្រប់រូបដែលជាឬធ្លាប់ជាមន្ត្រីនិងភ្នាក់ងារនៃរដ្ឋបាលសារពើពន្ធ ត្រូវរក្សាភាពសម្ងាត់នូវព័ត៌មានទាក់ទិននឹងអ្នកជាប់ពន្ធដែលបានទទួលនៅក្នុងពេលបំពេញភារកិច្ចជាផ្លូវការ ហើយអាចផ្តល់ព័ត៌មានទៅឱ្យតែបុគ្គលដែលមាត្រានេះបានអនុញ្ញាតប៉ុណ្ណោះ។

២- មន្ត្រីនិងភ្នាក់ងារនៃរដ្ឋបាលសារពើពន្ធ អាចផ្តល់ព័ត៌មានទាក់ទិននឹងអ្នកជាប់ពន្ធឱ្យចំពោះតែៈ

ក- មន្ត្រីនិងភ្នាក់ងារផ្សេងទៀតរបស់រដ្ឋបាលសារពើពន្ធនៅក្នុងពេលនិងក្នុងគោលដៅបំពេញភារកិច្ចតាមបទប្បញ្ញត្តិស្តីពីពន្ធដារ។

ខ- អាជ្ញាធរព្រហ្មទណ្ឌសម្រាប់គោលដៅប្តឹងចោទប្រកាន់អំពីបទល្មើសពន្ធដារ។

គ- តុលាការនៅក្នុងដំណាក់កាលជម្រះក្តីដើម្បីកំណត់ពន្ធត្រូវបង់របស់អ្នកជាប់ពន្ធ ឬក៏ការទទួលខុសត្រូវចំពោះការរំលោភបទប្បញ្ញត្តិស្តីពីពន្ធដារ។

ឃ- អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនឹងពន្ធដាររបស់ប្រទេសណាមួយទៀតស្របតាមកិច្ចព្រមព្រៀងអន្តរជាតិ។

៣- បុគ្គលដែលបានទទួលព័ត៌មានពីបុគ្គលម្នាក់ទៀតដែលបានការអនុញ្ញាតឱ្យផ្តល់ព័ត៌មានដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រានេះ ត្រូវរក្សាភាពសម្ងាត់លើព័ត៌មាននោះទៅតាមការកំណត់នៃមាត្រានេះ លើកលែងតែកម្រិតអប្បបរមាណាមួយដែលចាំបាច់ត្រូវអនុញ្ញាតឱ្យផ្តល់ព័ត៌មាននេះ។

៤- ព័ត៌មានទាក់ទិននឹងអ្នកជាប់ពន្ធអាចផ្តល់ទៅឱ្យបុគ្គលម្នាក់ទៀតបាន ប្រសិនបើមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអ្នកជាប់ពន្ធ។

**មាត្រា១៩៨.-** ការផ្តល់ព័ត៌មានដល់អ្នកជាប់ពន្ធ

ការផ្តល់ព័ត៌មានដល់អ្នកជាប់ពន្ធត្រូវអនុវត្តដូចខាងក្រោមៈ

១- លិខិតស្នាមឬលិខិតជូនដំណឹងដែលរដ្ឋបាលសារពើពន្ធផ្តល់ទៅឱ្យអ្នកជាប់ពន្ធមានលក្ខណៈជាការដាក់ឱ្យអ្នកជាប់ពន្ធនោះមានកាតព្វកិច្ចចំពោះរដ្ឋបាលសារពើពន្ធ លុះណាតែលិខិតស្នាមឬលិខិតជូនដំណឹងនោះត្រូវបានធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវបានប្រគល់ឱ្យដល់អ្នកជាប់ពន្ធ។ លិខិតស្នាមឬលិខិតជូនដំណឹងដូចមានចែងក្នុងកថាខណ្ឌនេះ រួមបញ្ចូលទាំងការជូនដំណឹងតាមប្រព័ន្ធអេឡិចត្រូនិកដែលក្នុងនោះ មានជាអាទិ៍ទូរសារ សារអេឡិចត្រូនិក។

២- ក្នុងករណីដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវឱ្យរដ្ឋបាលសារពើពន្ធផ្តល់លិខិតស្នាមឬលិខិតជូនដំណឹងទៅឱ្យបុគ្គល លិខិតស្នាមឬលិខិតជូនដំណឹងនោះត្រូវបានចាត់ទុកថាបានប្រគល់យ៉ាងត្រឹមត្រូវ លុះណាតែបានប្រគល់ឱ្យបុគ្គលនោះ ឬក៏បានផ្ញើតាមប្រៃសណីយ៍ជាលិខិតអនុសិដ្ឋទៅអាសយដ្ឋានតាមផ្លូវច្បាប់របស់បុគ្គលនោះ។ ចំពោះការជូនដំណឹងតាមប្រព័ន្ធអេឡិចត្រូនិកដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ត្រូវបានចាត់ទុកថាបានប្រគល់ត្រឹមត្រូវ ប្រសិនបើបានបញ្ជូនទៅអាសយដ្ឋានចុងក្រោយដែលអ្នកជាប់ពន្ធបានផ្តល់ឱ្យរដ្ឋបាលសារពើពន្ធ។

៣- កាលបរិច្ឆេទនៃលិខិតស្នាមឬលិខិតជូនដំណឹងផ្សេងៗ គឺជាកាលបរិច្ឆេទនៃការប្រគល់ឱ្យបុគ្គល។ ក្នុងករណីលិខិតស្នាម ឬលិខិតជូនដំណឹងត្រូវបានផ្ញើតាមលិខិតអនុសិដ្ឋ កាលបរិច្ឆេទនៃការជូនដំណឹង គឺជាកាលបរិច្ឆេទនៃការបោះត្រាលើលិខិតអនុសិដ្ឋរបស់ការិយាល័យប្រៃសណីយ៍។ ក្នុងករណីការជូនដំណឹងតាមប្រព័ន្ធអេឡិចត្រូនិក កាលបរិច្ឆេទនៃការជូនដំណឹង គឺជាកាលបរិច្ឆេទដែលដំណឹងត្រូវបានផ្ញើចេញ។



https://www.moj.gov.kh/kh/law-regular

៤- លិខិតស្នាមឬលិខិតជូនដំណឹងត្រូវចាត់ទុកថាបានប្រគល់ទទួលត្រឹមត្រូវ ប្រសិនបើលក្ខខណ្ឌក្នុងកថាខណ្ឌទី២នៃមាត្រានេះ ត្រូវបានបំពេញរួចហើយ ទោះបីជាបុគ្គលដែលត្រូវបានជូនដំណឹងនោះបដិសេធការប្រគល់ឬការទទួលលិខិតអនុសិដ្ឋក្តី។

៥- ក្នុងករណីដែលអាសយដ្ឋានរបស់បុគ្គលត្រូវបានផ្លាស់ប្តូរ ហើយបុគ្គលមិនបានជូនដំណឹងដល់រដ្ឋបាលសារពើពន្ធអំពីការផ្លាស់ប្តូរនោះទេ លិខិតស្នាមឬលិខិតជូនដំណឹងដែលបានបញ្ជូនទៅអាសយដ្ឋានដែលបានស្គាល់ចុងក្រោយបង្អស់ ត្រូវចាត់ទុកថាបានប្រគល់ទទួលត្រឹមត្រូវ។

៦- ក្នុងករណីដោយមូលហេតុណាមួយដែលលិខិតស្នាមឬលិខិតជូនដំណឹងមិនអាចផ្តល់ដល់អ្នកជាប់ពន្ធ ដូចមានចែងក្នុងកថាខណ្ឌទី១ ដល់កថាខណ្ឌទី៥នៃមាត្រានេះ លិខិតស្នាមឬលិខិតជូនដំណឹងត្រូវបានចាត់ទុកថាបានប្រគល់យ៉ាងត្រឹមត្រូវ ប្រសិនបើរដ្ឋបាលសារពើពន្ធបាន៖

ក- បិទលិខិតស្នាម ឬលិខិតជូនដំណឹងភ្ជាប់ទៅនឹងទ្វារនិវាសនដ្ឋាន ឬទីកន្លែងប្រកបអាជីវកម្មរបស់អ្នកជាប់ពន្ធ ឬ

ខ- ផ្សព្វផ្សាយតាមសារព័ត៌មាន វិទ្យុ ទូរទស្សន៍ ឬគេហទំព័ររបស់រដ្ឋបាលសារពើពន្ធ ដោយតម្រូវឱ្យអ្នកជាប់ពន្ធបង្ហាញខ្លួននៅរដ្ឋបាលសារពើពន្ធមិនឱ្យលើសពី១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទផ្សព្វផ្សាយ។

**មាត្រា១៩៩ .-** ការផ្សព្វផ្សាយនិងការពន្យល់ណែនាំបទប្បញ្ញត្តិស្តីពីពន្ធដារ

១- រដ្ឋបាលសារពើពន្ធ ត្រូវរៀបចំសៀវភៅពន្យល់ខ្លីៗស្តីពីខ្លឹមសារសំខាន់ៗនៃប្រភេទពន្ធនីមួយៗ។

២- ចំពោះប្រភេទពន្ធណាមួយដែលរដ្ឋបាលសារពើពន្ធកំណត់ថាគួរចុះធ្វើការពន្យល់ណែនាំនោះ មន្ត្រីពន្ធដារនៅតាមមូលដ្ឋាន ត្រូវចុះអប់រំដល់អ្នកជាប់ពន្ធឱ្យបានយល់អំពីកាតព្វកិច្ចនិងសិទ្ធិរបស់អ្នកជាប់ពន្ធទាំងនោះ។

**មាត្រា២០០ .-** ការលើកទឹកចិត្តចំពោះការប្រមូលពន្ធ

១- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកសាងប្រព័ន្ធលើកទឹកចិត្តសម្រាប់រដ្ឋបាលសារពើពន្ធ។

២- វិធាននិងនីតិវិធីសម្រាប់ដំណើរការប្រព័ន្ធលើកទឹកចិត្តត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២០១ .-** ការកាន់ កត់ត្រា រក្សាទុកបញ្ជី លិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុ

១- អ្នកជាប់ពន្ធត្រូវកាន់ កត់ត្រា និងរក្សាទុកបញ្ជី លិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុផ្សេងៗដូចដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានកំណត់ និងត្រូវដាក់បញ្ជីនិងឯកសារទាំងនោះតាមការតម្រូវជូនរដ្ឋបាលសារពើពន្ធ។

២- ចំពោះអ្នកជាប់ពន្ធដែលពុំមានកាតព្វកិច្ចកាន់បញ្ជីគណនេយ្យតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកាន់ទិនានុប្បវត្តិដោយកត់ត្រាចុះតាមលំដាប់ថ្ងៃ ខែ នូវចំណូលនិងចំណាយផ្សេងៗទាំងអស់ដែលទាក់ទិននឹងអាជីវកម្មទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់។



https://www.moj.gov.kh/kh/law-regular

៣_ ក្នុងករណីដែលអ្នកជាប់ពន្ធមិនកាន់ កត់ត្រា ឬកត់ត្រាមិនត្រឹមត្រូវនូវបញ្ជីគណនេយ្យ ឬកំណត់ត្រានានាតាមលក្ខខណ្ឌដែលបានកំណត់ រដ្ឋបាលសារពើពន្ធជាអ្នកកំណត់នូវប្រាក់ចំណូលនិងចំណាយផ្សេងៗ។

៤_ បុគ្គលដែលត្រូវកាន់ កត់ត្រា ឬរក្សាទុកបញ្ជី ឯកសារនានា ឬទិន្នន័យវត្តិដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារឬបទប្បញ្ញត្តិដទៃ ត្រូវរក្សាទុកបញ្ជីឬឯកសារទាំងនោះ ក្នុងរយៈពេល១០(ដប់)ឆ្នាំសម្រាប់អ្នកជាប់ពន្ធមធ្យមនិងធំ និង៣(បី)ឆ្នាំសម្រាប់អ្នកជាប់ពន្ធតូច គិតពីដំណាច់ឆ្នាំជាប់ពន្ធ។

៥_ អ្នកជាប់ពន្ធត្រូវចេញវិក្កយបត្រលើរាល់ប្រតិបត្តិការអាជីវកម្ម។ វិធានវិក្កយបត្រត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៦_ អ្នកជាប់ពន្ធត្រូវកត់ត្រាសេចក្តីរាយលម្អិតនៃវិក្កយបត្រឱ្យបានត្រឹមត្រូវចូលក្នុងទិន្នន័យវត្តិ។

**មាត្រា២០២ ._** សិទ្ធិទទួលព័ត៌មាន

១_ ក្នុងគោលដៅកំណត់ប្រាក់ពន្ធត្រូវបង់របស់បុគ្គលណាម្នាក់ ឬដើម្បីប្រមូលពន្ធ ឬដើម្បីបំពេញកាតព្វកិច្ចស្របតាមកិច្ចព្រមព្រៀងអន្តរជាតិ រដ្ឋបាលសារពើពន្ធអាចធ្វើលិខិតជូនដំណឹងដល់អ្នកជាប់ពន្ធ ឬតតិយជន រួមទាំង ធនាគារ សហគ្រាសធានារ៉ាប់រង និងគ្រឹះស្ថានហិរញ្ញវត្ថុនានាឱ្យ៖

ក_ ផ្តល់ព័ត៌មានដែលទាក់ទិននឹងអ្នកជាប់ពន្ធឬបុគ្គលពាក់ព័ន្ធដូចមានចែងក្នុងលិខិតជូនដំណឹង ដូចជាព័ត៌មានស្តីពីអ្នកផ្គត់ផ្គង់ អតិថិជន ឬគណនីនៅធនាគារ។

ខ_ បង្ហាញខ្លួនទៅតាមពេលវេលានិងទីកន្លែងដែលមានបញ្ជាក់នៅក្នុងលិខិតជូនដំណឹង ដើម្បីផ្តល់ព័ត៌មាននិងដើម្បីបង្ហាញ ឬផ្តល់ឯកសារ ឬទិន្នន័យដែលបុគ្គលនោះគ្រប់គ្រង ដែលមានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងលិខិតជូនដំណឹង។

២_ បន្ថែមលើព័ត៌មានដែលបានតម្រូវដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ លិខិតជូនដំណឹងត្រូវមានចុះឈ្មោះនិងលេខអត្តសញ្ញាណកម្មនៃបុគ្គលអ្នកជាប់ពន្ធ (ប្រសិនបើមាន) ហើយនិងហត្ថលេខារបស់រដ្ឋបាលសារពើពន្ធដែលចេញលិខិតជូនដំណឹង។

៣_ អ្នកជាប់ពន្ធឬតតិយជន រួមទាំង ធនាគារ សហគ្រាសធានារ៉ាប់រង និងគ្រឹះស្ថានហិរញ្ញវត្ថុនានា ត្រូវបញ្ជូនរបាយការណ៍ឬបញ្ជូនលិខិតឆ្លើយតបមករដ្ឋបាលសារពើពន្ធក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងស្តីពីការផ្តល់ព័ត៌មានដែលទាក់ទិននឹងអ្នកជាប់ពន្ធ។

៤_បុគ្គលទាំងឡាយអាចរាយការណ៍មករដ្ឋបាលសារពើពន្ធនូវព័ត៌មានដែលពាក់ព័ន្ធនឹងពន្ធដារ។

៥_ការសម្ងាត់វិជ្ជាជីវៈមិនត្រូវបានរារាំងដល់ការអនុវត្តមាត្រានេះ និងមាត្រាដទៃទៀតនៃច្បាប់នេះ។

**មាត្រា២០៣ ._** កាតព្វកិច្ចចុះបញ្ជីនិងបច្ចុប្បន្នកម្ម

១_ បុគ្គលទាំងឡាយត្រូវចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេល១៥(ដប់ប្រាំ)ថ្ងៃ ក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ចឬសកម្មភាពផ្សេងទៀត រួមទាំងសកម្មភាពរបស់ស្ថាប័នឬអង្គការនានា ដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា៩នៃច្បាប់នេះ។

២_ បុគ្គលទាំងឡាយត្រូវជូនដំណឹងទៅរដ្ឋបាលសារពើពន្ធក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ក្រោយពីការផ្លាស់ប្តូរអាសយដ្ឋាន ទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម ការផ្ទេរ ការបញ្ឈប់អាជីវកម្ម សមាសភាពអ្នកគ្រប់គ្រង ឬអ្នកទទួលបន្ទុកកិច្ចការពន្ធដាររបស់សហគ្រាស។

៣_ វិធាននិងនីតិវិធីនៃការចុះបញ្ជីនិងការធ្វើបច្ចុប្បន្នកម្មត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



https://www.moj.gov.kh/kh/law-regular

**មាត្រា២០៤ .-** លិខិតបញ្ជាក់ការចុះបញ្ជីនិងលេខអត្តសញ្ញាណកម្មសារពើពន្ធ

១- នៅពេលបានអនុវត្តការចុះបញ្ជីរួចរាល់ហើយ រដ្ឋបាលសារពើពន្ធត្រូវចេញលិខិតបញ្ជាក់ការចុះបញ្ជីដែលមានចុះលេខអត្តសញ្ញាណកម្មសារពើពន្ធរបស់បុគ្គល។ លេខអត្តសញ្ញាណកម្មនេះត្រូវយកទៅប្រើលើគ្រប់ឯកសារទាក់ទិននឹងពន្ធដារ។

២- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវតែប្រើលេខអត្តសញ្ញាណកម្មក្នុងមាត្រានេះ។ រាល់កិច្ចសន្យាជាមួយស្ថាប័នរដ្ឋត្រូវតែមានចុះលេខអត្តសញ្ញាណកម្មសារពើពន្ធទើបចាត់ទុកជាបានការ។

**មាត្រា២០៥ .-** សិទ្ធិរបស់រដ្ឋបាលសារពើពន្ធក្នុងការចុះបញ្ជីអ្នកជាប់ពន្ធ

រដ្ឋបាលសារពើពន្ធមានសិទ្ធិចុះបញ្ជីចំពោះបុគ្គលទាំងឡាយដែលច្បាប់បានកំណត់ឱ្យចុះបញ្ជី ហើយពុំបានមកចុះបញ្ជី ក្នុងករណីនេះរដ្ឋបាលសារពើពន្ធអាចកំណត់កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជី។

## ផ្នែកទី៤
## លិខិតប្រកាសសារពើពន្ធ

**មាត្រា២០៦ .-** ការដាក់លិខិតប្រកាសសារពើពន្ធ

ការដាក់លិខិតប្រកាសសារពើពន្ធត្រូវបានកំណត់ដូចខាងក្រោម៖

១- អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក ត្រូវដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធតាមទម្រង់ ពេលវេលា និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់។

២- លិខិតប្រកាសសារពើពន្ធ ត្រូវចុះហត្ថលេខាដោយអ្នកជាប់ពន្ធឬតំណាងស្របច្បាប់របស់អ្នកជាប់ពន្ធ។

៣- អ្នកវិនិយោគទាំងអស់ ត្រូវដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែសម្រាប់ខែនីមួយៗ និងលិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំជាប់ពន្ធនោះ និងបង់ពន្ធអាករទាំងអស់ទៅតាមបទប្បញ្ញត្តិនៃពន្ធនីមួយៗ។

៤- អ្នកវិនិយោគទាំងអស់ ត្រូវភ្ជាប់នូវវិញ្ញាបនបត្ររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបញ្ជាក់ពីការគោរពប្រតិបត្តិជាមួយលិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំជាប់ពន្ធនោះ។

៥- អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក ឬអ្នកវិនិយោគទាំងអស់ អាចដាក់លិខិតប្រកាសសារពើពន្ធដូចមានចែងក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី៣នៃមាត្រានេះ តាមប្រព័ន្ធទទួលលិខិតប្រកាសអេឡិចត្រូនិករបស់រដ្ឋបាលសារពើពន្ធ ហើយមានតម្លៃស្មើគ្នានឹងលិខិតប្រកាសសារពើពន្ធជាលាយលក្ខណ៍អក្សរដែលជាច្បាប់ដើម។

**មាត្រា២០៧ .-** ការដាក់លិខិតប្រកាសព័ត៌មាននិងឯកសារផ្សេងទៀត

បុគ្គលណាមួយដែលបានបើកប្រាក់ឱ្យទៅបុគ្គលផ្សេងទៀត ត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធនូវលិខិតប្រកាសព័ត៌មាននិងឯកសារផ្សេងទៀតស្តីពីការបើកប្រាក់នោះទៅតាមបែបបទដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ។



https://www.moj.gov.kh/kh/law-regular

**មាត្រា២០៨ .-** តំណាងអ្នកជាប់ពន្ធ

១- អ្នកជាប់ពន្ធអាចធ្វើការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរទៅឱ្យបុគ្គលដែលជាតំណាងម្នាក់ទៀតឱ្យធ្វើសកម្មភាពជំនួសមុខខ្លួនក្នុងកិច្ចការនានាទាក់ទិននឹងពន្ធដារ។ អ្នកជាប់ពន្ធអាចកំណត់ព្រំដែនសិទ្ធិអំណាចនៃការផ្ទេរសិទ្ធិនេះ។ អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចទទួលខុសត្រូវដោយផ្ទាល់ចំពោះរាល់សកម្មភាពរបស់បុគ្គលដែលជាតំណាងស្របច្បាប់របស់ខ្លួន ឬបុគ្គលដែលបានទទួលការផ្ទេរសិទ្ធិពីខ្លួនរហូតដល់ពេលណាដែលរដ្ឋបាលសារពើពន្ធបានទទួលសេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សរពីអ្នកជាប់ពន្ធស្តីពីការលុបចោលនូវការផ្ទេរសិទ្ធិនោះ។

២- បុគ្គលដែលជាតំណាងអ្នកជាប់ពន្ធ ត្រូវមានសិទ្ធិជំនួសមុខឱ្យអ្នកជាប់ពន្ធដើម្បី៖

- ដាក់លិខិតប្រកាសសារពើពន្ធ
- បង្ហាញរបាយការណ៍ ឬលិខិតស្នាមផ្សេងៗ
- បង់ពន្ធអាករទាំងឡាយដែលកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារ
- ធ្វើបណ្តឹងតវ៉ា
- បំពេញរាល់កាតព្វកិច្ចដែលអ្នកជាប់ពន្ធត្រូវទទួលខុសត្រូវចំពោះមុខច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ។

៣- បុគ្គលដែលជាតំណាងរបស់អ្នកជាប់ពន្ធក្នុងអំឡុងពេល១៥(ដប់ប្រាំ)ថ្ងៃ ត្រូវផ្តល់ព័ត៌មានជូនរដ្ឋបាលសារពើពន្ធ ដោយភ្ជាប់មកនូវភស្តុតាងជាលាយលក្ខណ៍អក្សរនៃការផ្ទេរសិទ្ធិដែលមានសុពលភាព។

៤- បុគ្គលដែលទទួលអាជ្ញាបណ្ណជាភ្នាក់ងារសេវាកម្មពន្ធដារអាចជាតំណាងអ្នកជាប់ពន្ធនិងអាចធ្វើការផ្គត់ផ្គង់សេវាទាក់ទិននឹងពន្ធដារដល់អ្នកជាប់ពន្ធ។ វិធាននិងនីតិវិធីនៃការគ្រប់គ្រងភ្នាក់ងារសេវាកម្មពន្ធដារត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៥
## ការកំណត់ពន្ធ

**មាត្រា២០៩ .-** ការកំណត់ពន្ធ

ចំនួនប្រាក់ពន្ធត្រូវបានកំណត់ដូចខាងក្រោម៖

១- ក្នុងករណីដែលប្រាក់ពន្ធរបស់អ្នកជាប់ពន្ធត្រូវបានបង់តាមវិធីកាត់ទុក ហើយអ្នកជាប់ពន្ធគ្មានកាតព្វកិច្ចធ្វើប្រកាសសារពើពន្ធទេនោះ ការកំណត់ពន្ធរបស់អ្នកជាប់ពន្ធ គឺជាការកំណត់ចំនួនប្រាក់ពន្ធដែលបានកាត់ទុកនៅក្នុងឆ្នាំប្រតិទិន។

២- ក្នុងករណីដែលអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកមានកាតព្វកិច្ចត្រូវដាក់លិខិតប្រកាសសារពើពន្ធ ការកំណត់ពន្ធរបស់អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក គឺជាការកំណត់ពន្ធដែលអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកបានគណនានៅលើលិខិតប្រកាសសារពើពន្ធដែលដាក់ជូនរដ្ឋបាលសារពើពន្ធ។

៣- ក្នុងករណីដែលអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក មានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធ ប៉ុន្តែមិនបានដាក់លិខិតប្រកាស មិនបានរក្សាទុកឱ្យបានត្រឹមត្រូវនូវបញ្ជិកាគណនេយ្យឬឯកសារផ្សេងទៀតតាមតម្រូវ ឬមិនបានផ្តល់ព័ត៌មានចាំបាច់ជូនរដ្ឋបាលសារពើពន្ធដើម្បីកំណត់ពន្ធឱ្យបានត្រឹមត្រូវ ការកំណត់ពន្ធរបស់អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក គឺជាការកំណត់ពន្ធជាឯកតោភាគីដែលរដ្ឋបាលសារពើពន្ធបានធ្វើ និងបានប្រគល់ឱ្យបុគ្គលនោះ។ ការកំណត់ពន្ធជាឯកតោភាគីត្រូវផ្អែកលើ៖


https://www.moj.gov.kh/kh/law-regular

ក_ ព័ត៌មានដែលមានចុះនៅក្នុងលិខិតប្រកាសសារពើពន្ធនានាឬឯកសារផ្សេងទៀត ដែលអ្នកជាប់ពន្ធបានដាក់ជូនរដ្ឋបាលសារពើពន្ធ។

ខ_ ព័ត៌មានដែលមានចុះក្នុងលិខិតប្រកាសព័ត៌មាន។

គ_ ព័ត៌មានផ្សេងទៀតដែលរដ្ឋបាលសារពើពន្ធបានទទួល។

៤_ប្រសិនបើមានមូលដ្ឋានបញ្ជាក់ថា ការប្រមូលពន្ធអាចមានឧបសគ្គ រដ្ឋបាលសារពើពន្ធអាចធ្វើការកំណត់ពន្ធលើអ្នកជាប់ពន្ធនៅពេលណាមួយក៏បាន។

**មាត្រា២១០ ._** ការកំណត់ពន្ធឡើងវិញនិងរយៈពេលកំណត់ពន្ធឡើងវិញ

ការកំណត់ពន្ធឡើងវិញនិងរយៈពេលកំណត់ពន្ធឡើងវិញត្រូវដំណើរការដូចខាងក្រោម៖

១_ចំពោះការកំណត់ពន្ធដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រា២០៩នៃច្បាប់នេះ រដ្ឋបាលសារពើពន្ធអាចធ្វើការកំណត់ពន្ធឡើងវិញក្នុងរយៈពេល៣(បី)ឆ្នាំ បន្ទាប់ពីឆ្នាំប្រតិទិនដែលការកាត់ទុកបានកើតឡើង។

២_ចំពោះការកំណត់ពន្ធដូចមានចែងក្នុងកថាខណ្ឌទី២និងកថាខណ្ឌទី៣នៃមាត្រា២០៩នៃច្បាប់នេះ រដ្ឋបាលសារពើពន្ធ អាចធ្វើការកំណត់ពន្ធឡើងវិញក្នុងរយៈពេលណាមួយដូចខាងក្រោម៖

ក_ ក្នុងរយៈពេល៣(បី)ឆ្នាំ ក្រោយថ្ងៃដាក់លិខិតប្រកាសសារពើពន្ធ។

ខ_ ក្នុងរយៈពេល១០(ដប់)ឆ្នាំ ក្រោយកាលបរិច្ឆេទដែលតម្រូវឱ្យដាក់លិខិតប្រកាសសារពើពន្ធ ប្រសិនបើមានភស្តុតាងបញ្ជាក់ថា មានអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្ដីពីពន្ធដារ។

គ_ ក្នុងរយៈពេលណាមួយក៏បាន តាមការយល់ព្រមជាលាយលក្ខណ៍អក្សររបស់អ្នកជាប់ពន្ធ។

៣_ អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកអាចស្នើសុំធ្វើការកែតម្រូវលិខិតប្រកាសសារពើពន្ធក្នុងរយៈពេល ៣(បី)ឆ្នាំ ក្រោយកាលបរិច្ឆេទនៃការដាក់លិខិតប្រកាសសារពើពន្ធតាមកថាខណ្ឌទី២នៃមាត្រា២០៩នៃច្បាប់នេះ ដោយផ្អែកលើមូលដ្ឋាននៃការភាន់ច្រឡំឬការភ្លេចភ្លាំងដែលអ្នកជាប់ពន្ធបានធ្វើនៅក្នុងលិខិតប្រកាសពីមុន។ ប្រសិនបើលទ្ធផលប្រកាសសារពើពន្ធកែតម្រូវនោះបណ្ដាលឱ្យមានការបង្វិលសងប្រាក់ពន្ធ ឬឥណទានពន្ធ រដ្ឋបាលសារពើពន្ធអាចធ្វើការពិនិត្យបញ្ជាក់តាមការធ្វើសវនកម្ម។

៤_ អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកអាចស្នើសុំឱ្យរដ្ឋបាលសារពើពន្ធធ្វើការកែតម្រូវការកំណត់ពន្ធឡើងវិញក្នុងរយៈពេល៣(បី)ឆ្នាំ ក្រោយកាលបរិច្ឆេទដែលរដ្ឋបាលសារពើពន្ធកំណត់ពន្ធឡើងវិញ ដោយផ្អែកលើព័ត៌មានបន្ថែមដែលអ្នកជាប់ពន្ធឬរដ្ឋបាលសារពើពន្ធមិនបានទទួលក្នុងពេលកំណត់ពន្ធឡើងវិញនោះ។

៥_ ក្នុងករណីដែលអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកធ្វើការកែតម្រូវការកំណត់ពន្ធរបស់ខ្លួន ឬស្នើសុំឱ្យរដ្ឋបាលសារពើពន្ធកែតម្រូវការកំណត់ពន្ធឡើងវិញ អាជ្ញាយុកាលនៃការកំណត់ពន្ធឡើងវិញក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២នៃមាត្រានេះ ត្រូវចាប់ផ្ដើមគិតពីកាលបរិច្ឆេទនៃការដាក់លិខិតប្រកាសសារពើពន្ធកែតម្រូវ ឬកាលបរិច្ឆេទដែលរដ្ឋបាលសារពើពន្ធធ្វើការកែតម្រូវការកំណត់ពន្ធឡើងវិញ។

៦_ វិធាននិងនីតិវិធីនៃការកំណត់ពន្ធឡើងវិញនិងរយៈពេលកំណត់ពន្ធឡើងវិញត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



https://www.moj.gov.kh/kh/law-regular

**មាត្រា២១១ .-** នីតិវិធីនៃការកំណត់ពន្ធឡើងវិញ

ការកំណត់ពន្ធឡើងវិញត្រូវបានដំណើរការតាមនីតិវិធីដូចខាងក្រោម៖

១- រដ្ឋបាលសារពើពន្ធត្រូវផ្ញើលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញដល់អ្នកជាប់ពន្ធ។

២- អ្នកជាប់ពន្ធមានរយៈពេល៣០(សាមសិប)ថ្ងៃ ដើម្បីឆ្លើយតបចំពោះការកំណត់ពន្ធឡើងវិញទៅអង្គភាពដែលទទួលបន្ទុកធ្វើការកំណត់ពន្ធឡើងវិញនោះ។ ក្នុងរយៈពេលនេះ អ្នកជាប់ពន្ធអាចទទួលយក ឬជំទាស់ ចំពោះការកំណត់ពន្ធឡើងវិញ។ អ្នកជាប់ពន្ធត្រូវចាត់ទុកថាយល់ព្រមចំពោះការកំណត់ពន្ធឡើងវិញ ប្រសិនបើពុំបានឆ្លើយតប។

៣- ប្រសិនបើមានការជំទាស់ចំពោះការកំណត់ពន្ធឡើងវិញ អ្នកជាប់ពន្ធត្រូវដាក់ពាក្យតវ៉ាទៅអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ តាមនីតិវិធីដូចមានចែងក្នុងមាត្រា២៣៦នៃច្បាប់នេះ។

៤- អង្គភាពទទួលបន្ទុកការកំណត់ពន្ធឡើងវិញរបស់អគ្គនាយកដ្ឋានពន្ធដារ ត្រូវបញ្ជូនលទ្ធផលនៃការកំណត់ពន្ធឡើងវិញទៅអង្គភាពប្រមូលពន្ធក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ក្រោយការចេញលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញ។

**មាត្រា២១២ .-** បន្ទុកភស្តុតាង

១- ក្នុងករណីដែលអ្នកជាប់ពន្ធមិនបានរក្សាទុកឯកសារគ្រប់គ្រាន់ ឬក៏មិនបានផ្តល់ព័ត៌មានគ្រប់គ្រាន់ រដ្ឋបាលសារពើពន្ធមានសិទ្ធិកំណត់ពន្ធលើអ្នកជាប់ពន្ធដោយផ្អែកលើមូលដ្ឋាននៃព័ត៌មានជាក់លាក់ដែលរដ្ឋបាលសារពើពន្ធមាន។

២- ក្នុងករណីដែលប្រាក់ចំណូលជាប់ពន្ធឬប្រាក់ចំណូលដែលបានប្រកាសដោយអ្នកជាប់ពន្ធមានភាពខុសគ្នាច្រើនធៀបទៅនឹងការទិញទ្រព្យសកម្មឬវត្ថុនានាដែលធ្វើឱ្យឃើញចំណាយរបស់អ្នកជាប់ពន្ធលេចធ្លោឡើងនោះ រដ្ឋបាលសារពើពន្ធមានសិទ្ធិកំណត់ពន្ធដោយផ្អែកលើមូលដ្ឋាននៃប្រាក់ចំណូលប៉ាន់ស្មានសមស្របទៅនឹងទំហំនៃចំណាយដើម្បីទិញទ្រព្យសកម្មឬវត្ថុនានាដែលលេចធ្លោនោះ។

៣- ការស្វែងរកភស្តុតាងនានាដើម្បីបញ្ជាក់ថា ប្រាក់ពន្ធដែលរដ្ឋបាលសារពើពន្ធបានកំណត់ដូចក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២នៃមាត្រានេះ មិនត្រឹមត្រូវ គឺជាបន្ទុករបស់អ្នកជាប់ពន្ធ។

## ផ្នែកទី៦
## ការប្រមូលពន្ធ

**មាត្រា២១៣ .-** ការបង់ពន្ធ

ការបង់ពន្ធត្រូវបានកំណត់ដូចខាងក្រោម៖

១- ប្រាក់ពន្ធត្រូវដល់កំណត់និងត្រូវបង់នៅក្នុងរយៈពេលដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានតម្រូវឱ្យធ្វើការដាក់លិខិតប្រកាសសារពើពន្ធ។

២- បំណុលពន្ធត្រូវដល់កំណត់ និងត្រូវបង់ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ក្រោយពីការប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធ។

៣- ប្រាក់ពន្ធត្រូវដល់កំណត់និងត្រូវបង់ក្នុងរយៈពេល៣(បី)ថ្ងៃ ក្រោយពីការប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធដូចមានចែងក្នុងកថាខណ្ឌទី៤នៃមាត្រា២០៩នៃច្បាប់នេះ។


https://www.moj.gov.kh/kh/law-regular

៤_ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញប្រកាសនូវវិធាននិងនីតិវិធីដើម្បីៈ

- កំណត់កាលបរិច្ឆេទទារបំណុលពន្ធដើម្បីចៀសវាងការខាតបង់ដោយទារបំណុលពន្ធមិនបាន
- ចាត់ទុកបំណុលពន្ធជាប្រាក់ពន្ធដែលមិនអាចប្រមូលបាន។

៥_ អាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុលពន្ធមានរយៈពេល១០(ដប់)ឆ្នាំ ចាប់ពីថ្ងៃដែលបំណុលពន្ធត្រូវបានជូនដំណឹងទៅអ្នកជាប់ពន្ធ។ វិធាននិងនីតិវិធីនៃការផ្អាកឬការបង្អង់អាជ្ញាយុកាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២១៤._** ការទទួលខុសត្រូវរបស់អភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករ

ប្រសិនបើអភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិកររបស់សហគ្រាសណាមួយដឹងឮ ឬមានចេតនាធ្វើឱ្យសហគ្រាសមិនរាយការណ៍ ឬរាយការណ៍បន្ថយនូវប្រាក់ពន្ធដោយរំលោភទៅលើបទប្បញ្ញត្តិស្តីពីពន្ធដារ ឬមិនឱ្យបង់ពន្ធកាត់ទុកជូនរដ្ឋបាលសារពើពន្ធ អភិបាល ឬបណ្ណាធិការ ឬកម្មសិទ្ធិករទាំងនោះត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះប្រាក់ពន្ធដែលត្រូវបង់។

**មាត្រា២១៥ ._** ការផ្ទេរអាជីវកម្មឬការផ្ទេរភាគហ៊ុននិងការរួមបញ្ចូលគ្នានៃសហគ្រាស

១_ ក្នុងករណីមានការផ្ទេរអាជីវកម្ម ឬការផ្ទេរភាគហ៊ុន ម្ចាស់កម្មសិទ្ធិថ្មីត្រូវទទួលខុសត្រូវចំពោះបំណុលពន្ធទាំងអស់របស់អាជីវកម្ម ឬសហគ្រាស។

២_ ក្នុងករណីការរំលាយបញ្ចូលគ្នានៃសហគ្រាស២(ពីរ)ឬច្រើន សហគ្រាសដែលនៅបន្តឬកើតពីការរំលាយបញ្ចូលគ្នានៃសហគ្រាស២(ពីរ)ឬច្រើន ត្រូវទទួលខុសត្រូវចំពោះបំណុលពន្ធទាំងអស់។

## ផ្នែកទី៧
## សិទ្ធិអំណាចរបស់រដ្ឋបាលសារពើពន្ធក្នុងការប្រមូលប្រាក់ពន្ធ

**មាត្រា២១៦ ._** លិខិតជូនដំណឹងទារបំណុលពន្ធនិងលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ

១_ ដូចមានចែងក្នុងកថាខណ្ឌទី៤នៃមាត្រា២១១នៃច្បាប់នេះ រដ្ឋបាលសារពើពន្ធត្រូវផ្ញើលិខិតជូនដំណឹងទារបំណុលពន្ធដែលបញ្ជាក់អំពីចំនួនប្រាក់ពន្ធ ពន្ធបន្ថែម ការប្រាក់ និងការផាកពិន័យជាប្រាក់ទៅអ្នកជាប់ពន្ធ។ អ្នកជាប់ពន្ធមានរយៈពេល៣០(សាមសិប)ថ្ងៃ ដើម្បីធ្វើការទូទាត់បំណុលពន្ធដូចមានចែងក្នុងកថាខណ្ឌនេះ។

២_ ក្នុងករណីអ្នកជាប់ពន្ធមិនបានទូទាត់បំណុលពន្ធដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ រដ្ឋបាលសារពើពន្ធត្រូវផ្ញើលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធទៅអ្នកជាប់ពន្ធ។

៣_ រដ្ឋបាលសារពើពន្ធអាចអនុវត្តវិធានការតឹងទារដូចមានចែងក្នុងមាត្រា២១៧ មាត្រា២១៨ មាត្រា២២០ មាត្រា២២១ និងមាត្រា២២២នៃច្បាប់នេះ យ៉ាងតិច១៥(ដប់ប្រាំ)ថ្ងៃ ក្រោយការប្រគល់លិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រានេះ។


https://www.moj.gov.kh/kh/law-regular

**មាត្រា២១៧ .-** សិទ្ធិឃាត់ទុក ចាប់យក និងឃុំគ្រងលើទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ

សិទ្ធិឃាត់ទុក ចាប់យក និងឃុំគ្រងលើទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធត្រូវបានកំណត់ដូចខាងក្រោម៖

១- ប្រសិនបើបុគ្គលដែលមានកាតព្វកិច្ចបង់ពន្ធតាមការតម្រូវនៃបទប្បញ្ញត្តិស្តីពីពន្ធដារ ធ្វេសប្រហែស ឬបដិសេធមិនព្រមបង់ពន្ធក្រោយពេលដែលលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធត្រូវបានប្រគល់ត្រឹមត្រូវ រដ្ឋបាលសារពើពន្ធមានសិទ្ធិឃាត់ទុក ចាប់យក និងឃុំគ្រងលើទ្រព្យសម្បត្តិបុគ្គលនោះក្នុងកម្រិតតម្លៃសមស្រប នឹងបំណុលពន្ធ។ រដ្ឋបាលសារពើពន្ធត្រូវផ្ញើលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធទៅអ្នកជាប់ពន្ធយ៉ាងតិច ១៥(ដប់ប្រាំ)ថ្ងៃ មុនអនុវត្តវិធានការតឹងទារដូចមានចែងក្នុងមាត្រា២១៨ មាត្រា២២០ មាត្រា២២១ និង មាត្រា២២២ នៃច្បាប់នេះ។

២- សិទ្ធិឃាត់ទុក ចាប់យក និងឃុំគ្រងលើទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធកើតមានឡើងនៅថ្ងៃដែល លិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធត្រូវបានប្រគល់ទៅឱ្យអ្នកជាប់ពន្ធដូចមានចែងក្នុងមាត្រា១៩៨ នៃច្បាប់នេះ។

៣- បើលក្ខខណ្ឌទាំងឡាយនៃមាត្រានេះត្រូវបានបំពេញត្រឹមត្រូវហើយនោះ សិទ្ធិឃាត់ទុក ចាប់យក និងឃុំគ្រងលើទ្រព្យសម្បត្តិដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះមានសុពលភាពនិងអាទិភាពលើសិទ្ធិ ដទៃទៀតទាំងអស់ដែលមានពីមុនមក ឬដែលកើតឡើងក្រោយសិទ្ធិឃាត់ទុក ចាប់យក និងឃុំគ្រងលើ ទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ លើកលែងតែមានការកំណត់ផ្ទុយពីនេះក្នុងច្បាប់ស្តីពីក្ស័យធននិងបទប្បញ្ញត្តិ ពាក់ព័ន្ធនឹងសិទ្ធិប្រាតិភោគ។ រដ្ឋបាលសារពើពន្ធ ត្រូវធ្វើសេចក្តីប្រកាសផ្សាយជាសាធារណៈអំពីទ្រព្យសម្បត្តិ របស់អ្នកជាប់ពន្ធដែលត្រូវបានសម្រេចឃាត់ទុក ចាប់យក និងឃុំគ្រងដោយរដ្ឋបាលសារពើពន្ធ។ រាល់សិទ្ធិ ប្រាតិភោគដែលត្រូវបានបង្កើតឡើងលើទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ ដែលត្រូវបានសម្រេចឃាត់ទុក ចាប់យក និងឃុំគ្រងដោយរដ្ឋបាលសារពើពន្ធនៅក្រោយកាលបរិច្ឆេទនៃការប្រកាសផ្សាយជាសាធារណៈរបស់ រដ្ឋបាលសារពើពន្ធ មិនអាចយកមកតតាំងជាមួយនឹងសិទ្ធិអាទិភាពរបស់រដ្ឋបាលសារពើពន្ធលើទ្រព្យសម្បត្តិ នោះបានឡើយ។ បែបបទនិងនីតិវិធីនៃការប្រកាសផ្សាយជាសាធារណៈនូវទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ ដែលត្រូវឃាត់ទុក ចាប់យក និងឃុំគ្រងដោយរដ្ឋបាលសារពើពន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៤- សោហ៊ុយក្នុងការឃុំគ្រង ត្រួតពិនិត្យ និងថែរក្សាលើទ្រព្យសម្បត្តិនេះ គឺជាបន្ទុករបស់អ្នកជាប់ពន្ធ។

៥- បុគ្គលទាំងឡាយអាចធ្វើការតវ៉ាទៅរដ្ឋបាលសារពើពន្ធដើម្បីសុំឱ្យលើកសិទ្ធិឃាត់ទុក ចាប់យក និងឃុំគ្រងលើទ្រព្យសម្បត្តិរបស់ខ្លួនដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ដោយលើកឡើងនូវកំហុសឆ្គង ក្នុងការដាក់សិទ្ធិនោះ។

៦- ប្រសិនបើរដ្ឋបាលសារពើពន្ធបានពិនិត្យឃើញថា ការដាក់សិទ្ធិឃាត់ទុក ចាប់យក និងឃុំគ្រង លើទ្រព្យសម្បត្តិនោះមានការខុសឆ្គង រដ្ឋបាលសារពើពន្ធត្រូវចេញលិខិតបញ្ជាក់អំពីការលើកសិទ្ធិឃាត់ទុក ចាប់យក និងឃុំគ្រងលើទ្រព្យសម្បត្តិក្នុងរយៈពេល១០(ដប់)ថ្ងៃ បន្ទាប់ពីពិនិត្យឃើញ ព្រមទាំងចុះក្នុង លិខិតបញ្ជាក់នោះថា ការដាក់សិទ្ធិឃុំគ្រងនោះមានការខុសឆ្គង។



https://www.moj.gov.kh/kh/law-regular

**មាត្រា២១៨ .-** សិទ្ធិប្រើប្រាស់និងអាស្រ័យផល សិទ្ធិចាត់ចែងជាបណ្ដោះអាសន្ន និងការរឹបអូស

សិទ្ធិប្រើប្រាស់និងអាស្រ័យផល សិទ្ធិចាត់ចែងជាបណ្ដោះអាសន្ន និងការរឹបអូសទ្រព្យសម្បត្តិអ្នកជាប់ពន្ធ ត្រូវបានកំណត់ដូចខាងក្រោម៖

១- ក្នុងករណីចាំបាច់ និងដើម្បីធានានូវការទូទាត់បំណុលពន្ធ រដ្ឋបាលសារពើពន្ធមានសិទ្ធិប្រើប្រាស់និងអាស្រ័យផលលើទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធដែលត្រូវបានឃាត់ទុក។

២- ក្រៅពីសិទ្ធិប្រើប្រាស់និងអាស្រ័យផលដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ រដ្ឋបាលសារពើពន្ធអាចប្ដឹងទៅតុលាការដើម្បីរឹបអូសទ្រព្យសម្បត្តិអ្នកជាប់ពន្ធក្នុងគោលដៅធានាការទូទាត់បំណុលពន្ធ។ ក្នុងអំឡុងពេលដែលមិនទាន់មានសេចក្ដីសម្រេចរឹបអូសទ្រព្យសម្បត្តិអ្នកជាប់ពន្ធជាស្ថាពរ និងក្នុងករណីដែលទទួលបានការអនុញ្ញាតតាមដីកាសម្រេចពីតុលាការដែលទទួលពាក្យបណ្ដឹង រដ្ឋបាលសារពើពន្ធអាចធ្វើការចាត់ចែងជាបណ្ដោះអាសន្ននូវទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធក្នុងទម្រង់ជាការលក់ឡាយឡុង ហើយប្រាក់ដែលបានមកពីការចាត់ចែងជាបណ្ដោះអាសន្នត្រូវរក្សាទុកនៅក្នុងគណនីបណ្ដោះអាសន្នមួយរបស់រដ្ឋបាលសារពើពន្ធ។

៣-បុគ្គលដែលមានភារៈកាន់កាប់និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធដែលត្រូវរដ្ឋបាលសារពើពន្ធរឹបអូសដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រានេះ មិនអាចបង្វិលទ្រព្យសម្បត្តិនោះទៅឱ្យអ្នកជាប់ពន្ធវិញ ឬក៏យកទ្រព្យសម្បត្តិនោះទៅធ្វើការទូទាត់ផ្សេងៗបានទេ លើកលែងតែការទូទាត់ដែលរដ្ឋបាលសារពើពន្ធបានអនុញ្ញាត។

៤- ចំពោះទ្រព្យសម្បត្តិជាសាច់ប្រាក់ រដ្ឋបាលសារពើពន្ធអាចរឹបអូសសាច់ប្រាក់របស់អ្នកជាប់ពន្ធ ឬសាច់ប្រាក់ដែលអ្នកជាប់ពន្ធនឹងត្រូវទទួលបាន ដោយមិនចាំបាច់អនុវត្តតាមនីតិវិធីដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រានេះ។

**មាត្រា២១៩ .-** ការចាត់ចែងលើទ្រព្យសម្បត្តិដែលបានរឹបអូស

ក្នុងករណីដែលមានការលក់នូវទ្រព្យសម្បត្តិបន្ទាប់ពីមានការរឹបអូសទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ ចំនួនទឹកប្រាក់លក់បានដែលលើសអំពីបំណុលពន្ធរបស់អ្នកជាប់ពន្ធនៅក្រោមច្បាប់នេះ ត្រូវបង្វិលទៅឱ្យអ្នកជាប់ពន្ធវិញ លើកលែងតែមានការចាត់ចែងផ្សេងពីនេះដោយតុលាការស្របតាមច្បាប់ជាធរមាន។

**មាត្រា២២០ .-** ការឃាត់ទុកគណនីធនាគារ

១- រដ្ឋបាលសារពើពន្ធអាចឃាត់ទុកគណនីរបស់អ្នកជាប់ពន្ធនៅធនាគារតាមលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ ហើយដែលមានប្រសិទ្ធភាពអនុវត្តភ្លាមក្រោយពីការប្រគល់លិខិតនោះទៅឱ្យធនាគារ។ ការឃាត់ទុកគណនីធនាគារក្នុងមាត្រានេះ រួមបញ្ចូលទាំងការឃាត់ទុកប្រតិបត្តិការតាមគ្រប់ទម្រង់។

២- តាមរយៈការជូនដំណឹងឱ្យឃាត់ទុកគណនីធនាគារនេះ ធនាគារមិនអាចបើកគណនីថ្មីទៀតឱ្យអ្នកជាប់ពន្ធដដែលបានទេ ហើយក៏មិនអាចធ្វើការទូទាត់ផ្សេងៗចេញពីគណនីនោះបានឡើយ លើកលែងតែការបង់ប្រាក់ដែលរដ្ឋបាលសារពើពន្ធកំណត់ឱ្យដើម្បីទូទាត់ប្រាក់ពន្ធត្រូវបង់ ពន្ធបន្ថែម ការប្រាក់ និងការផាកពិន័យជាប្រាក់ផ្សេងទៀត។

៣- គណនីធនាគារដែលបានឃាត់ទុកអាចបើកឱ្យប្រើវិញបាន លុះត្រាតែមានលិខិតជូនដំណឹងពីរដ្ឋបាលសារពើពន្ធ។



https://www.moj.gov.kh/kh/law-regular

៤_ ធនាគារដែលមិនបានអនុវត្តតាមលិខិតជូនដំណឹងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ត្រូវទទួលខុសត្រូវចំពោះរដ្ឋបាលសារពើពន្ធនូវកម្រិតទឹកប្រាក់ដែលមាននៅក្នុងគណនីរបស់អ្នកជាប់ពន្ធនៅពេលដែលលិខិតជូនដំណឹងត្រូវបានប្រគល់ឱ្យ។

**មាត្រា២២១ ._** ការបញ្ឈប់ប្រតិបត្តិការនាំចេញនាំចូល

១_ រដ្ឋបាលសារពើពន្ធអាចបញ្ឈប់ប្រតិបត្តិការនាំចេញនាំចូល។ ការបញ្ឈប់ប្រតិបត្តិការនាំចេញនាំចូល សំដៅដល់ ការឃាត់ទុកដោយរដ្ឋបាលគយនូវទំនិញនាំចូលរបស់អ្នកជាប់ពន្ធ និងទំនិញដែលត្រូវនាំចេញដោយអ្នកជាប់ពន្ធតាមលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ ដែលមានប្រសិទ្ធភាពអនុវត្តភ្លាមក្រោយពេលដែលលិខិតនោះបានប្រគល់ឱ្យរដ្ឋបាលគយ។

២_ រដ្ឋបាលសារពើពន្ធអាចរឹបអូស ប្រើប្រាស់និងអាស្រ័យផល និងចាត់ចែងជាបណ្តោះអាសន្ននូវទំនិញរបស់អ្នកជាប់ពន្ធដែលបានឃាត់ទុកដោយរដ្ឋបាលគយ ទៅតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា២១៨ នៃច្បាប់នេះ។

៣_ ការអនុញ្ញាតឱ្យប្រតិបត្តិការនាំចេញនាំចូលរួចពីការបញ្ឈប់ ត្រូវអនុវត្តតាមលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ។

៤_ ទំនិញឃាត់ទុកដោយរដ្ឋបាលគយដែលមិនមែនជារបស់អ្នកជាប់ពន្ធ ត្រូវបានរួចផុតពីការឃាត់ទុកដោយមានការយល់ព្រមពីរដ្ឋបាលសារពើពន្ធ។

**មាត្រា២២២ ._** ការទុកជាមោឃៈនូវលិខិតអនុញ្ញាត និងអាជ្ញាបណ្ណ

រដ្ឋបាលសារពើពន្ធអាចចេញលិខិតជូនដំណឹងទៅកាន់អាជ្ញាធរមានសមត្ថកិច្ចស្នើសុំឱ្យទុកជាមោឃៈនូវលិខិតអនុញ្ញាតនិងអាជ្ញាបណ្ណផ្សេងៗរបស់អ្នកជាប់ពន្ធ ដើម្បីអនុវត្តសកម្មភាពណាមួយ។

## ជំពូកទី១៨
## ទោសប្បញ្ញត្តិ
### ផ្នែកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា២២៣ ._** ការធ្វេសប្រហែស

អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក ត្រូវបានចាត់ទុកថាមានការធ្វេសប្រហែស ប្រសិនបើប្រាក់ពន្ធបានបង់មានចំនួនតិចជាងប្រាក់ពន្ធដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារមិនលើសពី១០(ដប់)ភាគរយ ឬមិនបានបង់ពន្ធតាមកាលបរិច្ឆេទដែលច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតបានកំណត់។

**មាត្រា២២៤ ._** ការធ្វេសប្រហែសធ្ងន់ធ្ងរ

អ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុក ត្រូវបានចាត់ទុកថាមានការធ្វេសប្រហែសធ្ងន់ធ្ងរ ប្រសិនបើប្រាក់ពន្ធបានបង់មានចំនួនតិចជាងប្រាក់ពន្ធដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារលើសពី១០(ដប់)ភាគរយ។



https://www.moj.gov.kh/kh/law-regular

**មាត្រា២២៥ ._** អំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ

ត្រូវបានចាត់ទុកជាអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ចំពោះអំពើដែលប្រព្រឹត្តផ្ទុយពីការកំណត់របស់ច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតដូចខាងក្រោម៖

១_ ការមិនបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ស្របតាមការកំណត់របស់ច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត។

២_ ការមិនបានជូនដំណឹងទៅរដ្ឋបាលសារពើពន្ធអំពីការផ្លាស់ប្តូរព័ត៌មាននៃការចុះបញ្ជី។

៣_ ការមិនបានដាក់លិខិតប្រកាសសារពើពន្ធ។

៤_ ការមិនបានប្រើប្រាស់ប្រព័ន្ធកត់ត្រាដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ។

៥_ ការមិនបានចេញវិក្កយបត្រ។

៦_ ការមិនផ្តល់ព័ត៌មានឬមិនបញ្ជូនរបាយការណ៍តាមការស្នើសុំ។

៧_ ការមិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធធ្វើការពិនិត្យបញ្ជិកាគណនេយ្យឬឯកសារផ្សេងៗ។

៨_ ការមិនបានរក្សាបញ្ជិកាគណនេយ្យនិងឯកសារផ្សេងទៀត។

៩_ ការព្យាយាមរារាំងការកំណត់និងការប្រមូលពន្ធ។

១០_ ការកសាងឬផ្តល់នូវកំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានក្លែងបន្លំ។

១១_ ការលាក់ទុកឬបំផ្លាញចោលដោយចេតនានូវបញ្ជិកាគណនេយ្យ កំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានផ្សេងៗ។

១២_ ការចេញវិក្កយបត្រក្លែងបន្លំ។

១៣_ ការមិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធចូលគ្រឹះស្ថានអាជីវកម្មដើម្បីកំណត់និងប្រមូលពន្ធ។

**មាត្រា២២៦ ._** ការគេចវេះពន្ធ

១_ ការគេចវេះពន្ធ គឺជាអំពើណាមួយដែលបានប្រព្រឹត្តឡើងដោយចេតនានិងមានការរៀបចំទុកជាមុនដែលនាំឱ្យបាត់ប្រាក់ពន្ធដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវឱ្យបង់។

២_ ត្រូវបានចាត់ទុកថាជាការគេចវេះពន្ធផងដែរចំពោះករណីណាមួយដូចខាងក្រោម៖

- ក_ ការធ្វេសប្រហែសធ្ងន់ធ្ងរដូចមានចែងក្នុងមាត្រា២២៤នៃច្បាប់នេះ ដែលត្រូវបានប្រព្រឹត្តឡើងពីរលើកដាច់ពីគ្នាក្នុងរយៈពេល៣(បី)ឆ្នាំនៃឆ្នាំប្រតិទិន។
- ខ_ ការធ្វេសប្រហែសធ្ងន់ធ្ងរដូចមានចែងក្នុងមាត្រា២២៤នៃច្បាប់នេះ ដែលត្រូវបានប្រព្រឹត្តឡើងបីលើកឬច្រើនជាងនេះដាច់ពីគ្នាក្នុងរយៈពេល១០(ដប់)ឆ្នាំនៃឆ្នាំប្រតិទិន។

**មាត្រា២២៧ ._** មូលហេតុនៃការរំលត់បណ្តឹងអាជ្ញា

១_ ការសម្របសម្រួលជាមួយរដ្ឋបាលសារពើពន្ធ តាមរយៈការបង់ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់នាំឱ្យបណ្តឹងអាជ្ញារលត់ចំពោះបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។ ក្នុងករណីដែលរដ្ឋបាលសារពើពន្ធយល់ព្រមធ្វើការសម្របសម្រួល រដ្ឋបាលសារពើពន្ធត្រូវធ្វើកំណត់ហេតុអំពីការសម្របសម្រួលនេះហើយបញ្ជូនទៅស្ថាប័នអយ្យការ ឬស្ថាប័នតុលាការដែលមានសមត្ថកិច្ច។

២_ បទប្បញ្ញត្តិនៃកថាខណ្ឌទី១នៃមាត្រានេះ មិនត្រូវយកមកអនុវត្តឡើយចំពោះបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។


https://www.moj.gov.kh/kh/law-regular

## ផ្នែកទី២
## សិទ្ធិអំណាចរបស់រដ្ឋបាលសារពើពន្ធ

**មាត្រា២២៨ .-** សមត្ថកិច្ចក្នុងការកសាងសំណុំរឿងព្រហ្មទណ្ឌ

១- រដ្ឋបាលសារពើពន្ធជាស្ថាប័នតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការស៊ើបអង្កេតនិងការកសាងសំណុំរឿងពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដោយអនុវត្តស្របតាមច្បាប់នេះ និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

២- រដ្ឋបាលសារពើពន្ធ ក៏អាចមានសមត្ថកិច្ចផងដែរក្នុងការស៊ើបអង្កេត និងកសាងសំណុំរឿងទាក់ទិននឹងបទល្មើសព្រហ្មទណ្ឌផ្សេងទៀតដែលមានការពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ប្រសិនបើមានការអនុញ្ញាតពីព្រះរាជអាជ្ញា។

**មាត្រា២២៩ .-** នីតិសម្បទាជានគរបាលយុត្តិធម៌របស់មន្ត្រីពន្ធដារ

១- មន្ត្រីពន្ធដារទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

២- បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីពន្ធដារ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៣- រាល់ប្រតិបត្តិការរបស់មន្ត្រីពន្ធដារ ដែលពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ រដ្ឋបាលសារពើពន្ធមានសិទ្ធិស្នើសុំកិច្ចសហការពីស្ថាប័នមានសមត្ថកិច្ចដើម្បីចូលរួមបង្ក្រាបបទល្មើសលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

**មាត្រា២៣០ .-** អំណាចក្នុងការស៊ើបអង្កេត

មន្ត្រីពន្ធដារមានអំណាចក្នុងការស៊ើបអង្កេតដូចខាងក្រោម៖

១- មន្ត្រីពន្ធដារមានអំណាចចូលទៅក្នុងគ្រឹះស្ថានអាជីវកម្មឬទីកន្លែងដែលត្រូវបានចាត់ទុកថាជាគ្រឹះស្ថានអាជីវកម្មដើម្បីពិនិត្យបញ្ជីគណនេយ្យ លិខិតប្រកាសសារពើពន្ធគ្រប់ប្រភេទ និងឯកសារពាក់ព័ន្ធផ្សេងៗទៀតដើម្បីកំណត់ពន្ធ។ ការចូលទៅក្នុងគ្រឹះស្ថានអាជីវកម្មដូចមានចែងក្នុងកថាខណ្ឌនេះ ត្រូវធ្វើឡើងនៅក្នុងម៉ោងអាជីវកម្ម ឬនៅគ្រប់ពេលវេលាដោយអនុវត្តតាមដីការបស់ស្ថាប័នអយ្យការឬស្ថាប័នតុលាការដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

២- មន្ត្រីពន្ធដារដែលបានចូលដោយស្របច្បាប់ទៅក្នុងគ្រឹះស្ថានអាជីវកម្មឬទីកន្លែងដែលត្រូវបានចាត់ទុកថាជាគ្រឹះស្ថានអាជីវកម្មដូចដែលមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះមានសិទ្ធិ៖

ក- ធ្វើសម្រង់ ឬចម្លងឯកសារនានា រួមទាំងឯកសារអេឡិចត្រូនិកដែលស្ថិតនៅក្នុងកន្លែងនោះ។

ខ- ចាប់យកឯកសារនានា ឬវត្ថុតាងដទៃទៀតដែលអាចក្លាយជាព័ត៌មានឬភស្តុតាងសម្រាប់កំណត់ប្រាក់ពន្ធត្រូវបង់របស់បុគ្គលណាម្នាក់ ដោយត្រូវធ្វើកំណត់ហេតុស្តីពីការចាប់យក។

គ- ដាក់ឧបករណ៍សម្រាប់ត្រួតពិនិត្យផ្សេងៗ ឬបោះត្រាបិទសម្គាល់ ឃាត់ទុកទំនិញ ប្រសិនបើមានជាប់ទាក់ទិនដល់ការអនុវត្តពន្ធណាមួយ។

ឃ- ធ្វើសារពើភណ្ឌទ្រព្យសកម្ម វត្ថុធាតុដើម ផលិតផលកំពុងផលិត ផលិតផលសម្រេច និងស្តុក/សន្និធិដទៃទៀត។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



https://www.moj.gov.kh/kh/law-regular

ង- ចាប់យក ឃាត់ទុក ឬឃុំគ្រងទ្រព្យសម្បត្តិអ្នកជាប់ពន្ធដើម្បីធានាបំណុលពន្ធ។

ច- ឃាត់ខ្លួនអ្នកជាប់ពន្ធដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដោយអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

៣- ក្នុងគ្រប់ករណីទាំងអស់ នៅពេលមានបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារត្រូវបានរកឃើញនៅក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតរបស់មន្ត្រីពន្ធដារ ប្រតិបត្តិការរបស់មន្ត្រីពន្ធដារទាក់ទិននឹងការប្រមូលភស្តុតាង ការធ្វើកំណត់ហេតុ និងការអនុវត្តរាល់កិច្ចនីតិវិធីព្រហ្មទណ្ឌចាំបាច់ដទៃទៀត ដោយរួមទាំងការឃាត់ខ្លួនជនសង្ស័យផង ត្រូវធ្វើឡើងដោយមន្ត្រីពន្ធដារដែលមាននីតិសម្បទាជាមន្ត្រីឬភ្នាក់ងារនគរបាលយុត្តិធម៌ ហើយត្រូវអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

៤- រដ្ឋបាលសារពើពន្ធ អាចតម្រូវឱ្យស្ថាប័នធនាគារដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ផ្តល់ព័ត៌មានអំពីគណនីរបស់អ្នកជាប់ពន្ធឬបុគ្គលពាក់ព័ន្ធនៅធនាគារ ឬឃាត់ទុកគណនីរបស់អ្នកជាប់ពន្ធឬបុគ្គលពាក់ព័ន្ធនោះក្នុងករណីមានភស្តុតាងបញ្ជាក់ថាបានប្រព្រឹត្តអំពើគេចវេះពន្ធ។

៥- ក្នុងអំឡុងពេលចូលទៅធ្វើការស៊ើបអង្កេត មន្ត្រីពន្ធដារត្រូវមានអាកប្បកិរិយាសមរម្យ ចៀសវាងប្រការដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយសនិងអាជីវកម្មរបស់អ្នកជាប់ពន្ធ។

## ផ្នែកទី៣

## ទណ្ឌកម្មរដ្ឋបាល

**មាត្រា២៣១ .-** ប្រភេទទណ្ឌកម្មរដ្ឋបាល

១- ទណ្ឌកម្មរដ្ឋបាលដែលកំណត់ក្នុងច្បាប់នេះ រួមមានពន្ធបន្ថែម ការប្រាក់ ការផាកពិន័យជាប្រាក់ ការព្យួរឬការដកហូតអាជ្ញាបណ្ណ ការបិទអាជីវកម្មជាបណ្តោះអាសន្ន និងទណ្ឌកម្មរដ្ឋបាលផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

២- ការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាល ជាសមត្ថកិច្ចរបស់រដ្ឋបាលសារពើពន្ធ។ អង្គភាពមានសមត្ថកិច្ចរបស់រដ្ឋបាលសារពើពន្ធ អាចទទួលបានសិទ្ធិក្នុងការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាល តាមការកំណត់របស់លិខិតបទដ្ឋានគតិយុត្តជាធរមាន។ ការតវ៉ាចំពោះការសម្រេចរបស់អង្គភាពមានសមត្ថកិច្ចរបស់រដ្ឋបាលសារពើពន្ធ ត្រូវអនុវត្តស្របតាមមាត្រា២៣៦នៃច្បាប់នេះ។

**មាត្រា២៣២ .-** ការអនុវត្តពន្ធបន្ថែម

១- ពន្ធបន្ថែមត្រូវអនុវត្តចំពោះអំពើល្មើសបទប្បញ្ញត្តិស្តីពីពន្ធដារ។

២- ពន្ធបន្ថែមសម្រាប់ការបង់ពន្ធខ្វះឬការបង់យឺត ត្រូវគណនាដាច់ដោយឡែកពីការផាកពិន័យជាប្រាក់ចំពោះការប្រព្រឹត្តអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ។

៣- ក្នុងករណីមានការបង់ពន្ធខ្វះ ពន្ធបន្ថែមនិងការប្រាក់ ត្រូវដល់កំណត់និងត្រូវបង់តាមបែបបទដូចគ្នានឹងការអនុវត្តចំពោះប្រាក់ពន្ធដែលបានបង់ខ្វះនោះ។

៤- ទោះបីក្នុងករណីណាក៏ដោយ ការដាក់ឱ្យអនុវត្តពន្ធបន្ថែមមិនមានផលប៉ះពាល់ដល់ការអនុវត្តទណ្ឌកម្មព្រហ្មទណ្ឌចំពោះអំពើល្មើសនឹងបទប្បញ្ញត្តិស្តីពីពន្ធដារឡើយ។



https://www.moj.gov.kh/kh/law-regular

**មាត្រា២៣៣.-** ពន្ធបន្ថែមនិងការប្រាក់

ពន្ធបន្ថែមនិងការប្រាក់ត្រូវបានកំណត់ដូចខាងក្រោម៖

១- ចំពោះបុគ្គលដែលប្រព្រឹត្តអំពើធ្វេសប្រហែសដូចមានចែងក្នុងមាត្រា២២៣នៃច្បាប់នេះ ប្រាក់ពន្ធបន្ថែមត្រូវស្មើនឹង១០(ដប់)ភាគរយនៃចំនួនប្រាក់ពន្ធដែលបង់ខ្វះឬបង់យឺត បូកបន្ថែមការប្រាក់១,៥(មួយក្បៀសប្រាំ)ភាគរយ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួនប្រាក់ពន្ធខ្វះមិនទាន់បានបង់។

២- ចំពោះបុគ្គលដែលប្រព្រឹត្តអំពើធ្វេសប្រហែសធ្ងន់ធ្ងរដូចមានចែងក្នុងមាត្រា២២៤នៃច្បាប់នេះ ប្រាក់ពន្ធបន្ថែមត្រូវស្មើនឹង២៥(ម្ភៃប្រាំ)ភាគរយនៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់១,៥(មួយក្បៀសប្រាំ)ភាគរយនៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធខ្វះមិនទាន់បានបង់។

៣- ក្នុងករណីការកំណត់ពន្ធជាឯកតោភាគី ប្រាក់ពន្ធបន្ថែមត្រូវស្មើនឹង៤០(សែសិប)ភាគរយនៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់១,៥(មួយក្បៀសប្រាំ)ភាគរយនៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធខ្វះមិនទាន់បានបង់។

៤- ក្នុងករណីការកំណត់ពន្ធជាឯកតោភាគីចំពោះការមិនដាក់លិខិតប្រកាស ប្រាក់ពន្ធបន្ថែម ត្រូវស្មើនឹង៤០(សែសិប)ភាគរយនៃចំនួនប្រាក់ពន្ធដែលបានកំណត់ បូកបន្ថែមការប្រាក់១,៥(មួយក្បៀសប្រាំ)ភាគរយនៃចំនួនប្រាក់ពន្ធដែលបានកំណត់សម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធមិនទាន់បានបង់។

៥- ប្រសិនបើបុគ្គលមិនបានបង់ពន្ធក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ក្រោយពេលបានទទួលលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ ពន្ធបន្ថែមត្រូវកំណត់តាមអត្រា២៥(ម្ភៃប្រាំ)ភាគរយនៃទឹកប្រាក់ពន្ធបង់យឺត បូកនឹងការប្រាក់១,៥(មួយក្បៀសប្រាំ)ភាគរយនៃទឹកប្រាក់ពន្ធបង់យឺតសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួនប្រាក់ពន្ធនោះនៅមិនទាន់បានបង់។

៦- ពន្ធបន្ថែមចំពោះការយឺតយ៉ាវក្នុងការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងពន្ធប្រថាប់ត្រា ត្រូវស្មើនឹង១០០(មួយរយ)ភាគរយនៃប្រាក់ពន្ធត្រូវបង់។

៧- ការប្រាក់ដូចមានចែងក្នុងមាត្រានេះ ត្រូវគិតចាប់ពីថ្ងៃទី១នៃខែបន្ទាប់ពីខែដែលត្រូវបង់ពន្ធ។ ចំពោះពន្ធលើប្រាក់ចំណូល ការប្រាក់ត្រូវគិតចាប់ពីថ្ងៃទី១នៃខែបន្ទាប់ដែលជាខែផុតរយៈពេលកំណត់សម្រាប់ការដាក់លិខិតប្រកាសលទ្ធផលប្រចាំឆ្នាំ។ ការប្រាក់មិនត្រូវអនុវត្តទេ ក្នុងរយៈពេលកំណត់ពន្ធឡើងវិញតាមមាត្រា២១១នៃច្បាប់នេះ ឬក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ក្រោយការប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធតាមមាត្រា២១៣នៃច្បាប់នេះ។

**មាត្រា២៣៤.-** ការព្រមានជាលាយលក្ខណ៍អក្សរ

ត្រូវព្រមានជាលាយលក្ខណ៍អក្សរដោយរដ្ឋបាលសារពើពន្ធចំពោះបុគ្គលដែលប្រព្រឹត្តអំពើរាំងស្ទះផ្សេងៗក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃមាត្រា២២៥នៃច្បាប់នេះ។



https://www.moj.gov.kh/kh/law-regular

**មាត្រា២៣៥ .-** ការផាកពិន័យជាប្រាក់ចំពោះអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្ដីពីពន្ធដារ

ការផាកពិន័យជាប្រាក់ចំពោះអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្ដីពីពន្ធដារត្រូវបានកំណត់ដូចខាងក្រោម៖

១- ត្រូវផាកពិន័យជាប្រាក់ចំនួន៥ ០០០ ០០០(ប្រាំលាន)រៀល ដោយរដ្ឋបាលសារពើពន្ធ ដោយពុំទាន់គិតដល់ទណ្ឌកម្មរដ្ឋបាលផ្សេងទៀត ចំពោះបុគ្គលដែលធ្លាប់ត្រូវបានទទួលការព្រមានជាលាយលក្ខណ៍អក្សរពីរដ្ឋបាលសារពើពន្ធលើសពី២(ពីរ)លើក ហើយនៅតែប្រព្រឹត្តនូវអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្ដីពីពន្ធដារណាមួយ ដូចមានចែងក្នុងកថាខណ្ឌទី១ កថាខណ្ឌទី២ និងកថាខណ្ឌទី៣នៃមាត្រា២២៥នៃច្បាប់នេះ។

២- ត្រូវផាកពិន័យជាប្រាក់ចំនួន១០ ០០០ ០០០(ដប់លាន)រៀល ដោយរដ្ឋបាលសារពើពន្ធ ដោយពុំទាន់គិតដល់ទណ្ឌកម្មរដ្ឋបាលផ្សេងទៀត ចំពោះបុគ្គលដែលបានប្រព្រឹត្តអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្ដីពីពន្ធដារណាមួយ ដូចមានចែងក្នុងកថាខណ្ឌទី៤ កថាខណ្ឌទី៥ កថាខណ្ឌទី៦ កថាខណ្ឌទី៧ និងកថាខណ្ឌទី៨នៃមាត្រា២២៥នៃច្បាប់នេះ។

៣- ក្នុងករណីដែលបុគ្គលដែលត្រូវបានសម្រេចឱ្យបង់ប្រាក់ផាកពិន័យដូចមានចែងក្នុងកថាខណ្ឌទី១ ឬកថាខណ្ឌទី២នៃមាត្រានេះរួចហើយ ហើយបុគ្គលនោះបានប្រព្រឹត្តនូវអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្ដីពីពន្ធដារណាមួយ ដូចមានចែងក្នុងកថាខណ្ឌទី១ កថាខណ្ឌទី២ កថាខណ្ឌទី៣ កថាខណ្ឌទី៤ កថាខណ្ឌទី៥ កថាខណ្ឌទី៦ កថាខណ្ឌទី៧ និងកថាខណ្ឌទី៨នៃមាត្រា២២៥នៃច្បាប់នេះម្ដងទៀត បុគ្គលនោះត្រូវមានទោសព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា២៤៣នៃច្បាប់នេះ។

## ផ្នែកទី៤
## ដំណោះស្រាយការតវ៉ារបស់អ្នកជាប់ពន្ធ

**មាត្រា២៣៦ .-** វិធាននៃបណ្ដឹងតវ៉ាខាងរដ្ឋបាល

វិធាននៃដំណោះស្រាយបណ្ដឹងតវ៉ារបស់អ្នកជាប់ពន្ធអំពីបញ្ហាសារពើពន្ធ ត្រូវបានកំណត់ដូចខាងក្រោម៖

១- អ្នកជាប់ពន្ធដែលមិនយល់ព្រមនឹងការកំណត់ពន្ធឡើងវិញ ការផាកពិន័យជាប្រាក់ ឬសេចក្ដីសម្រេចផ្សេងទៀតដែលធ្វើឡើងដោយអង្គភាពមានសមត្ថកិច្ចរបស់រដ្ឋបាលសារពើពន្ធ អាចធ្វើការតវ៉ាទៅអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ។ ការតវ៉ាត្រូវមានកម្រិតព្រំដែនតែត្រឹមដើមហេតុឬព័ត៌មានផ្សេងទៀតដែលមាននៅក្នុងការកំណត់ពន្ធឡើងវិញ សេចក្ដីសម្រេចឬនីតិវិធីនៃការកំណត់ពន្ធឡើងវិញប៉ុណ្ណោះ។

២- ការតវ៉ាខាងរដ្ឋបាល ត្រូវធ្វើជាលាយលក្ខណ៍អក្សរទៅតាមទម្រង់ដូចមានចែងក្នុងមាត្រា២៣៧នៃច្បាប់នេះ និងត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធក្នុងរយៈពេលយ៉ាងយឺតបំផុត៣០(សាមសិប)ថ្ងៃ ក្រោយថ្ងៃដែលអ្នកជាប់ពន្ធបានទទួលលិខិតជូនដំណឹងទារបំណុលពន្ធ ការផាកពិន័យជាប្រាក់ ឬសេចក្ដីសម្រេចផ្សេងទៀត ដែលធ្វើឡើងដោយអង្គភាពមានសមត្ថកិច្ចរបស់រដ្ឋបាលសារពើពន្ធ។

៣- ការតវ៉ាខាងរដ្ឋបាលពុំធ្វើឱ្យអ្នកជាប់ពន្ធរួចផុតពីកាតព្វកិច្ចបង់ប្រាក់ពន្ធ ពន្ធបន្ថែម ការប្រាក់ និងការផាកពិន័យជាប្រាក់ផ្សេងៗដែលបញ្ជាក់នៅក្នុងលិខិតជូនដំណឹងទារបំណុលពន្ធ ការផាកពិន័យជាប្រាក់ ឬសេចក្ដីសម្រេចផ្សេងទៀត ដែលធ្វើឡើងដោយអង្គភាពមានសមត្ថកិច្ចរបស់រដ្ឋបាលសារពើពន្ធឡើយ។


https://www.moj.gov.kh/kh/law-regular

**មាត្រា២៣៧ .-** ខ្លឹមសារបណ្តឹងតវ៉ាខាងរដ្ឋបាលរបស់អ្នកជាប់ពន្ធ

១- ការតវ៉ាខាងរដ្ឋបាលអាចនឹងទទួលយកបាន ប្រសិនបើក្នុងពាក្យតវ៉ានោះមានខ្លឹមសារដូចខាងក្រោម៖

ក- លេខអត្តសញ្ញាណកម្មរបស់អ្នកជាប់ពន្ធដែលធ្វើពាក្យតវ៉ា។

ខ- សេចក្តីយោងទៅរកការកំណត់សេចក្តីសម្រេចឬលទ្ធផលដែលជាកម្មវត្ថុនៃពាក្យតវ៉ា។

គ- ដើមហេតុឬអំពើដែលជាកម្មវត្ថុនៃពាក្យតវ៉ា។

ឃ- ហេតុផលនៃការតវ៉ា។

ង- កាលបរិច្ឆេទនិងហត្ថលេខារបស់អ្នកជាប់ពន្ធ និងហត្ថលេខារបស់តំណាងស្របច្បាប់របស់អ្នកជាប់ពន្ធ។

២- វិធាននិងនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ាត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៣៨ .-** សេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធ

១- រដ្ឋបាលសារពើពន្ធត្រូវចេញសេចក្តីសម្រេចជាថ្មីក្នុងរយៈពេលយ៉ាងយឺតបំផុត៦០(ហុកសិប)ថ្ងៃ ក្រោយពីថ្ងៃបានទទួលពាក្យតវ៉ាដើម្បីបញ្ជាក់ភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវទាំងស្រុង ឬចំណែកណាមួយនៃការកំណត់ពន្ធ ឬសេចក្តីសម្រេចផ្សេងៗដែលអ្នកជាប់ពន្ធតវ៉ា។ រដ្ឋបាលសារពើពន្ធត្រូវបញ្ជាក់ផងដែរនូវមូលដ្ឋាននៃការសម្រេចនេះ។

២- ប្រសិនបើអ្នកជាប់ពន្ធមិនយល់ព្រមលើសេចក្តីសម្រេចថ្មីនេះរបស់រដ្ឋបាលសារពើពន្ធ អ្នកជាប់ពន្ធអាចដាក់ពាក្យតវ៉ាទៅគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធក្នុងរយៈពេលយ៉ាងយឺតបំផុត៣០(សាមសិប)ថ្ងៃ ក្រោយពីថ្ងៃដែលបានទទួលសេចក្តីសម្រេច។

**មាត្រា២៣៩ .-** គណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ

១- ត្រូវបានបង្កើតគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ មានភារកិច្ចដើម្បីពិនិត្យដោះស្រាយលើបណ្តឹងតវ៉ារបស់អ្នកជាប់ពន្ធដែលមិនពេញចិត្តចំពោះសេចក្តីសម្រេចឬវិធានការចុងក្រោយរបស់អគ្គនាយកដ្ឋានពន្ធដារពាក់ព័ន្ធនឹងវិវាទពន្ធដារ។

២- ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធត្រូវកំណត់ដោយអនុក្រឹត្យតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៤០ .-** បណ្តឹងទៅតុលាការ

១- អ្នកជាប់ពន្ធមានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ចជំទាស់នឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធក្នុងរយៈពេលយ៉ាងយឺតបំផុត៣០(សាមសិប)ថ្ងៃ ក្រោយពីបានទទួលដំណឹងស្តីពីសេចក្តីសម្រេចនោះ។

២- អ្នកជាប់ពន្ធត្រូវតម្កល់ទុកនៅធនាគារជាតិនូវប្រាក់ឬទ្រព្យដែលមានតម្លៃសមមូលយ៉ាងតិចស្មើនឹងចំនួនប្រាក់ពន្ធដែលទាក់ទិននឹងវិវាទ មុននឹងដាក់ពាក្យបណ្តឹងទៅតុលាការ។ វិធាននិងនីតិវិធីនៃការកំណត់និងការផ្តាច់ចោលតម្កល់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



https://www.moj.gov.kh/kh/law-regular

**មាត្រា២៤១ ._** ការអនុវត្តសេចក្តីសម្រេចស្តីពីការផាកពិន័យជាប្រាក់

១_ រដ្ឋបាលសារពើពន្ធ អាចប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនតាមការកំណត់ក្នុងច្បាប់នេះ ដើម្បីធានាដល់ប្រសិទ្ធភាពនៃការអនុវត្តសេចក្តីសម្រេចស្តីពីការផាកពិន័យជាប្រាក់ នៅពេលដែលសេចក្តីសម្រេចនេះចូលជាស្ថាពរ។

២_ ក្នុងករណីចាំបាច់ និងដើម្បីធានាដល់ប្រសិទ្ធភាពនៃការអនុវត្តសេចក្តីសម្រេចស្តីពីការផាកពិន័យជាប្រាក់ចូលជាស្ថាពរ បទប្បញ្ញត្តិនៃជំពូកទោល(បទប្បញ្ញត្តិទូទៅ)នៃមាតិកាទី១(បទប្បញ្ញត្តិទូទៅ) ជំពូកទោល(ការបង្ខំដល់រូបកាយ)នៃមាតិកាទី៣(ការបង្ខំដល់រូបកាយ)នៃគន្ថីទី៨នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្ត ក្នុងករណីដែលសេចក្តីសម្រេចអំពីការផាកពិន័យជាប្រាក់បានចូលជាស្ថាពរ។

## ផ្នែកទី៥

## ទណ្ឌកម្មព្រហ្មទណ្ឌ

**មាត្រា២៤២ ._** បទល្មើសគេចវេះពន្ធ

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត អភិបាល បណ្ណាធិការ កម្មសិទ្ធិកររបស់សហគ្រាសណាមួយ ឬបុគ្គលទទួលខុសត្រូវឱ្យសហគ្រាសណាមួយដែលបានប្រព្រឹត្តអំពើគេចវេះពន្ធដូចមានចែងក្នុងមាត្រា២២៦នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ២០០ ០០០ ០០០(ពីររយលាន)រៀល។

**មាត្រា២៤៣ ._** បទល្មើសរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី៥០ ០០០ ០០០(ហាសិបលាន)រៀល ទៅ១០០ ០០០ ០០០ (មួយរយលាន)រៀល ចំពោះបុគ្គលដែលបានប្រព្រឹត្តអំពើរាំងស្ទះដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារណាមួយ ដូចខាងក្រោម៖

១_ ព្យាយាមរារាំងការកំណត់និងការប្រមូលពន្ធ។

២_ កសាងឬផ្តល់នូវកំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានក្លែងបន្លំ។

៣_ លាក់ទុកឬបំផ្លាញចោលដោយចេតនានូវបញ្ជិកាគណនេយ្យ កំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានផ្សេងៗ។

៤_ ចេញវិក្កយបត្រក្លែងបន្លំ។

៥_ មិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធចូលគ្រឹះស្ថានអាជីវកម្មដើម្បីកំណត់និងប្រមូលពន្ធ។

**មាត្រា២៤៤ ._** ការធ្វើឱ្យធ្លាយការសម្ងាត់

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត បុគ្គលណាដែលបានធ្វើឱ្យធ្លាយការសម្ងាត់នៃព័ត៌មានពន្ធដារ ដោយបំពានមាត្រា១៩៧នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី៥០ ០០០ ០០០(ហាសិបលាន)រៀល ទៅ១០០ ០០០ ០០០ (មួយរយលាន)រៀល។


https://www.moj.gov.kh/kh/law-regular

**មាត្រា២៤៥ .-** ការប្រកបវិជ្ជាជីវៈជាភ្នាក់ងារសេវាកម្មពន្ធដារដោយគ្មានអាជ្ញាបណ្ណ

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត បុគ្គលដែលប្រកបវិជ្ជាជីវៈជាភ្នាក់ងារសេវាកម្មពន្ធដារដោយគ្មានអាជ្ញាបណ្ណ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀល ទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល។

**មាត្រា២៤៦ .-** ការខកខានមិនបានបង់ប្រាក់ពន្ធដែលបានប្រមូលរួច

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត បុគ្គលដែលខកខានមិនបានបង់ប្រាក់ពន្ធដែលបានប្រមូលរួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី៥០ ០០០ ០០០(ហាសិបលាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល។

**មាត្រា២៤៧ .-** ការប្រមូលប្រាក់ពន្ធដែលមិនមានសិទ្ធិប្រមូល

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត បុគ្គលដែលធ្វើការប្រមូលប្រាក់ពន្ធ ដោយមិនទទួលបានសិទ្ធិពីរដ្ឋឬការអនុញ្ញាតស្របតាមការកំណត់របស់ច្បាប់នេះឬលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី៥០ ០០០ ០០០(ហាសិបលាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល។

**មាត្រា២៤៨ .-** ការទទួលខុសត្រូវផ្នែករដ្ឋបាលរបស់មន្ត្រីពន្ធដារ

មន្ត្រីពន្ធដារទាំងឡាយណាដែលអនុវត្តបំពានបទប្បញ្ញត្តិនៃច្បាប់នេះនិងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានផ្សេងទៀត ក្នុងការអនុវត្តមុខងារនិងភារកិច្ចរបស់ខ្លួន ត្រូវទទួលទណ្ឌកម្មរដ្ឋបាលស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត។ ទណ្ឌកម្មរដ្ឋបាលនេះ មិនមែនជាឧបសគ្គសម្រាប់ការចោទប្រកាន់និងការផ្តន្ទាទោសព្រហ្មទណ្ឌ ព្រមទាំងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ស្របតាមច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀតឡើយ។

**មាត្រា២៤៩ .-** ការទទួលខុសត្រូវរបស់នីតិបុគ្គល

១_ នីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា២៤២ មាត្រា២៤៣ មាត្រា២៤៥ មាត្រា២៤៦ មាត្រា២៤៧ និងមាត្រា២៥០នៃច្បាប់នេះ។

២_ ចំពោះនីតិបុគ្គលដែលប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងមាត្រា២៤២នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ២០០ ០០០ ០០០(ពីររយលាន)រៀល។

៣_ ចំពោះនីតិបុគ្គលដែលប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងមាត្រា២៤៣ មាត្រា២៤៦ និងមាត្រា២៤៧នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥០ ០០០ ០០០(ហាសិបលាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល។



https://www.moj.gov.kh/kh/law-regular

៤_ ចំពោះនីតិបុគ្គលដែលប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងមាត្រា២៤៩នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀល ទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល។

៥_ ចំពោះនីតិបុគ្គលដែលប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងមាត្រា២៥០នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥០ ០០០ ០០០(ហាសិបលាន)រៀល ទៅ២០០ ០០០ ០០០(ពីររយលាន)រៀល។

៦_ នីតិបុគ្គលអាចត្រូវប្រកាសទោសបន្ថែមណាមួយ ឬច្រើនដូចមានចែងក្នុងមាត្រា១៦៨(ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២៥០ ._** ការទទួលខុសត្រូវរបស់អ្នកផ្តើមគំនិត និងអ្នកសមគំនិត

អ្នកផ្តើមគំនិតឬអ្នកសមគំនិត ដែលមានជាអាទិ៍ជួយជ្រោមជ្រែង អូសទាញ ផ្តល់គំនិត ឬជំរុញបុគ្គលម្នាក់ទៀតឱ្យប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារដូចមានចែងក្នុងច្បាប់នេះនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត ត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ។

**មាត្រា២៥១ ._** ការប្រព្រឹត្តបទល្មើសពុករលួយ

១_ ចំពោះបទល្មើសដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា២៤៣ មាត្រា២៤៦ និងមាត្រា២៤៧នៃច្បាប់នេះ ហើយដែលប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ត្រូវកំណត់ថាជាបទល្មើសពុករលួយ ដែលត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខតែមួយគត់របស់អង្គភាពប្រឆាំងអំពើពុករលួយ ក្នុងការស៊ើបអង្កេត និងកសាងសំណុំរឿងពុករលួយទៅតុលាការ។

២_ ការស៊ើបអង្កេតបទល្មើសពុករលួយក្នុងវិស័យពន្ធដារ និងការកសាងសំណុំរឿងពុករលួយនៅក្នុងវិស័យនេះទៅតុលាការ គឺជាសមត្ថកិច្ចផ្តាច់មុខរបស់អង្គភាពប្រឆាំងអំពើពុករលួយ ស្របតាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ។

**មាត្រា២៥២ ._** ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត

ការអនុវត្តបទប្បញ្ញត្តិនៃជំពូកទី១៨នៃច្បាប់នេះ មិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀតក្នុងករណីអំពើដែលកំណត់ថាជាបទល្មើសដូចមានចែងក្នុងច្បាប់នេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។

## ជំពូកទី១៩
## អន្តរប្បញ្ញត្តិ

**មាត្រា២៥៣ ._** អន្តរប្បញ្ញត្តិ

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលត្រូវបានដាក់ឱ្យអនុវត្តដោយផ្អែកលើមូលដ្ឋាននៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ និងវិសោធនកម្មជាបន្តបន្ទាប់ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។



https://www.moj.gov.kh/kh/law-regular

## ជំពូកទី២០

## អវសានប្បញ្ញត្តិ

**មាត្រា២៥៤ .-** និរាករណ៍

ច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៥៥ .-** ការប្រកាសឱ្យប្រើច្បាប់

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃអង្គារ ១២រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០២៣

ពសរ.២៣០៥.៥៩៤

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**


https://www.moj.gov.kh/kh/law-regular